

អ្នកប្រែ

ប៊ុច សង្វាវ៉ាន

# ជើងមេឃថ្មី

ថតជាខ្សែភាពយន្ត នៅប្រទេសបារាំង

193

អ្នកស្រី ម៉ុម សុធាវ៉ាន

895-9323

# សើចទេមើញ

ប្រលោមលោកផ្នែក មនោសញ្ចេតនា

ការផ្សាយរបស់
សមាគមអ្នកនិពន្ធខ្មែរនៅបរទេស

ស.អ.ខ.ប.
A.E.K.E.

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

រក្សាសិទ្ធិគ្រប់យ៉ាង

គ.ស. ១៩៩០ ព.ស. ២៥៣៣

បោះពុម្ពលើកទី ២



អ្នកស្រី ទិត្យ សុខាវ៉ាន ហៅ ព្រហ្ម សុន្ធីតា

រូបថត ឆ្នាំ ១៩៦៨ - អាយុ ២១ ឆ្នាំ

# អារម្ភកថា

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណអស់លោក-លោកស្រី អ្នកនាងកញ្ញា និង មិត្តអ្នកអានមួយចំនួននៅសហរដ្ឋអាមេរិក ប្រទេសបារាំង ចក្រភពអង់គ្លេស ប្រទេសសហព័ន្ធអាល្លឺម៉ង់ និង ប្រទេសដទៃខ្លះទៀតដែលធ្លាប់អានស្នាដៃរឿង ជើងមេឃថ្មី របស់ខ្ញុំតាមរយៈទំព័រសារពត៌មាន នគរធំ និង ព្រឹត្តិប័ត្រ ខ្មែរសាមគ្គី ..... ។

រឿង ជើងមេឃថ្មី ដែលលោកអ្នកនាងបានអានថ្មីម្តងទៀតនេះ បានយកមករៀបរៀងបន្ថែមបន្ថយដោយអន្លើខ្លះខុសប្លែកពីសាច់រឿងដែលលោកអ្នកនាងធ្លាប់បានអានតាមខ្នង់ទំព័រសារពត៌មាន និង ព្រឹត្តិប័ត្រ ។

លំនាំសាច់រឿង និង តួអង្គទាំងឡាយសុទ្ធតែជាការច្នៃប្រឌិតទៅតាមព្រឹត្តិការណ៍ពិតក្នុងជីវិតរបស់មជ្ឈដ្ឋានខ្មែរនៅប្រទេសបារាំង ។ រឿងនេះក៏បានយកមកច្នៃថតជាខ្សែភាពយន្តខ្មែរពណ៌ធម្មជាតិ ទំហំ ១៦ ម.ម. រួចជាស្រេចកាលពីចុងខែកក្កដា ១៩៨៨ ហើយក៏បានបើកបញ្ចាំងសម្ពោធលើកដំបូងនៅទីក្រុងប៉ារីស៍ កាលពីថ្ងៃទី ៥ មិនា ១៩៨៩ ។

សមាគមអ្នកនិពន្ធខ្មែរ នៅបរទេសបានសំរេចយករឿងនេះមកបោះពុម្ពផ្សាយជាសៀវភៅប្រលោមលោក ដើម្បីទុកជាកញ្ចក់ដ៏តូចមួយសំរាប់ឆ្លុះពីសង្គមខ្មែរក្នុងសម័យដែលយើងទាំងអស់គ្នារសាត់អណ្តែតមកស្នាក់អាស្រ័យលើទឹកដីរបស់គេ បន្ទាប់ពីព្រឹត្តិការណ៍ដ៏ខ្មៅងងឹត ១៧ មេសា ១៩៧៥ មក ។

ឆ្លៀតពេលនេះ ខ្ញុំសូមឧទ្ទិសជូនចំពោះ លោកប៉ា អ្នកម្តាយដ៏ជាទីគោរព និង មានគុណធ្ងន់ ចាត់ទុកជាព្រះរស់របស់ខ្ញុំ ដែលបានបណ្តុះ

បណ្តាល អោយ កូន ស្រី បាន រៀន សូត្រ មាន ចំណេះ វិជ្ជាសក្តិ សម ជា ស្រី ខ្មែរ ម្នាក់ ។ លោកអ្នកមានគុណទាំងទ្វេបានផ្តល់កំណើត និង ឈាម ជ័រកូនស្រី អោយបានក្លាយទៅជាអ្នកស្រឡាញ់អក្សរសាស្ត្រខ្មែរម្នាក់ និង ចេះថែរក្សា ដួងព្រលឹងក្នុង លក្ខណៈជាខ្មែរ នឹតបីប្រែប្រួល ទោះក្នុងកាលៈទេសៈណា ក៏ដោយ ។

បន្ថែមពីលើនេះទៀត ខ្ញុំសូមថ្លែងអំណរគុណជាពន្លឺកចំពោះ អ្នកគ្រូខ្ញុំ ដែលបង្រៀនភាសាខ្មែរតាំងពីថ្នាក់ទី ៦ ទំនើប មានជាអាទិ អ្នកគ្រូ បាន រាសី (លោកស្រី ចេង គឹមងួន) ដែលបង្រៀនខ្ញុំនៅថ្នាក់ទី ៣ ទំនើប នៅវិទ្យាល័យព្រះយុគន្ធរ ដែលបានធ្វើអោយខ្ញុំរឹតតែស្រឡាញ់ចូលចិត្តអក្សរ សាស្ត្រ ខ្មែរ រហូត ដល់ អស់ លោក សាស្ត្រា ចារ្យ អក្សរ សិល្ប៍ ខ្មែរ នៅ មហា វិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ និង មហាវិទ្យាល័យគរុកោសល្យ និង ចំពោះលោក ប៉ិច ឈុន ស្វាមីរបស់ខ្ញុំដែលបានជួយគាំទ្រគ្រប់សកម្ម ភាពរបស់ខ្ញុំ ដោយមានការយោគយល់ និង ជួយលើកទឹកចិត្តខ្ញុំយ៉ាងច្រើន ក្នុងការនិពន្ធរឿងទាំងឡាយ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូម ថ្លែង អំណរគុណជា អតិបរិមា ចំពោះ លោក សុទ្ធ ប៉ូលីន ដែលបានជួយ លើកទឹកចិត្តខ្ញុំយ៉ាង ច្រើនក្នុងកិច្ចនិពន្ធ ដោយបានចុះ ផ្សាយ រឿង "**ជើងមេឃថ្មី**" និង រឿង ដទៃ ផ្សេងៗ ឯទៀត ក្នុង ទំព័រ សារពត៌មាន "**នគរធំ**" របស់លោក ។

ខ្ញុំសង្ឃឹមថា ប្រលោមលោក និង ខ្សែភាពយន្ត រឿង "ជើងមេឃថ្មី" នឹងបានក្លាយជាចំណីអារម្មណ៍ លោកអ្នកនាងកញ្ញា ។ សូមទុកជាសម្បត្តិ

អក្សរសាស្ត្រ និង សិល្បៈខ្មែរដ៏តូចមួយគ្រាន់នឹងបន្តពីស្នាដៃទាំងឡាយដែលបាត់បង់ទៅពីសំណាក់ជនបំផ្លាញជាតិឯង ។

សមាគមអ្នកនិពន្ធខ្មែរនៅបរទេស ព្រមទាំងរូបខ្ញុំផ្ទាល់ ក៏សូមអំពាវនាវដល់អស់លោកអ្នកនាងដែលមានទេពកោសល្យក្នុងការតែងនិពន្ធ សូមនាំគ្នានិពន្ធ សូមនាំគ្នាជួយសរសេរអោយបានច្រើនគ្នា ដើម្បីជួយទ្រទ្រង់អក្សរសាស្ត្រយើងក្នុងគ្រាដែលយើងរស់នៅក្រៅស្រុកនេះ ដើម្បីគ្រាន់ជាកញ្ចក់ឆ្លុះសង្គមខ្មែរគ្រប់កាលសម័យ ..... សូមអោយអ្នកនិពន្ធខ្មែរទាំងបុរស ទាំងស្ត្រី កាន់តែមានសម្បូណ៌ច្រើនឡើងដូចជាអ្នកនិពន្ធបរទេសនានា .....

ជយោអក្សរសាស្ត្រខ្មែរ ! ជយោវប្បធម៌ខ្មែរ !

ប៉ុងទីញើ (ប្រទេសបារាំង) ថ្ងៃទី ១៨ មិថុនា ១៩៨៩

អ្នកស្រី **ម៉ិច សង្វាវ៉ាន** ហៅ **ព្រហ្ម សុនន្ទពិតា**

# សេចក្តីឧទ្ទិស

ខ្ញុំសូមឧទ្ទិសស្នាដៃថ្មីនេះចំពោះវិញ្ញាណក្ខ័ន្ធ :

- លោក ឈាង ហ៊ប អាន
- លោក លី ធាម តេង
- លោក ជូ ថានី
- លោក ឡាំង ប៉េង សៀក

នៅខាងសមាគមអ្នកនិពន្ធខ្មែរ និង

- លោក ម៉ៅ ប៊ុន ថន នៅខាងវិទ្យុជាតិដែលធ្លាប់បានជួយលើកទឹកចិត្តខ្ញុំអោយរឹតតែស្រឡាញ់ និង មានសេចក្តីក្លាហានបំរើអក្សរសាស្ត្រខ្មែរទៀតឡើងៗជាលំដាប់ ព្រមទាំងសូមរំឭកដល់វិញ្ញាណក្ខ័ន្ធរបស់
- លោកស្រី ឡាយ សុគន្ធា ដែលជាមិត្តនារីឯករបស់ខ្ញុំនៅមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រដែលខ្ញុំនៅនឹកឃើញគ្មានគ្រាប់ភ្លេច ..... ។

វណ្ណកម្ម របស់ អ្នក និពន្ធ បម្រុង យក មក ចងក្រង បោះ ពុម្ព ផ្សាយ ក្នុង អនាគតដ៏ខ្លី មាន :

១- នេះឬបិត្តប្រុស ( ១៩៦៨ ) ( ប្រលោមលោកវែង )

២- ថ្ងៃ ៨ កក្កដា ( ១៩៦៩ ) -ដ-

៣- ខ្លោចផ្សានៅមឿងភីន ឬ អស្តង្គត(១៩៨១) (ប្រលោមលោកខ្លី)

៤- ស្តាយពាក្យមួយម៉ាត់ ( ១៩៨១ ) -ដ-

៥- ពេលដែលកន្លងទៅ ( ១៩៨១ ) -ដ-

៦- វាសនាអភ័ព្វ ( ១៩៨៣ ) -ដ-

៧- មានសង្ឃឹម ឬគ្មានសង្ឃឹម? ( ១៩៨៣ ) -ដ-

៨- ព្រោះរឿងអ្វី? ( ១៩៨៣ ) -ដ-

៩- ថ្ងៃណា? ថ្ងៃណា? ( ១៩៨៣ ) -ដ-

១០- កម្មករសេរី ( ១៩៨៣ ) -ដ-

១១- ខ្យល់សមុទ្រ ( ១៩៨៣ ) -ដ-

១២- ម្តាយក្មេកទំនើប ( ១៩៨៤ ) -ដ-

១៣- ព្រោះតែអ្នក ( ១៩៨៤ ) -ដ-

១៤- ស្រមោលស្នេហ៍ ( ១៩៨៤ ) -ដ-

១៥- ប្អូនផ្កា ( ១៩៨៤ ) -ដ-

# ជើងមេឃថ្មី

# NOUVEL HORIZON

Roman de

Madame PECH Sangwawann



Dépôt légal : 2e trimestre 1990
ISBN 2-950 40 63-0-0

# - ១ -

នៅក្នុងបន្ទប់ទទួលភ្ញៀវ លោកស្រីផានីអង្គុយលើកៅអី ទំរេតដោយខំផ្ចង់ស្មារតី ស្តាប់វិទ្យុសម្លេងខ្មែរ ផ្សាយពត៌មានសង្ខេបខ្លីៗ ស្តីពីព្រឹត្តិការណ៍ដ៏សំខាន់នានាដែលកើតមានឡើងក្នុងរបបរាជានិយម សាធារណរដ្ឋនិយម ប្រជាមានិតកម្ពុជា រហូតមកទល់នឹងរបបប្រជាធិបតេយ្យកម្ពុជាក្នុងរយៈពេលជិតប្លែឆ្នាំនេះ ។

លោកស្រីបិទប្ញារីដោយបង្អុយផ្សែងទ្រលោមហោះហើរវិលវល់ពេញបន្ទប់ទទួលភ្ញៀវ ។ លុះឮសម្រឹបជើងមនុស្សដើរនៅក្បែរនោះ លោកស្រីក៏ស្រែកហៅថា :

- សូភាព
- ចា៎ះ លោកស្រី

នារីឈ្មោះសូភាពបាន ឆ្លើយ រួចក៏ដើរយ៉ាងឱនលំទោនមកជិតចៅហ្វាយស្រី រួចក៏ដាក់ខ្លួនអង្គុយចុះទៅលើកំរាលព្រំក្បែរជើងលោកស្រីផានីទៅតាមទម្លាប់ធម្មតារបស់នាងក្នុងឋានៈជាអ្នកបំរើ ។ នាងអង្គុយបត់ជើងយ៉ាងសុភាពរាបសារង់ចាំស្តាប់ប្រសាសន៍ចៅហ្វាយស្រីដែលនិយាយមកកាន់នាងច្បាស់លះៗ មានសេចក្តីថា :

- យើងរស់ស្រុក រស់ទេសហើយ ។ ឯងក៏ដឹងស្រាប់ហើយថាយើងមករស់

នៅស្នាក់អាស្រ័យនៅស្រុកបារាំង ... ។ ដូច្នេះ អ្វីៗក៏លែងដូចពីមុនទៀតដែរ ។ លោកប្រុសរបស់ឯងក៏លែងមានឋានៈវណ្ណៈបុណ្យអ្វីទៀត គឺគ្មាននរណាគេស្គាល់ជាមន្ត្រីអ្វីទៀតឡើយ ។ ពីថ្ងៃនេះតទៅ អញលែងទុកឯងជាអ្នកបំរើអញទៀតហើយ ព្រោះអញគ្មានលុយអោយប្រាក់ខែឯងដូចពីកាលនៅក្នុងស្រុកយើងទៀតទេ ។ ដូច្នេះ ......

គ្រាន់តែឮពាក្យប៉ុណ្ណេះភ្លាម នាងសូភាពធ្លាក់ទឹកមុខមួយរំពេច ។ ទ្រូងនាងចាប់ភ័យញ័រប៉ផ្លុក ។ នារីកំសត់ក៏សាកសួរចៅហ្វាយស្រីថា :

- តើលោកស្រីគិតបណ្តេញខ្ញុំហើយឬ? ។ ខ្ញុំគ្មានទីពឹងឯណាក្រៅតែពីលោកនិង លោកស្រីទេ ។ សូមលោកស្រីមេត្តាអោយខ្ញុំបានរស់នៅ ជ្រកកោនក្រោមម្លប់គ្រួសារលោកស្រីតទៅទៀតផង ។ ខ្ញុំសូមនៅបំរើគ្រួសារលោកស្រីដូចពីមុនដដែល ....

ស្តាប់ឮពាក្យនេះកាលណា លោកស្រីផានីក៏ងក់ក្បាលថ្ងក់ៗ គោះកំទេចបារីដាក់ក្នុងក្រឡម រួចក៏បឺតបារីបង្ហុយផ្សែងមួយខ្សឹត ទើបលោកស្រីបន្តវាចាទៀតថា :

- អញមិនមែនបណ្តេញឯងទេ សូភាព ។ អញដឹងហើយថាឯងគ្មានទីពឹង ។ ឪពុកម្តាយឯងក៏ប្រហែលជាស្លាប់បាត់អស់ទៅហើយ ។ ប៉ុន្តែអញគ្រាន់តែចង់បញ្ជាក់ថា អញគ្មានលទ្ធភាពផ្តល់ប្រាក់ខែអោយឯងដូចពីមុនទេ ហើយក៏ពុំអាចចិញ្ចឹមឯងបានទៀតផង ទើបអញគិតថា ចង់អោយឯងទៅធ្វើការចិញ្ចឹមជីវិតនឹងគេចុះ ។ ឯងអាចនៅជាមួយអញដូចធម្មតាបាន ។ ក៏ប៉ុន្តែ ដោយនៅទីក្រុងដែលយើងរស់នៅសព្វថ្ងៃនេះ បងប្អូនភៀសខ្លួនខ្មែរយើងក៏កាន់តែនាំគ្នាមកដល់ជាហូរហែនោះ ។ អញហាមមិនអោយឯងទាក់ទងជាមួយនឹងខ្មែរណាជាដាច់ខាត ។ ឧបមាបើមានគេសួរ ឯងត្រូវថាឯងជាក្មួយរបស់អញ ... គ្មានឈ្នួល គ្មានចៅហ្វាយអីទៀតទេវ៉ិយ ។ នេះបើសិន

ជាឯងចង់នៅជ្រកកោនក្រោមដំបូលផ្ទះអញតទៅទៀត ឬទេ! សូភាព!!
- ចាំះ លោកស្រី
- បើអញ្ចឹង ព្រឹកស្អែកនេះ លោកប្រុសនឹងជូនឯងទៅបង្ហាញខ្លួននៅរោងចក្រដេរខោអាវមួយ ព្រោះគេកំពុងតែរកកម្មការិនីពីរនាក់
- ខ្ញុំមិនទាន់ចេះនិយាយបារាំងផង ទៅធ្វើការយ៉ាងម៉េចកើត លោកស្រី?
- ឈប់ហៅអញថាលោកស្រីទៀតទៅ ហៅថាលោកអ៊ុំស្រីបានហើយ ។ ចំណែកលោកប្រុស ឯងហៅថាលោកអ៊ុំប្រុសៗទៅណាំ
- ចាំះ លោក ... លោកអ៊ុំ ... ស្រី (សូភាពហៅទាំងតគាក់តគុប នាងដូចជារីងអណ្ដាតបន្តិចក្នុងការហៅបែបនេះជាលើកដំបូង)
- កុំទើសទាល់អី តោងខំទម្លាប់មាត់ហៅអញ្ចឹងទៅ
- ចាំះ ! ..... និយាយអំពីរឿងធ្វើការ ខ្ញុំដូចជាភ័យណាស់លោកអ៊ុំ
- កុំភ័យ! បើបារាំងគេសួរអី ឯងឆ្លើយតែ oui ! oui ! ទៅ គេស្មានតែឯង ចេះ សព្វ ចេះ គ្រប់ គេមុខ ជា ព្រម ទទួល យក ឯង អោយ ធ្វើការ ហើយ ។ នៃវ៉ុយ បើមិនខំប្រឹងជួយខ្លួនឯងនោះ គ្មាននរណាជួយឯងកើតទេ ។ អញគ្មានប្រាក់ចិញ្ចឹមឯងទេ ។ បញ្ហាធំ គឺបញ្ហាក្រពះទារបាយ ។ ឬមួយក៏ក្រពះឯងមិនចេះឃ្លាន? អើបើមិនចេះឃ្លាន សឹមខ្ជិល !
- ខ្ញុំមិនមែនខ្ជិលទេលោកអ៊ុំ ខ្ញុំគ្រាន់តែភ័យខ្លាចគេមិនយកខ្ញុំអោយធ្វើការទេតើ
- យើស! បាន អោយ ឡើង ថាន: ជា ក្មួយ អញ ក៏ហ៊ាន តមាត់ ប៉ប៉ើសភ្លាម ។ កុំនិយាយច្រើន ទៅដេកទៅពួនទៅ នឹងអាលភ្ញាក់ពីព្រលឹមចេញទៅ រកការ ធ្វើ ។ លើក នេះ លោក អ៊ុំ ប្រុស ឯង ជូន ទៅ ម្ដង ចុះ ។ លើកក្រោយៗ ត្រូវទៅម្នាក់ឯង ។ នេះអញប្រាប់អោយដឹងមុន ។
- ចាំះ លោកអ៊ុំ!

ព្រលឹមឡើង នាងសូភាពក៏ចេញពីផ្ទះជាមួយលោកស៊ីផលបាត់ទៅ ។ ថ្ងៃនេះ ភរិយាលោកស៊ីផលហែបដូចជាហេលហាលពុំដឹងជាត្រូវធ្វើអ្វីខ្លះក្នុងផ្ទះ ព្រោះលោកស្រីធ្លាប់តែស្រណុក ធ្លាប់តែមានអ្នកបំរើធ្វើជំនួស ។ ថ្ងៃនេះ នាងសូភាពទៅរកការធ្វើបាត់ ។ ដូច្នេះ កិច្ចការផ្ទះទាំងអស់ត្រូវធ្លាក់មកលើលោកស្រី ។ លោកស្រីបានបង្ខាតពេលអង្គុយជក់បារីអស់មួយដើមហើយមួយដើមទៀត ទំរាំនឹងដាច់ចិត្តចូលទៅក្នុងផ្ទះបាយដណ្តាំស្ល ។ លោកស្រីធ្វើការបណ្តើរ រអ៊ូរទាំបណ្តើរ ថា :

- នេះហេតុតែចង់អោយសូភាពវាមានការធ្វើចិញ្ចឹមជីវិតដោយខ្លួនវា ។ យី! ដល់ថ្នាក់ចៅហ្វាយដាំបាយអោយឈ្នួលស៊ីវិញហើយទេតើអញ!!

មាត់ចេះតែរអ៊ូ ដៃក៏ចេះតែធ្វើការឥតឈប់ឈរសោះ ។ ម្ហូបម្ហាក៏ឆ្អិនអស់សព្វគ្រប់ដែរ ។ ស្រាប់តែទូរស័ព្ទរោទិ៍ឡើងជាបន្ទាន់ ។ លុះស្តាប់រួច ដឹងថាសូភាពបានការធ្វើនោះ លោកស្រីផានិត្រេកអរយ៉ាងក្រៃលែង ។ លោកស្រីនឹកថា ពីថ្ងៃនេះទៅបានធូរហើយ ដោយបានសូភាពរកលុយចូលផ្ទះខ្លះនោះ ។

បើយើងនាំគ្នាសង្កេតមើលនាងសូភាពវិញ យើងឃើញទឹកមុខនាងរីករស់ស្រាយខុសពីគ្រាមុនឆ្ងាយណាស់ ។ ថ្វីបើនាងធ្វើការ ៨ ម៉ោងក្នុងរោងចក្រ ហើយប្រើពេលវេលាយូរក្នុងការទៅមកមែន តែសូភាពនៅតែញញឹមៗ ព្រោះនាងពេញចិត្តនឹងវាសនាថ្មីរបស់នាងណាស់ ។ នាងនឹកថា បើនាងនៅស្រុកខ្មែរ នាងប្រាកដជាគ្មានវាសនាបានការងារធ្វើនឹងគេទេ ។ សូម្បីតែកិច្ចការក្នុងរោងចក្រក៏ដោយ បើនាងគ្មានបក្សពួកនឹងគេនោះ ។ ហេតុនេះហើយបានជាឪពុកម្តាយនាងយកនាងមកអោយនៅបំរើគ្រួសារលោកស៊ីផលតាំងពីសូភាពអាយុបានដប់ប្រាំឆ្នាំមកម្លេះ ។ នាងត្រូវគ្រួសារលោកស៊ីផលយកមកតាមបំរើពេលដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរភាំតប្រូវ

អោយលោកស៊ីផលមកធ្វើការក្នុងស្ថានអគ្គរដ្ឋទូតប្រចាំប្រទេសថៃ ។ លុះដល់ប្រទេសខ្មែរធ្លាក់ក្នុងរបបកុម្មុយនីស្តខ្មែរក្រហម គេបំភ្លេចមន្ត្រីទាំងអស់ដែលធ្វើការនៅរដ្ឋទូតនានាចោលអស់ ទើបលោកក៏បានសុំគេចេញមករស់នៅប្រទេសបារាំង ហើយក៏បានតាំងទីលំនៅជាប់លាប់នៅ Hautepierre ដែលជាឈ្មោះទីក្រុងមួយនៃទីរួមខេត្តស្ត្រាស់បួរ៍ (Strasbourg) ។ ដូច្នេះ នាងសូភាពពុំដែលស្គាល់ការរងទុក្ខវេទនាអត់ឃ្លានក្នុងរបបប៉ុលពតទេ ។ នេះគឺដោយសារនាងមកតាមបំរើគ្រួសារលោកស៊ីផលដែរ ។

ការដឹងគុណនេះហើយដែលញុំាងអោយនាងសូភាពខិតខំយកចិត្តទុកដាក់បំរើចៅហ្វាយនាយ ។ សព្វថ្ងៃនេះ គេក៏បានក្លាយទៅជាឪពុកម្តាយធំនាងជំនួសលោកអ្នកមានគុណរបស់នាងទៅហើយ ។

ក្រៅពីម៉ោងធ្វើការក្នុងរោងចក្រ នៅក្នុងផ្ទះសូភាពបំរើគេដូចគ្រាមុនដដែល គឺធ្វើបាយទឹក រៀបចំបោសជូតផ្ទះ ហាល អ៊ុត បត់ខោអាវ ងូតទឹកអោយកូនគេ ។ល។ គឺគ្មានទំនេរដៃបន្តិចណាសោះ ។ នាងក៏មិនដែលហ៊ានសំរាកអោយបានស្រួលបួលឡើយ ហើយក៏មិនដែលត្អូញត្អែរដែរ គឺសុខចិត្តខំទ្រាំទ្រដូច្នេះទៅ ធ្វើដូចម្តេចបើនាងបានជាជំពាក់គុណគេ ។ គុណដែលសងមិនចេះចប់ ។ សូម្បីតែមូលទានប័ត្រ (chèque) ប្រាក់ខែ ក៏នាងយកទៅប្រគល់ជូនលោកស្រីផានីអោយយកទៅដាក់បញ្ចូលក្នុងធនាគារ លោកស្រីផានីបាននាំនាងទៅបើកកុង (compte) ហើយក៏បានប្រគល់សិទ្ធិអំណាចទាំងស្រុងជូនលោកស្រី ការការដាក់ដកប្រើប្រាស់បានតាមចិត្ត នេះក៏ព្រោះតែនាងល្ងង់ខ្លៅ មិនស្គាល់ មិនយល់អ្វីទាំងអស់ ហើយក៏ខ្លាចគេពេកផង ។

\+

\+ \+

## - ២ -

តាំងពីចូលធ្វើការកាលណាមក សូភាពបានស្រកទម្ងន់ជាច្រើន ។ ប៉ុន្តែទឹកមុខនាងនៅតែមានសម្រស់ដដែល ។ ភ្នែកនាងនៅតែមានរស្មីស្រទន់គួរអោយចាប់ចិត្ត ។ ថ្វីបើនាងមានសម្បុរខ្មៅបន្តិចមែន តែខ្មៅស្រស់ ។

ថ្ងៃមួយ បន្ទាប់ពីបានជួសជុលម៉ាស៊ីនដេរអោយនាងរួច ប៉ាទ្រីក(Patrick) ក៏សរសើរនាងថា :

- សូភាពឯងសំណាងណាស់ សម្បុរឯងពណ៌ស្លាន់ធម្មជាតិមិនចាំបាច់ហាលថ្ងៃឡើយ ...

សូភាពភ្ញាក់ព្រើតកាលបើឮ Patrick សរសើរនាង ។ នាងរំភើបរីករាយរកពាក្យអ្វីមកប្រដូចពុំបាន ។ នេះគឺជាលើកដំបូងក្នុងជីវិតនាងហើយដែលនាងបានឮគេសរសើរដូច្នេះ ។ តាមការពិត នាងដឹងថា បើទៅស្រុកខ្មែរវិញ សាច់ខ្មៅដូចនាង ក៏គ្រាតោកយ៉ាកថ្នាក់ធ្វើជាអ្នកបំរើគេដូចយ៉ាងរូបនាងនោះ តើមាននរណាគេយកចិត្តទុកដាក់មើលមករូបនាង? ។ តើបុរសណាមួយហើយដែលមិនសម្លឹងរកតែនារីរូបល្អ មានឋានៈខ្ពង់ខ្ពស់ មានសម្បត្តិស្តុកស្តម្ភនោះ? ។ ស្រាប់តែឥឡូវ មានប្រុសបារាំងម្នាក់ពោលវាចាសរសើរនាង ។ តើមិនអោយនាងរីករាយដូចម្តេចបាន ហ្ន៎? ។ ទោះបីនាងចេះនិយាយបារាំងបន្តិចបន្តួចក្តី ក៏សូភាពស្រីខិតខំបញ្ចេញសូរសៀងសងទៅប៉ាទ្រីក

វិញទាំងញញឹមថា :

- អរគុណ ប៉ាទ្រីក
- ពិតណាស់សូភាព ភាពឯងស្អាតមែន

សូភាពញញឹមហែបអៀនប្រៀនដាក់ប៉ាទ្រីក ហើយក៏លាចេញទៅផ្ទះបាត់ទៅ ។

រាត្រីកាលចូលមកដល់ ....

សូភាពរួចដៃពីការផ្ទះនៅវេលាម៉ោងជាង ១០ យប់ ។ នាងក៏ចូលកាន់ដំណេក ។ នៅលើពូក សូភាពចេះតែព្រួយថា ប៉ាទ្រីកដែលពោលសរសើរនាង ។ នាងញញឹមតែម្នាក់ឯងដាក់ពិតានផ្ទះ ។ នៅមិនសុខមិនសល់ ស្រីស្ទុះងើបមកឆ្លុះកញ្ចក់មើលមុខមាត់រាងរៅនាងអោយបានច្បាស់ ។ គឺចាប់តាំងពីពេលនោះមក ទើបសូភាពចាប់ចេះស្រឡាញ់ខ្លួន ចេះយកចិត្តទុកដាក់ថែទាំរូបកាយ ខុសពីគ្រាមុនៗ ។

សូភាពស៊ើចដាក់កញ្ចក់មួយ ទើបចូលកាន់ដំណេក ហើយក៏លង់លក់ទាំងអារម្មណ៍រីកថ្លាខុសសព្វមួយដង ។

ព្រលឹមឡើងជាព្រឹកថ្ងៃអាទិត្យ ។ សូភាពចូលមកក្នុងបន្ទប់លោកស្រីផានី ។ ស្រីកំព្រាលបអៀនជញ្ជាំងធ្វើរឹមអៀនៗ ចង់និយាយបន្តិច មិនចង់បន្តិច ។ លុះឃើញសូភាពស្ទាក់ស្ទើរដូច្នេះ លោកស្រីផានីក៏សួរភ្លាមថា :

- មានការអីឬសូភាពទាំងព្រលឹម?
- ចាំះ ....លោកអ៊ុំ .... នែ .... ខ្ញុំ

- ខ្ញុំ! ស្អី? និយាយ ភ្លាម ទៅ ។ អញ ស្អប់ អា រតាក់ រតុប នេះ ណាស់ និយាយអោយលេះ ស្រួលអញយល់ផងមើល!
- ចាំះ លោកអ៊ុំ .... ខ្ញុំ .... នែ៎ .... ចង់សុំប្រាក់ខ្ញុំពីលោកអ៊ុំប្រាំរយហ្រ្វង់

ឮថាប្រាំរយហ្រ្វង់ លោកស្រីស្រែកសន្ធាប់ថា :

- យី! រួចយកទៅធ្វើអីដល់ទៅប្រាំរយនោះ? ។ នែ៎ កុំរៀនចាយវាយធំពេកសូភាព ។ ឯងត្រូវចេះសន្សំសំចៃបង្ការទុកពេលណាឯងអត់ការធ្វើ ។ ថ្ងៃនេះឯងមានលុយ ព្រោះមានការធ្វើ ។ ចុះបើបន្តិចទៀត បើអត់ការធ្វើទៅ តើឯងដោះស្រាយការរស់នៅរបៀបម៉េចកើតរួា?

សូភាពធ្លាក់ទឹកចិត្តរលីង! ។ នាងនឹកថា កម្លាំងខ្លួននាងខំបញ្ចេញរកប្រាក់ ដល់នាងត្រូវការចាយវាយបន្តិចបន្តួច ក៏ត្រូវគេហាមឃាត់ទៅវិញ ។ តើនាងគ្មានសិទ្ធិចាយវាយប្រាក់ដែលបានមកពីកម្លាំងនាងផ្ទាល់ទេឬ? ។ គិតឃើញដូច្នោះកាលណា សូភាពក៏បញ្ជាក់ថា :

- លោកអ៊ុំ! ខ្ញុំចង់បានប្រាក់យកមកទិញខោអាវនិងស្បែកជើងខ្លះ ស៊ីករស់ហើយ លោកអ៊ុំ ។
- យី! ឥឡូវចេះតែងខ្លួនផងឬ? ។ ចុះសំពត់អាវនិងស្បែកជើងដែលគេចែកអោយគគោកនោះ ម្ដេចក៏មិនប្រើអោយអស់សិនទៅ?
- ខោបារាំងជើងធំៗពេក អត់ត្រូវម៉ូដគេទេ ។ ខ្ញុំខ្មាសអ្នកធ្វើការជាមួយគ្នាណាស់លោកអ៊ុំ
- លុយឯងកម្លាំងឯង អញគ្រាន់តែជួយមើលការខុសត្រូវអោយតែប៉ុណ្ណោះ ព្រោះអញឃើញឯងកំព្រឹកំព្រា ។ នែ! ទៅធ្វើការរោងចក្រស្បែកពាក់ល្អៗបានហើយណាំសូភាព ។ បើទិញហូលទិញផាមួងអីអញមិនថាទេ គ្រាន់ទុកស្លៀកពាក់ទៅបុណ្យទានខ្មែរនឹងគេម្ដងម្កាល ។

- សូមលោកវរុំរាណិតខ្ញុំម្ដងចុះ ។ ចំណែកហួលផោម្លងក៏ខ្ញុំចង់បានដែរ សូមលោកវរុំជួយបើកប្រាក់ខ្ញុំអោយខ្ញុំផងចុះ
- អើ! ចាំអញអោយ ។ ឯងប្រញាប់ទៅរៀបចំធ្វើបាយទឹកគ្រាស់គ្រែលផង ព្រោះ ថ្ងៃ នេះ អញ មាន មិត្ត ភក្តិ គេ មក លេង ដល់ ទៅ បីបួន នាក់ ឯណោះ ។
- ចាំះ

ឆ្លើយរួច នាងក៏ដើរចេញពីបន្ទប់លោកស្រីផានីទៅ ។ ប៉ុន្តែពុំដឹងជានឹកឃើញអ្វី ក៏ស្រាប់តែត្រឡប់ចូលទៅជួបលោកស្រីផានីវិញ ហើយក៏ស្រដីថា :

- លោកវរុំ ខ្ញុំ ....
- ខ្ញុំ! ស្អីទៀតហើយសូភាព?
- ចាំះ ខ្ញុំខ្លាចលោកវរុំសប្បាយនឹងភ្ញៀវពេកក៏ភ្លេចរឿងខ្ញុំសុំប្រាក់ ៥០០ ទៅ ។ ខ្ញុំសុំយកឥឡូវបានទេលោកវរុំ? ។
- យី! គឺវាដូចជាខ្លាចអញនោះសម្បើមណាស់ហ្ន៎!!

មានប្រសាសន៍រួច លោកស្រីក៏បើកកាបូបស្បែកខ្មៅដកយកប្រាក់ប្រាំរយមួយសន្លឹកថ្មីចែសយកមកហុចអោយសូភាព ។ សូភាពអរខ្លាំងណាស់ ។ ដើមទ្រូងនាងញាប់ញ័រ កាលបើបានទទួលប្រាក់ដែលបានមកពីកម្លាំងញើសនាងសុទ្ធសាធដូច្នេះ ។ តាំងពីមកដល់ស្រុកបារាំង នាងទើបតែបានស្គាល់នៅគ្រានេះឯង ។

ថ្ងៃអាទិត្យណាក៏ដូចថ្ងៃអាទិត្យណាដែរ ។ សូភាពមិនដែលទំនេរសោះពីព្រោះលោកស្រីផានីមានភ្ញៀវជានិច្ច ។ យូរៗនាងនឹកឃើញថា លោកស្រីផានីហាមមិនអោយស្គាល់ទាក់ទងរាប់អានជាមួយខ្មែរ ។ ចុះហេតុអ្វីក៏លោក

ស្រីចេះទាក់ទងនឹងខ្មែរបាន? ។ មើលចុះ! ថ្ងៃនេះភ្ញៀវមកពេញផ្ទះ ។ គឺមានស្ត្រីពីរនាក់និងបុរសម្នាក់ដែលប្រដាប់ទៅដោយអាវការពាររងាធ្វើអំពីស្បែកនិងពីរោមសត្វដ៏មានតម្លៃ បញ្ជាក់អោយឃើញថា ជាអ្នកធ្លាប់មានឋានៈខ្ពង់ខ្ពស់ មានមុខមានមាត់ពីសម័យមុនមក ។ ប្រាកដណាស់ ត្បិតលោកស្រីផានីជាមនុស្សម្នាក់ប្រកាន់ឋានៈវណ្ណៈ ។ លោកស្រីមិនដែលរាប់រកចងមិត្តភាពជាមួយអ្នកណាដែលមានឋានៈតូចទាបទន់ខ្សោយជាងលោកស្រីជាដាច់ខាត ។ បើទោះណាជាលោកស្រីមកស្នាក់អាស្រ័យក្នុងស្រុកគេក្តី ក៏លោកស្រីមិនប្តូរគំនិតចាស់ចោលជាដាច់ខាត ។

កាលបើបំរើភ្ញៀវរួចរាល់ហើយ សូភាពក៏ចូលទៅក្នុងផ្ទះបាយ ចំអិនម្ហូបអាហារវិញ ។ នាងដូចជារងាស្ទៀវស្រាញ ហើយចាប់ឈឺក្បាលខ្លាំងៗ តែស្រីកំសត់ចេះតែខំមាត់សង្កត់ចិត្តធ្វើការឥតឈប់ដៃសោះ ។ លុះលំបាកពេកម្តងៗ ស្រីអភ័ព្វចង់តែអង្គុយទ្រហោយំអោយខ្លាំងៗ ។ ពេលខ្លះតឹងទ្រូងពេកទៅ នាងចង់ត្អូញត្អែ តែពុំដឹងត្អូញប្រាប់អ្នកណា បើនាងគ្មានមិត្តភក្តិ គ្មានស្គាល់អ្នកណាម្នាក់ ។ នេះក៏ព្រោះតែស្តាប់បង្គាប់មិនហ៊ានក្បត់បណ្តាំចៅហ្វាយស្រីនោះ ។

បើគេក្រឡេកមើលទៅក្នុងបន្ទប់ទទួលភ្ញៀវឯណោះវិញ គេឮសូរមាត់លោកស្រីផានីមានប្រសាសន៍ថា :

- ខ្ញុំស្មានតែមិនបានអញ្ជើញមកទេតើ

ភ្ញៀវប្រុសម្នាក់ក៏តបវិញថា :

- បាទ! ខ្ញុំសូមទោសចុះលោកស្រី ។ ខ្ញុំបានហៅទូរស័ព្ទមកជាច្រើនដង តែហៅមិនបានសោះ ។ ទូរស័ព្ទចេះតែជាប់រវល់រហូត ។

- ចឹក៏មិនជាប់លោក បើកូនខ្ញុំវាជាប់និយាយជាមួយមិត្តភក្តិវារស់មួយព្រឹក

ធំ ។ ហ៊ឺ! វានិយាយរកគ្នាវាសុទ្ធតែបារាំងបារូស រកតែខ្ញុំស្តាប់មិនយល់

ភ្ញៀវស្រីម្នាក់ដែលមានសក់ប្រួសស្អា ក៏ស្រដីម្តងថា :

- កូនខ្ញុំក៏អញ្ចឹងដែរ អ្នកបង វាមិនព្រមនិយាយខ្មែរទាល់តែសោះ

លោកស្រីផានីដកដង្ហើមធំ ហើយក៏ឧទានឡើងថា :

- គួរអោយស្តាយណាស់ដែលយើងជាខ្មែរមិនព្រមអោយកូនយើងនាំគ្នានិយាយខ្មែរអញ្ចឹង ។ ភាសាជាតិយើងដែលយើងចេះស្រាប់ មិនគួរយើងនាំគ្នាបំភ្លេចចោលសោះ ។ ចំណែកប្តីវាក៏ចេះតែបន្ទោសខ្ញុំជារឿយៗ ថាមកពីខ្ញុំបណ្តែតបណ្តោយពេក ។ បើខ្ញុំតឹងរ៉ឹងតាំងពីដើមមក បែបកូនយើងមិនដល់ថ្នាក់នេះទេមើលទៅ ។

លោកសារីដែលអង្គុយស្តាប់ជាយូរមកហើយនោះ ក៏មានប្រសាសន៍ម្តងថា :

- បើតាមខ្ញុំយល់ ទោះជាក្មេងៗវាមិនចេះខ្មែរក៏មិនជាការអ្វីដែរ ។ .... ភាសាខ្មែរមិនមែនជាភាសាអន្តរជាតិអាចយកមកប្រើការឯណាបានឡើយ ... ។

ពុទ្ធោះ លោកស្រីជាភរិយាលោកសារីក៏ចាក់បន្ថែមទៀតថា :

- មែនហើយអ្នកបង ខ្ញុំក៏យល់ដែរថា បើយើងចេះភាសាបរទេស ដូចជាអង់គ្លេស អាល្លឺម៉ង់ អេស្ប៉ាញ៉ុលអីៗក្រែងវាថ្លៃថ្នូរជាង ។

ចំណែកលោកស្រីផានីដែលហាក់ដូចជាមិនសូវយល់ស្របតាមគំនិតរបស់មិត្តភក្តិនោះ លោកស្រីក៏ស្រដីតបទាំងទោម្នេញថា :

- ប៉ុន្តែ បងមានវិប្បដិសារីជាច្រើនដែលកូនបងមិនចេះខ្មែរនោះ ។

លោកស្រីគន្ធាក៏ជួយបន្ថែមថា :

- ចាំះ ត្រូវហើយអ្នកបង ។ ចុះបើថ្ងៃណាមួយ យើងត្រូវត្រឡប់ទៅស្រុក

យើងវិញ មិនរីកវរទៅហើយទេ ។

- ស្លាប់ហើយ (លោកស្រីសារីឆ្លើយកាត់ផ្ទង) គិតអីដល់ទៅរឿងចូលស្រុកទេសនោះ! ។ ខ្ញុំគ្មានសង្ស័យបន្តិចបន្តួចណាទេអ្នកបង ។

- បើនិយាយពីរឿងចូលស្រុកទេសនោះ ខ្ញុំក៏យល់ថា ក្មេងៗដែលធ្លាប់រស់នៅតាមរបៀបរបបស្រុកបរទេសរស់ទៅហើយ ។ ពួកវាប្រាកដជាមិនចេះរស់នៅតាមបែបថប្រទេសយើងជាដាច់ខាត ។

- ណ្ហើយ! កុំទៅគិតច្រើន យើងគិតនាំគ្នាលេងបៀតងវិញវាសប្បាយជាងមិនថារញ្ជើង!

លុះស្រុះស្រួលត្រូវរ៉ូវគ្នាហើយ ទាំងភ្ញៀវទាំងម្ចាស់ផ្ទះក៏រវល់វាយតងយ៉ាងសប្បាយ ដោយស៊ីសងប្រាក់គ្នាជាច្រើនទៀតផង ។

ចាយឆ្អិនរួចរស់ហើយ សូភាពក៏ដើរចូលមកក្នុងបន្ទប់សាឡុង ។ កាលបើប្រទះឃើញស្ថានភាពបែបនេះ នាងក៏គិតឃើញទៅដល់ប្រាក់ខែនាងភ្លាមមួយរំពេច ។ ឱ! ប្រសិនបើលោកស្រីផានីចាញ់បៀររស់នោះ ប្រាក់ខែនាងក៏ច្បាស់ជារស់ខ្ទេចជាមិនខានឡើយ ។ ណ្ហើយ! កុំរវាលគិតដល់អីនោះស្រីខំកម្លាចិត្តខ្លួនឯង ហើយក៏ដើរចូលទៅជិតលោកស្រីផានី ជំរាបសួរខ្សឹបៗថា :

- តើខ្ញុំអាចរៀបបាយឥឡូវបានទេ លោកអ៊ុំ?

- ចាំបន្តិចទៀតសិន សូភាព ។ ឯងរៀបអោយប្អូនៗញ៉ាំមុនសិនចុះ ។ ចាំកាលណាអ៊ុំឃ្លាន អ៊ុំហៅឯងមកប្រាប់

សូភាពភ្ញាក់ព្រើតនឹងពាក្យ "អ៊ុំ" ជំនួសពាក្យ "អញ" ដែលលោកស្រីផានីប្រើជាលើកដំបូងចំពោះរូបនាង ។ កាលបើធ្វើតាមបញ្ជាអ៊ុំនាងរួចស្រេចបាច់រស់ហើយ សូភាពក៏ឆ្លៀតទៅសំរាកបន្តិចដើម្បីយកកម្លាំង ។

កំពុងតែរលីវៗជិតលង់លក់ទៅហើយ ស្រាប់តែលោកស្រីផានីមកដាស់សួរនាងថា :

- វាចឺទៅហើយសូភាពបានជាដេកទាំងថ្ងៃយ៉ាងហ្នឹង?

សូភាពខំត្រដររក្រោកឡើងទាំងឆេងឆាង ។ នាងហាមាត់បម្រុងឆ្លើយតបទៅសំណួររវ៉ុស្រី តែត្រូវវ៉ុនាងសួរបន្ថែមទៀតថា :

- ម៉េចក៏មុខស្លាំងម្ល៉េះសូភាព?

- ខ្ញុំឈឺក្បាល ហើយរងាខ្លាំងណាស់លោករ៉ុ

- ហ្នឹងហើយ ច្បាស់ជាកាលពីយប់មិញរវល់តែគិតតែពីរឿងទិញអាវទិញខោថ្មីនោះហើយបានជាក្រដេកក្រពួន ។ កាលណាដេកមិនគ្រប់គ្រាន់ វាទៅជាឈឺអីចឹងហើយ

- មិនមែនមកពីរឿងហ្នឹងទេលោករ៉ុ

- កុំតវ៉ា វាគ្មានរឿងអីក្រៅពីនេះទេ

លុះមានប្រសាសន៍ចប់ហើយ លោកស្រីក៏ដើរទៅយកថ្នាំអាស្ពីរីនមួយគ្រាប់មកហុចអោយសូភាព ។

- ដាក់ទឹកកន្លះកែវ ហើយដាក់គ្រាប់ថ្នាំត្រាំអោយវារលាយអស់សឹមផឹក ។ បន្តិចទៀតវាជាហើយ ។ ឯងទៅរៀបបាយអោយភ្ញៀវមួយភ្លែតសិនទៅ សឹមមកដេកវិញ ។

អនិច្ចា! កញ្ញាកំព្រាអើយ! នាងឈឺហើយក៏គេមិនប្រណីទៀត ។ កាលពីដើមមក ទោះបីយ៉ាងណាក្ដីក៏លោកស្រីមិនដែលមានចិត្តអមនុស្សធម៌បែបនេះដែរ ។ ស្រាប់តែថ្ងៃនេះ លោកស្រីទៅជាមានចិត្តប្រែប្រួលដូច្នេះទៅវិញ ។ ឬមួយមកពីលោកស្រីចាញ់ប្រៀ? ។ ឱ! ពិបាកយល់ណាស់ចិត្តមនុស្សយើង! ។

ពីរបីថ្ងៃហើយដែលសូភាពឈឺមិនបានទៅធ្វើការ ។ ការសំរាកព្យាបាល នៅផ្ទះនេះមិនមែនជាការសំរាកអ្វីចំពោះនាងឡើយ ។ នាងខ្លាចចិត្តលោកស្រីផានីណាស់ ទោះបីជាឥឡូវនេះគេថាទុកនាងជាក្មួយក៏ដោយ ក៏ស្រីរងក័ព្ពុំ ដែលហ៊ានដំកើងខ្លួនដោយភ្លេចកំណើតរបស់ខ្លួនសោះឡើយ ។ នាងក៏យល់ដែរថា គេគ្មានទុកនាងជាកូនក្មួយដូចពាក្យដែលគេហៅគ្នាទៅវិញទៅមកអោយគ្រាន់តែនឹងពីរោះត្រចៀកនិងគ្រាន់តែសំរាប់កុហកដល់មនុស្សផងគ្នាតែប៉ុណ្ណោះទេ ។ តាមពិតទៅ គឺគេនៅតែទុកនាងជាឈ្នួលដដែល គឺឈ្នួលឥតប្រាក់ខែ ។

កាលបើសង្កេតឃើញលោកស្រីផានីចេះតែរករឿងរកហេតុនាងច្រើនពេកនោះ ថ្ងៃមួយនាងសូភាពក៏ថ្លែងទៅកាន់លោកស្រីផានីថា :

- លោកអ៊ុំ! ចាប់ពីថ្ងៃនេះតទៅ ខ្ញុំសូមបង់ជូនលោកអ៊ុំពីរពាន់ហ្វ្រង់រៀងរាល់ខែសំរាប់ជួយចេញថ្លៃផ្ទះ និងថ្លៃទទួលទានរាល់ថ្ងៃ ។ ហេតុនេះ សូមលោកអ៊ុំដកយកប្រាក់ខែខ្ញុំតាមចំនួននេះរៀងរាល់ខែចុះ

- អើ! អញបានដកយកតាំងពីយូរមកហើយ កុំទៅភ័យអី ។ បើឯងមិនជួយចេញសោះ ក៏យើងរស់នៅមិនបានគ្រប់គ្រាន់ដែរ

- អញ្ចឹង លោកអ៊ុំដកយកប្រាក់ខែខ្ញុំយូរហើយឬ?

- អើ អញបានប្រាប់ឯងជាយូរមកហើយទេតើ

- ចាះទេ ខ្ញុំពុំដែលដឹងរឿងនេះទេលោកអ៊ុំ

- អើ បើដឹងឬមិនដឹងក្តី ក៏វាត្រូវតែអញ្ចឹង គឺត្រូវតែជួយចេញគ្នាទើបបាន ។ អញមានប្រាក់ឯណាចិញ្ចឹមឯងនោះ ។ បើទោះជាឯងទៅនៅឯណាម្នាក់ឯង ក៏គង់តែឯងជួលផ្ទះនៅ ក៏ត្រូវតែចាយវាយទៅលើម្ហូបចំណីដូចតែគ្នា មិនមែនបានប្រាក់យកមកទុកសំពះថ្វាយបង្គំឯណា ។ ស្រួលមិនស្រួល បើ

នៅម្នាក់ឯងនោះ ឯងច្បាស់ជាមានបន្ទុកច្រើនជាងនេះទៅទៀតផង ។ ឯងនៅជាមួយគេញ ទោះយ៉ាងណាក៏ប្រហែលជាធូរស្រាលពីរឿងពន្ធដារខ្លះដែរ ។

សូភាពអង្គុយស្តាប់ប្រសាសន៍លោកស្រីផានីដោយយកចិត្តទុកដាក់ ។ នាងល្ងង់ដូច្នេះ បើទោះជាគេថាអ្វី ក៏នាងចេះតែជឿ ហើយធ្វើតាមគេដែរ ។ នាងគិតតែម្យ៉ាងថា ទោះអ្វីក៏ដោយក៏គ្រួសារនេះធ្លាប់មានគុណអាស្រ័យមកលើរូបនាងដែរ ។

មានថ្ងៃខ្លះ សូភាពតប់ប្រមល់ទល់ពុទ្ធោតែម្នាក់ឯង ។ នៅកន្លែងធ្វើការដោយនាងពុំសូវចេះភាសាបារាំង នាងនិយាយជាមួយបារាំងពុំត្រូវគ្នាសោះ ។ បើឃើញខ្មែរនៅតាមផ្លូវ នាងចង់រាប់អានគេណាស់ តែនាងមិនហ៊ានដោយខ្លាចខុសឱវាទរបស់លោកស្រីផានី ។

ប្រមាណប្រហែលមួយអាទិត្យហើយ សូភាពបានឃើញបុរសខ្មែរចេះតែដើរតាមនាងរាល់ពេលចេញពីធ្វើការ ។ បើគេពិនិត្យអោយមែនទៅ គេឃើញថាជាបុរសម្នាក់មានទឹកមុខស្លូតបូត ។ កាលបើដឹងខ្លួនថាត្រូវគេតាមពីក្រោយដូច្នេះ សូភាពរឹតតែខំបន្ថែមល្បឿនខុសធម្មតា ។ បុរសចម្លែកឃើញសូភាពដើរលឿន គេក៏រឹតតែដើរតាមលឿនដែរ ។ បើនាងដើរមួយៗ គេក៏ធ្វើជាបន្ថយល្បឿនទៅវិញ ។ ណាស់ៗពេកទៅ សូភាពទៅជាភិតភ័យ ត្បិតបុរសនេះពុំដឹងជាប្រាថ្នាអ្វីលើរូបនាង ។ ដើរគិតៗតែម្នាក់ឯង ស្រាប់តែឮវាចាបុរសចម្លែកស្រែកហៅនាងយ៉ាងស្រទន់ថា :

- បងស្រី កុំដើរលឿនពេក ។ ខ្ញុំសុំសួរបន្តិចបានទេ?

ព្រះអើយ! គ្រាន់តែពាក្យប៉ុណ្ណេះសោះ សូភាពទៅជាភ័យញ័រក្នុងទ្រូង ។ នាងនឹកឮួចដល់បំរាមរបស់លោកស្រីផានីដែលហាមនាងមិនអោយ

ទាក់ទងខ្មែរណានោះ ។ កាលបើងាកមើលឆ្វេងស្តាំរួច នាងក៏ដាច់ចិត្តសួរទៅគេវិញថា :

- ពូមានការអីដែរ?

បុរសចម្លែករស់សំណើច ក៏សើចក្អាកក្អាយកាលបើឮនាងហៅគេថា "ពូ" ។ សំណើចរបស់គេញាំងអោយនាងកាន់តែនឹកខ្មាសរឿន ។ ខ្មាសណាស់! ខ្មាសព្រោះមកពីខ្លួនមិនចេះប្រើពាក្យហៅបានជាគេសើចដូច្នេះ ។ សូភាពក៏ឈប់និយាយស្តីអ្វីទៀត ខំតែបង្កើនល្បឿនជំហានរបស់នាងទៅមុខយ៉ាងញាប់រន្ថើន ។

- ឈប់សិន បងស្រី! កុំដើរលឿនពេក

ឃាត់ណាស់ លឿនណាស់ ។ សូភាពដើរលឿនត្រួយ ។ បុរសនេះនៅតែខំដើរតាមនាងទៀត ។ កាលបើបានមកទន្ទឹមនាងម្តងៗ គេក៏ឆ្លៀតសួរពីនេះពីនោះ ។ សូភាពលែងខ្ជីនិយាយអ្វីទាំងរស់ ។ នាងមិនទាន់បាត់ខ្មាសនិងបាត់ខឹងពីការដែលគេសើចចំអកអោយនាងរំបាញ់មិញនៅឡើយទេ ។ ទ្រាំមិនបាន បុរសនោះក៏ស្ទុះមកដើរពីមុខនាងម្តង ។ មុខគេបែរមករកនាងគេញញឹមបន្តិច ក៏ដើរថោះជំហានថយក្រោយ ព្រោះគេចង់ឃើញមុខនាងចង់អោយនាងឆ្លើយឆ្លងរកគេវិញ ។ សូភាពរឹតតែខ្នាញ់ក្នុងចិត្ត ហើយក៏កាន់តែនឹកខឹងឡើង ។ ចុះប្រុសអីក៏ស្អិតយ៉ាងនេះ? ។ ពុំដែលឃើញទេព្រះអើយ ទើបតែប្រទះលើកទីមួយ ។ បើនាងដើរគេចមកឆ្វេង គេក៏គេចមកតាម ហើយនៅតែដើរពាំងពីមុខនាងរហូត ។ សំណាងល្អ ថ្ងៃនោះស្ងាត់ស្ងៀមហើយ គេប្រើផ្លូវនេះតែពីរនាក់គត់ ។ សូភាពក្តៅចិត្តពេក ក៏ឈប់នៅស្ងៀមម្តង បានឱកាស បុរសនេះក៏លូកចាប់ដៃនាង ។ សូភាពរលាស់ដៃចេញភ្លាម ហើយក៏ស្រដីថា :

- យី! ចុះប្រុសអីក៏ព្រហើនម្លេះ?
- ចុះ បងស្រីមិនព្រមនិយាយរកខ្ញុំធ្វើអី?
- បើគេមិននិយាយរក មកចាប់ដៃគេរញ៉េញឬ?
- ខ្ញុំមានចាប់ឯណា គ្រាន់តែសុំកាន់បន្តិចទេតើ!
- ហ្នឹងហើយ បើគេមិនអោយកាន់ ហើយហ៊ានកាន់គេៗថាចាប់រញ៉េញហើយ
- បើព្រមនិយាយរកខ្ញុំតាំងពីដំបូងមក ខ្ញុំមិនចាប់ទេ ។ ណេ្ហីយ អោយខ្ញុំសុំទោសចុះបានទេ ឬមួយក៏ទារជម្ងឺចិត្ត? អោយខ្ញុំសងប៉ុន្មាន ក៏ខ្ញុំសុខចិត្តសងដែរកុំអោយតែខឹងខ្ញុំ
- កុំនិយាយផ្តេសផ្តាសច្រើនពេក គ្មានជម្ងឺចិត្តជម្ងឺប៉ែតអីទេ ។ ថយទៅ កុំដើរតាមខ្ញុំទៀត ប្រយ័ត្នលោកវរ្ឌខ្ញុំឃើញ គាត់វាយខ្ញុំស្លាប់ហើយ
- មនុស្សរស់ធំហើយនៅវាយអីទៀត ។ រុំបងស្រីឯងក៏កាចម្លេះ? ។ បើខ្ញុំមានវុំកាចម្លឹងៗ ខ្ញុំឈប់នៅជាមួយហើយ
- តាមវីពូឯងជាប្រុស ចង់ទៅនៅឯណាក៏ចេះតែបាន
- ចុះប្រុសនិងស្រីមានសិទ្ធិស្មើគ្នាទេតើ
- ស្មើគ្នាហើយ តែខ្លះ ....

និយាយបានតែប៉ុណ្ណេះ ស្រីកំសត់ក៏ស្រក់ទឹកភ្នែកមកតក់ៗ នឹកស្រណោះអាណិតខ្លួនដែលកំព្រីកំព្រាកណ្តាចកណ្តែងម្នាក់ឯងក្នុងប្រទេសគេ ។ មាណពចម្លែកហាក់ជួយខ្លោចផ្សានឹងនេះដែរ ។ គេក៏សម្រួលវាចាអោយស្រទន់ជាងមុន ហើយថ្លែងទៅកាន់សូភាពថា ៖

- ភាព! ខ្ញុំសូមហៅឈ្មោះភាពចុះ

សូភាពងើយភក្ត្រមើលចំកែវភ្នែកអ្នកកម្លោះកាលបើឮគេហៅចំឈ្មោះ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

នាង ។ ស្រីប្រទះឃើញខ្សែភ្នែកមាណពស្រទន់ ហើយហាក់បង្ហាញពីភាសាម្យ៉ាងដែលនាំអោយស្រីខ្មាសអៀនយ៉ាងខ្លាំង ។ បុរសចាប់ចុងដៃសូភាពមកកាន់យ៉ាងថ្នមៗ ។ សូភាពបណ្តោយហត្ថានាងដាក់ក្នុងដៃបុរសចម្លែកដោយមិនដឹងខ្លួន ។ គេទាំងពីរនៅឈរទ្រឹងមួយស្របក់ ទើបយុវជននេះស្រដីឡើងថា ៖

– ភាពមិនស្គាល់ខ្ញុំមែន តែខ្ញុំបានស្គាល់ភាពច្បាស់ គឺស្គាល់ពីស្ថានភាពជីវិតរបស់ភាព ។ ខ្ញុំសូមសរសើរភាពយ៉ាងស្មោះចំពោះទឹកចិត្តអំណត់តស៊ូ ចំពោះការស្ងប់ស្ងៀម ខំបៀមទុក្ខគ្រប់បែបយ៉ាងរបស់ភាព ។ ទោះបីមិនដែលបញ្ចេញពីសេចក្តីទុក្ខនេះទៅប្រាប់នរណាម្នាក់មែន តែនេត្រាភាពបានបញ្ជាក់ពីសេចក្តីទុក្ខ ទុក្ខដ៏ធំធេងរបស់ភាពដែលអាចអោយខ្ញុំស្មានយល់ទាំងអស់ ។

ឱ! ព្រះអើយ! នេះជាគ្រាដំបូងទៀតហើយដែលសូភាពបានស្តាប់វាចាដ៏ពីរោះរណ្តំបែបនេះ ។ តើគេជាអ្នកណាទៅហ្ន៎? ។ គេជាអ្វី? ជាហោរាទេដឹងបានជាគេអាចប្រមាណពីសេចក្តីទុក្ខរបស់នាងបាន ។ បុរសនេះចេះនិយាយពីរោះមែន ។ នាងធ្លាប់ឮពាក្យពីរោះពីសារបែបនេះ តែតាមរឿងល្ខោន ឬកុនប៉ុណ្ណោះ ។ ស្រាប់តែថ្ងៃនេះ ស្រីកំសត់បានឮពាក្យនេះពេញត្រចៀកស្រស់ៗ ។ ស្រីហាក់អណ្តែតខ្លួនពីជីវិតវល់អស់ហើយ ។ នាងឮគេនិយាយទៀតថា ៖

– យើងជាកូនកំព្រាដូចគ្នា ។ ខ្ញុំចង់អោយឪពុកមាខ្ញុំទៅដណ្តឹងភាព ។ តើភាពយល់យ៉ាងណាដែរ?

– ខ្ញុំមិនដឹងទេ ពូសាកល្បងមើលទៅ (សូភាពឆ្លើយយ៉ាងអៀនប្រៀន)

– សូមភាពកុំប្រកែកណា៎

– ..........................................

សូភាពមិនបានឆ្លើយថាអ្វីទាំងអស់ ។ នាងពុំដែលគិតពីរឿងប្ដីសម្ដងណា សោះ ។ ពាក្យសំដីគ្រប់ម៉ាត់របស់មាណពនេះកាន់តែធ្វើអោយនាងអៀនអន់ ឡើង ។

- ខ្ញុំសូមបណ្ដើរភាព ជូនភាពទៅផ្ទះម្ដងបានទេ?

- ទេ! ទេ! មិនបានទេ! ។ បើលោករំខ្ញុំឃើញ រឿងរ៉ាវធំហើយ ។ គាត់ហាមមិនអោយខ្ញុំទាក់ទងជាមួយខ្មែរណាទេ ។ ពូជាប្រុសទៀតនោះរឹត តែវីវរធំហើយណាំ

- ណ្ហើយ ដើម្បីសេចក្ដីសុខរបស់ភាព ខ្ញុំគោរពតាមចុះ ។ នៅសប្ដាហ៍ ក្រោយ បើមានបុរសណាម្នាក់ឈ្មោះ "ជំនោរ" ទៅដណ្ដឹងភាព គឺរូបខ្ញុំនេះ ហើយ ។ ភាពកុំភ្លេចឈ្មោះខ្ញុំណាំ

នាងសម្លឹងភក្ត្រគេជំនួសចម្លើយរបស់នាង ។ ទ្រូងស្រីញាប់ញ័រជាពន់ ពេក ព្រោះភក្ត្រដ៏ស្រទន់របស់បុរសនេះធ្វើអោយនាងអៀនស្ទើរមុជក្រោម ធរណី ។ មាណវីឱនភក្ត្រចុះជ្រប់លែងចេញស្ដី ។ មាណពដែលមាននាមថា "ជំនោរ" យល់ចិត្តស្រី ក៏ស្រដីលាទាំងអាឡោះអាល័យ ថែមទាំងផ្ដែផ្ដាំ ថា ៖

- ខ្ញុំលាសិនហើយណាំភាព ... នឹកមកខ្ញុំផងណាំភាពណាំ

\+

\+ \+

## – ៣ –

រសៀលថ្ងៃមួយ លោកស្រីផានីក៏លើកយកបញ្ហានាងសុភាពមកពិគ្រោះជាមួយស្វាមី ។

– ប៉ាវ៉ា! លោកសុភក្ត្រចូលមកដណ្ដឹងកាភាពអោយជំនោរក្មួយប្រុសគេជាច្រើនដងណាស់ហើយ ។ តើប៉ាវ៉ាឯងថាយ៉ាងម៉េចដែរ?

លោកស្រីផានីសួរទៅស្វាមីដែលកំពុងតែរវល់អានកាសែតយ៉ាងជក់ជាប់ចិត្ត ។ លោកឥតបានឮភរិយាសួរលោកពីរឿងអ្វីទេ ទាល់តែលោកស្រីជាភរិយាសង្ហើញសួរខ្លាំងៗម្ដងទៀត ទើបលោកឆ្លើយយ៉ាងបីថា ៖

– ស្រេចតែម៉ាក់វ៉ាឯងទេ

– យី! ស្រេចតែខ្ញុំយ៉ាងម៉េចប៉ាវ៉ា? ខ្ញុំសួរក៏ព្រោះតែខ្ញុំចង់អោយប៉ាវ៉ាឯងជួយគិតគូរខ្ញុំណាំ

– ចុះចាំបាច់គិតអីច្រើន ។ អោយឬមិនអោយ ឆ្លើយប្រាប់គេអោយខ្លីៗទៅ វ៉ាចប់ទៅហើយ ។ មិនដឹងជាគិតគូរអីច្រើននាំអោយតែវ៉ាពិបាក ខ្ញុំដូចជាឆ្ងល់ដែរ ។

– នែ៎ មិនមែនអញ្ចឹងទេប៉ាវ៉ា ។ លោកសុភក្ត្រនិងគ្រួសារយើងជាមិត្តនឹងគ្នា ។ បើយើងព្រមឬមិនព្រម ក៏តោងតែយើងបញ្ជាក់ពីហេតុពីផលអោយ

ច្បាស់ណាស់ដែរ ។ មិនមែនចេះតែថាងាយដូចប៉ាវាឯងនោះទេ ។ កាភាព បើរោយវាមានប្ដីក៏ចេះតែបាន ប៉ុន្តែខ្ញុំចាញ់ហៀយកលុយកាក់វាទៅសងគេ អស់ហើយហើយ ។ បើរោយវាមានប្ដី យើងត្រូវតែមានប្រាក់គ្រប់ចំនួនសង វិញ ។ តើយើងទៅរកប្រាក់ឯណាបានដល់ទៅពីរបីម៉ឺននោះ?

- រឿងម៉ាក់វាយកលុយវាទៅលេងបៀរអស់នោះ ខ្ញុំមិនដឹងទេ ។ បើម៉ាក់វាឯងនិយាយដូច្នេះ មានតែចង់ទុកវា កុំរោយវាមានប្ដី ។ ទេ! គ្នាមិនដឹងទេម៉ាក់វា ស្រេចតែម៉ាក់វាឯងគិតគូរដោះស្រាយយ៉ាងណារោយបានសមរម្យទៅចុះ ។ រឿងនេះជារឿងរបស់ស្រីៗ ។ ខ្ញុំជាប្រុស ខ្ញុំពិបាករវារកាត់ណាស់ ។

ពុះដូច្នោះកាលណា លោកស្រីរឹតតែតានតឹងក្នុងចិត្តឡើង ។ លោកស្រីបឺតបារីមួយខ្សឺត ហើយបង្ហុយផ្សែងទ្រលោម ។ នេត្រាទាំងគូផ្ដោតមើលទៅផ្សែងបារីដែលកំពុងតែរវើរវាត្រសែតវិលវល់នៅពីមុខ ។ រំពេចនោះ លោកស្រីផានីក៏បញ្ចេញវាចាទាំងទឹកមុខញញឹមថា ៖

- ខ្ញុំនឹកឃើញហើយប៉ាវា

លោកស៊ុផលដកភ្នែកពីសារពត៌មាន រួចមើលមកភរិយាដោយអាការៈងឿងឆ្ងល់ ហើយក៏សួរថា ៖

- នឹកឃើញរឿងអីម៉ាក់វា? (រួចក៏ដើរចេញបាត់ទៅ)

.............................................................................................

រំលងមួយសប្ដាហ៍ក្រោយមក លោកស្រីផានីក៏ហៅនាងសូភាពមកនិយាយស្ងាត់ៗថា ៖

- សូភាពឯងជិតមានប្ដីហើយ ។ អញគិតថា ឯងជាស្រីត្រូវតែមានអលង្ការ

ខ្លះទុកពាក់កុំអោយប្តីមើលងាយ ។ តើឯងស្រឡាញ់ចិញ្ចៀននេះទេ? ។ ល្អណាស់ ឃើញទេ ។ ចិញ្ចៀននេះគេយកមកលក់អោយអញ ។ ប៉ុន្តែអញមានពាក់គគោកហើយ អញក៏នឹកឃើញដល់ឯង ។ ឯងពាក់លមើល តើពាក់ល្អមទេ? ។

សូភាពទទួលចិញ្ចៀនមកសិកពាក់ក្នុងនាងដៃ រួចផ្ទៀងផ្ទងមើល ហើយក៏ឈាន់មាត់សរសើរថា ៖

- ត្បូងអីក៏ដេញភ្លឺម្ល៉េះលោករុំ?
- ពេជ្រទាំងគ្រាប់ណាំ
- ថ្លៃប៉ុន្មានដែរលោករុំ?
- តែជាងប្រាំពាន់ទេ ។ អាហ្នឹងគេហៅថាចិញ្ចៀនវ៉ែន សំរាប់ស្ត្រីមានប្តី ។ តើឯងស្រឡាញ់ ហើយចង់បានឬទេសូភាព?
- ចាំះ ស្រឡាញ់ដែរ តែថ្លៃណាស់លោករុំ ។ ខ្ញុំស្តាយលុយណាស់ ណាមួយខ្ញុំមិនស្គាល់ពេជ្រផង ខ្លាចទិញទៅខុសចាញ់បោកគេ
- បើឯងមិនស្គាល់ពេជ្រ អញជាអ្នកស្គាល់ ។ អញក៏ចេះជួយមើលឯងដែរ ។ ឬមួយក៏ឯងមិនទុកចិត្តអញ? ។
- ចាំះ មិនមែនទេលោករុំ តែខ្ញុំចង់ទុកលុយបង្ការទុកពេលអត់ការធ្វើវិញ ដូចលោករុំធ្លាប់មានប្រសាសន៍ដាស់តឿនខ្ញុំពីមុននោះ ។
- ទិញទៅកាភាព ចិញ្ចៀននេះទឹកល្អណាស់ ។ បើឯងទិញ គេក៏មិនយកលុយភ្លាមៗដែរ អាចកាត់ខែបាន ព្រោះគេស្គាល់អញច្បាស់

លោកស្រីផានីបញ្ចុះបញ្ចូលសូភាពលុះត្រាតែនាងដាច់ចិត្តទិញចិញ្ចៀននោះ ។ នាងនឹកស្តាយប្រាក់ខ្លាំងណាស់ ។ ប៉ុន្តែដោយនាងខ្លាចលោករុំនាងនឹងធ្វើអោយនាងខានបានជួបជំនោរនោះ នាងក៏ចេះតែព្រមតាមទៅ ។

ទៀតពេលថ្មីៗនេះ នាងដូចជាដឹងខ្លួនឯងថា នាងចាប់ស្រឡាញ់គេតិចៗហើយ ។

បើយើងក្រឡេកមើលទៅខាងកម្លោះជំនោរឯណោះវិញ គេដឹងថាកម្លោះយើងក៏សប្បាយចិត្តណាស់ដែរដែលលោកសុភក្ត្រជាឪពុកមាបានយល់ពីទំហំស្នេហ៍របស់គេចំពោះសូភាពយ៉ាងច្បាស់ ហើយបានជួយជ្រោមជ្រែងគេដោយខ្នះខ្នែងជាទីបំផុត ។ រីឯលោកសុភក្ត្រ ក៏លោកចង់អោយជីវិតកំព្រាគ្រប់គ្រមោចរបស់ក្មួយប្រុសលោកមានការកក់ក្ដៅ មានខ្លឹមសារដូចរស់នឹងគេឡើង ។

ខ្ញុំភ្លេចជំរាបលោកអ្នកអានថា ជំនោរក៏ជាកម្មកររោងចក្រដេរសំលៀកបំពាក់ជាមួយសូភាពដែរ ។ យុវជននេះធ្វើការនៅក្នុងឃ្លាំងឥវ៉ាន់របស់រោងចក្រ ។ ដូច្នេះ សូភាពពុំដែលបានឃើញគេសោះឡើយ ។ ប៉ុន្តែជំនោរគេស្គាល់សូភាពច្បាស់ណាស់ ព្រោះគេធ្លាប់លបលួចមើលសូភាពជារៀងរាល់ថ្ងៃ ។ អ្នកកម្លោះមានការចាប់អារម្មណ៍ ហើយក៏តាមស៊ើបសួរដឹងរស់ពីឫសគល់របស់សូភាព ។ ទីបំផុត គេក៏ដឹងថាសូភាពជាមនុស្សម្នាក់នៅក្នុងគ្រួសារលោកស៊ីផលដែលជាមិត្តម្នាក់របស់ឪពុកមាគេ ។

ថ្ងៃនេះ លោកសុភក្ត្រទៅផ្ទះលោកស្រីផានីម្ដងទៀត ដើម្បីសុំដណ្ដឹងរៀបការ ។ ជំនោរនៅរង់ចាំទាំងអន្ទះសារ ។ យុវជនយើងមានអាកប្បកិរិយាឆ្លេឆ្លារសាប់រសល់ នៅមិនសុខមិនសាប់ ។ អ្នកនៅឈរជាប់នឹងមាត់បង្អួច ទន្ទឹងមើលផ្លូវឪពុកមាយ៉ាងប្រាស់ប្រាលជាពន់ពេក ។

មួយស្របក់ក្រោយមក ទើបជំនោរឃើញឪពុកមាគេត្រឡប់មកផ្ទះវិញទាំងទឹកមុខខ្មៅរែ ។ មាណពស្ទុះទៅជិតព្រមទាំងសាកសួរទាំងបារម្ភថា ៖

- មាមិនស្រួលខ្លួនឬ?

ឥតចម្លើយ ។ គេឃើញលោកមារបស់គេអង្គុយជ្រប់មុខយកដៃទាំងពីរ

ក្តោបភក្ត្រយ៉ាងស្ងាត់ស្ងៀម ។ អ្នកកម្លោះក៏សួរទាំងជ្រួលច្របល់ខ្វល់ក្នុងចិត្តថា ៖

- រឿងសុំដណ្តឹងសុភាពរៀបការនោះយ៉ាងណាហើយម៉ា?

លោកសុភក្ត្រតានតឹងក្នុងចិត្តរឹតតែខ្លាំងឡើងៗ ។ លោកពិបាកនឹងហាមាត់និយាយរឿងពិតនេះប្រាប់កូនកំព្រារបស់លោកណាស់ ។ ភាពច្រាស់ច្រាលអន្ទះសាររបស់ជំនោរនាំអោយលោករឹតតែតឹងទ្រូងថែមទៀត ។ ជំនោរចាប់អង្រួនឪពុកមាដោយចោទសួរបញ្ជាក់ថា ៖

- ម៉ា! តើលោកស្រីផានីយល់ព្រមអោយខ្ញុំរៀបការក្នុងរយៈពេលមួយខែទៀតឬទេ?

លោកសុភក្ត្រក៏ខំជម្រុះវាចាមួយៗថា ៖

- កុំប្រញាប់ពេកជំនោរកូន! សុភាពវាឈឺណាំ ។

- សុភាពឈឺអី? ។ ទេ! ខ្ញុំមិនជឿទេ ។ ខ្ញុំឃើញនាងទៅធ្វើការរាល់ថ្ងៃ ។ នាងមានឈឺអីម៉ា ។

- វាទើបតែនឹងឈឺទេ

- ឈឺអីម៉ា?

សួររួចភ្លាម គេក៏ស្ទុះចូលទៅក្នុងបន្ទប់ភ្លែត ។ លុះស្លៀកពាក់ស្រួលបួលហើយ គេក៏ចេញទៅរកសុភាពមួយរំពេច ។

ហាក់បីដូចជាណាត់ជួបគ្នាដូច្នោះឯង ។ យុវជនប្រទះឃើញស្រីស្នេហ៍នៅអង្គុយលំហែកាយលើកៅអីវែងមួយក្នុងទីសួនសាធារណៈដែលនៅជាប់ក្បែរនឹងជើងរបងផ្ទះលោកអ៊ុំធម៌របស់នាង ។ គេដើរលបៗពីក្រោយខ្នងស្រី ។ នាយឈរស្ងៀមពីខាងក្រោយប្រហែលពីរនាទី ក៏សុភាពនៅតែមិនដឹងខ្លួន ត្បិតនាងកំពុងបណ្តែតអារម្មណ៍រវើរវាយទៅទីឆ្ងាយ ។ ជំនោរលាហត្ថាទាំងគូបម្រុងផ្ទប់ភ្នែកកល្យាណី ។ ប៉ុន្តែមានវត្ថុអ្វីមួយមកទប់ចិត្តគេមិន

អោយធ្វើដូច្នោះវិញ ខ្លាចក្រែងសូភាពមិនពេញចិត្ត ។ ប្រុសកម្លោះបានត្រឹមតែដាក់ហត្ថាទាំងទ្វេទ្រាបលើខ្នងកៅអីវែងជិតសូភាព ហើយហៅឈ្មោះស្រីសម្លាញ់តិចៗថា ៖

- ភាព! អូនភាព!

សូភាពភ្ញាក់ក្រញាងដោយភិតភ័យ ។ ស្រីស្ទុះក្រោកពីកៅអី ងាកផាំងមករកម្ចាស់សំនៀង ។ ស្រីកំសត់បម្រុងហាមាត់សួរទៅជំនោរ តែត្រូវកម្លោះសួរកាត់មុនថា ៖

- ខ្ញុំឮថាភាពឈឺ តើភាពឈឺអី? ឈឺមែនឬភាព?

សំណួរនេះបានក្លាយជារន្ទះបាញ់ខ្ទប់ដួងចិត្តនាងសូភាពអោយបែកហែកខ្ទេចខ្ទីជាច្រើនចំរៀក ។ ពាក្យថា "ឈឺ" មួយម៉ាត់នេះក្លាយជាអាវុធមុតស្រួចមកចាក់ ភ្លើះ ឆ្លៀល បេះដូង ស្រី អោយ ចុក ចាប់ អួល ផ្សា ពន់ ពេកកន្លង ។ សូភាពមិនបានតបទៅជំនោរទេ ព្រោះនាង ... ព្រោះនាងនឹកទៅដល់វាចាលោកវរុំស្រីនាង ដែលមានប្រសាសន៍ជំរាបលោកសុភក្ត្រ ឪពុកមារបស់ជំនោរហាំងៗ ដែលកាលណោះនាងបានលបស្ដាប់ឮទាំងអស់គ្មានចន្លោះមួយម៉ាត់ណាឡើយអំពីជម្ងឺរបស់នាង ។ ក្រោយពីបានគិតហ្មត់ចត់ហើយ សូភាពក៏ដាច់ចិត្តពោលទាំងគំរោះគំរើយទៅកាន់ជំនោរថា ៖

- សូមពូជំនោរឈប់នឹកនាមករកខ្ញុំទៀតទៅ ។ ខ្ញុំអត់ស្រឡាញ់ពូបន្តិចណាទេ

- បងមិនជឿសំដីភាពទេ ។ បើភាពមិនស្រឡាញ់បង ភាពមុខជាប្រកែកយ៉ាងដាច់អហង្ការទៅ ហើយនៅពេលដែលឪពុកមា បងចូលទៅស្ដីដណ្ដឹងនោះ? ។

- កុំយកពាក្យ "យល់ព្រម" របស់ខ្ញុំមកធ្វើជាលេសអី ។ សូមពូជឿថា ខ្ញុំអាចត្រូវគេបង្ខំក៏បានដែរ (សូភាពនៅតែហៅជំនោរថា "ពូ" ដដែល) ។

- គ្មាននរណាបង្ខំភាពទេ ។ បងជឿច្បាស់ណាស់ ថាភាពមិនស្អប់បង

ឡើយ ។

- ចាំះ ខ្ញុំមិនស្អប់ពូមែន តែក៏មិនបានសេចក្តីថា ខ្ញុំស្រឡាញ់ពូទេ ។

- បងដឹងថា ទោះបីភាពមិនហ៊ានពោលពាក្យថាស្រឡាញ់ក៏ដោយ ។ ហើយទោះបីជាភាពមិនស្រឡាញ់បង ឬក៏ភាពត្រូវគេបង្ខិតបង្ខំអោយព្រមស្រឡាញ់បងក្តី ក៏រូបបងនៅតែស្រឡាញ់ភាព ស្រឡាញ់ដោយស្មោះអស់ពីបេះដូង ហើយថែមទាំងអាណិតយ៉ាងក្រៃលែងទៀតផង ។ បើទោះជាភាពឈឺមែន ឈឺស្តីក៏ដោយ ក៏បងស៊ូតែស្រឡាញ់ភាពដោយសូមថ្នាក់ថ្នមព្យាបាលភាពអោយអស់អំពីដួងចិត្តដោយមិនគ្លួញគ្លែរ និងឥតធុញទ្រាន់ជាដាច់ខាតណាំ

- ទេ! ទេ!

សូភាពស្រែកភ្លាត់សម្លេង រួចយកបាតដៃទាំងពីរមកខ្ទប់ត្រចៀក ។ ទឹកភ្នែកក៏ដណ្តើមគ្នាហូរខ្ចាយចេញពីកែវភ្នែកដ៏មានទុក្ខធំនេះ ហើយសូភាពក៏ខំនិយាយទាំងរួលរាក់ថា ៖

- ឈប់មករកខ្ញុំទៀតទៅ ឥតប្រយោជន៍ទេ

- ដរាបណាភាពនៅតែមិនព្រមបញ្ជាក់ប្រាប់បងពីហេតុផលច្បាស់លាស់ទេនោះ បងនៅតែតស៊ូមកជួបភាពជានិច្ច ។

- ខ្ញុំមិនចេះនិយាយពាក្យលេបខាយពីរោះដូចពូទេ

- បងអត់ចង់ស្តាប់ពាក្យលេបខាយអ្វីទាំងអស់ ក្រៅតែពីបងចង់ដឹងច្បាស់ពីចិត្តភាព ចិត្តភាពពិត សំដីភាពដែលហូរចេញពីដួងចិត្តខ្លួនឯងដោយមិនបង់ឮពាក្យលោកអ៊ុំខ្ញុំថាអីចេះ អ្នកនោះថាអីចុះជំនួសពាក្យពិតនៃសន្តានចិត្តរបស់ភាពខ្លួនឯងទេណាំ

- ពូឯងអាងមានវោហាយកមកល្បួងលោមចិត្តខ្ញុំអោយនឹកគិតមកពូអីចឹងឬ?

- ណាំកឃើញទេ ភាពនឹកបងដែរតើ ភាពអត់ស្អប់បងឯណា

- តែខ្ញុំរាត់ស្រឡាញ់ពូទេ ។ សូមកុំមករកខ្ញុំទៀត ។ យើងគ្មាននិស្ស័យនឹងគ្នាទេពូ ។ សូមពូកុំយករនាគតដ៏ល្អរបស់ពូមកបំផ្លាញដោយសាររូបខ្ញុំអោយសោះ ។

វាចាដ៏ចម្លែកនេះញាំងអោយជំនោរឆ្ងល់យ៉ាងខ្លាំង ។ គេស្ទុះភ្លែតមកឈរចំពីមុខសូភាព ហើយបញ្ចេញសូរសៀងដូចតទៅ៖

- ថ្ងៃនេះ ភាពមានវាចាប្លែកណាស់ ។ ភាពចេះនិយាយច្រើនហួរហែជាងសព្វមួយដង ។ ចុះហេតុអ្វីក៏ភាពមិនព្រមនិយាយពាក្យអ្វីមួយដែលអាចអោយខ្ញុំមានក្តីសង្ឃឹមខ្លះផងណា៎ភាព ។ គួរភាពយល់ដល់ចិត្តបងផង ។

- ព្រោះតែខ្ញុំយល់! ព្រោះតែរាណិតនោះហើយបានជាខ្ញុំលះបង់ ។ ខ្ញុំមិនចង់អោយពូរងទុក្ខសោកដោយសាររូបខ្ញុំឡើយ ។ កុំមករកខ្ញុំទៀតអី ឈប់មកអោយខ្ញុំឃើញមុខពូទៀត ឈប់ស្រឡាញ់ខ្ញុំទៅពូទេ!

គ្រាន់តែនិយាយចប់ភ្លាម នាងក៏រត់ចេញឡើងទៅលើផ្ទះវិញបាត់ទៅ ។ ជំនោរមិនហ៊ានឡើងទៅតាមទេ ។ អ្នកកម្លោះសុខចិត្តនាំរូបកាយអ្នកចូលមកលំនៅដ្ឋានរបស់អ្នកវិញទាំងក្រៀមក្រំ ។ លោកសុភក្ត្រយល់ស្ថានភាពបែបនេះ ក៏ចូលទៅលួងលោមក្មួយដោយក្តីករុណាថា៖

- ជំនោរក្មួយ! ចូរខំទប់ស្មារតី កុំបណ្តោយអោយមនោសញ្ចេតនាជិះជាន់បាន ។ ក្មួយត្រូវតែចេះខំរាត់ធ្មត់ខ្លះសិនទៅ ។ សូភាពឈឺ ចាំកាលណានាងជាវិញស្រួលបួល សឹមគិតគូរតទៅទៀត ។ ឯងការប្រពន្ធដែលមានជម្ងឺរ៉ាំរ៉ៃស្មានតែមានសុភមង្គលឬ? ។

- មាចេះតែថា ភាពឈឺ ។ ភាពមានឈឺអីនាង ។ ខ្ញុំទើបនឹងបានជួបនាងរាំបាញ់មិញទេតើ

- នាងឈឺពិតមែនណា៎ជំនោរក្មួយ

- ខ្ញុំមិនជឿទេ ។ លោកស្រីជានីច្បាស់ជាមានឧបាយកលអ្វីមួយជាមិនខាន

- និយាយអញ្ចឹងខុសហើយជំនោរ ។ លោកស្រីផានីចង់អោយតែសូភាព មានប្ដីនិងចេញពីបន្ទុកគេណាំ ។
- ប៉ុន្ដែសូភាពមិនមែនដេកស៊ីក្នុងបន្ទុកលោកស្រីផានីឯណា ។ នាងមានការធ្វើ មានប្រាក់ខែស្ពានតែនាងរស់នៅជាមួយគេដោយឥតចេញមួយសេនប្រលោកមា?
- ត្រូវហើយ គេមិនមែនចង់ទុកសូភាពធ្វើអ្វីដែរ
- នេះជាការស្ពានរបស់មាទេ ។ ការស្ពានមិនមែនសុទ្ធតែត្រូវទាំងអស់ទេ លោកមា

និយាយបានត្រឹមណោះ គេក៏បិទភ្នែកសម្ងំនិន្ទ្រាទាំងចង្អៀតចង្អល់ខ្វាយខ្វល់ពេញក្នុងដួងចិត្ត ។

ចំណែកឯនាងសូភាពវិញ ក៏រឹតតែវេទនាក្នុងចិត្តជាងជំនោរទៅទៀត ។ ស្រីកំសត់គេងសម្រក់ទឹកភ្នែកជោកខ្នើយអស់ ។ នាងតូចចិត្តនឹងវាសនាអាក្រក់របស់នាងណាស់ ។ កើតមកមានមាតាបិតាដូចអស់នឹងគេដែរ តែបែរជាព្រាត់ប្រាសអស់រលីង ។ នាងឈឺ! គេថានាងឈឺ! ជម្ងឺនាងនឹងនាំអោយពិបាកដល់គេ ។ បើនាងត្រដររស់នៅក្នុងផ្ទះនេះ នោះថ្ងៃណាមួយនាងនឹងស្លាប់លើផ្ទះគេ នាំអោយចង្រៃគេហង្ខាន់គេមិនខាន ។ ណាមួយ នាងដឹងថាជំនោរស្រឡាញ់នាងខ្លាំងណាស់ ។ គេច្បាស់ជាមករកនាង ។ ប៉ុន្ដែធ្វើម៉េចបើនាងមិនអាចរៀបការជាមួយគេបានជាមួយគេបាន ។ គិតសព្វគិតគ្រប់ទៅ តរុណីបានប្ដេជ្ញាចិត្តបន្សាត់ខ្លួនអោយឆ្ងាយពី Houlepierre ។

+

+ +

## - ៤ -

នៅក្នុងសួនសាធារណៈមួយតាមដងទន្លេ Rhin ក្បែរព្រំប្រទល់ប្រទេស អាល្លឺម៉ាញនោះ គេឃើញសូភាពអង្គុយលើកៅអីអង្រៀមនំប៉័ងសាច់ដែល នាងចាត់ថាជាអាហារថ្ងៃត្រង់ ។ ស្រីកំសត់អង្គុយសម្លឹងដងទន្លេដ៏ធំល្វឹងល្វើយ ធ្វើអោយស្រីនឹកឃើញដល់ទន្លេចតុមុខ ។ ឃើញស្ពានឆ្លងទៅ KEHL នាង នឹកឃើញដល់ស្ពានជ្រោយចង្វារដែលមានរាងស្រដៀងគ្នា ។

កំពុងតែអង្គុយគិតពីខ្សែជីវិតផ្សងព្រេង ស្រាប់តែមានស្ត្រីម្នាក់មកអង្គុយ ជិតនាង ។ សូភាពមិនបានអើពើជាមួយគេទេ តែនារីនោះសើចដាក់សូភាព ហើយថ្លែងវាចាសួរត្រង់ៗជាភាសាបារាំងដែលមានសេចក្ដីថា៖

- អ្នកជាជនជាតិណាដែរ?
- ខ្ញុំជាខ្មែរ
- ចំណែកខ្ញុំជា ជនជាតិអ៊ីតាលី ។ តើអ្នកមកនៅស្រុកបារាំងយូរហើយឬ? អ្នកមកជុំជាមួយគ្រួសារអ្នកឬ?
- ទេ! ខ្ញុំនៅស្រុកបារាំងតែម្នាក់ឯងគត់ ។ ខ្ញុំរត់ផ្ទះនៅទេ
- មិនពិតទេ ។ ខ្ញុំឮថា ជនភៀសខ្លួនឥណ្ឌូចិនសុទ្ធតែត្រូវរដ្ឋាភិបាលបារាំង

ជួយផ្គត់ផ្គង់ ហើយទទួលអោយសំណាក់នៅក្នុង foyer មួយរយៈកាលទំរាំមានការងារអាចរកជួលផ្ទះនៅបាន

- ចាំះ ពិតណាស់ ប៉ុន្តែខ្ញុំនៅហួសកំណត់ហើយ គេលែងអោយខ្ញុំនៅទៀត ។ ខ្ញុំរកជួលផ្ទះមិនទាន់បាន ខ្ញុំមិនហ៊ានត្រឡប់ទៅវិញទេ ។ ខ្ញុំសុខចិត្តនៅគេងទីនេះហើយ

- មិនបានទេ នៅដេកទីនេះត្រជាក់ណាស់ រងាស្លាប់ហើយៗ ប៉ូលីសមិនបណ្តោយអោយអ្នកមកដេកកន្លែងសាធារណៈអញ្ចឹងទេ ។ គួរតែត្រឡប់ទៅ Foyer សិនទៅ

- ទេ! ខ្ញុំសុខចិត្តនៅទីនេះចុះ ឬក៏ធ្វើដំណើរទៅមុខទៀត

- ទៅណា?

- ខ្ញុំគ្មានគោលដៅទេអ្នក

- បើដូច្នេះ មកនៅជាមួយខ្ញុំទៅ យល់ព្រមទេ?

ស្រីសាសន៍អ៊ីតាលីចាប់ក្តោបបាតដៃសូភាពមកក្តាប់យ៉ាងណែន នាំអោយមានចំហាយក្តៅឧណ្ហៗញ្ញាំងអោយសូភាពបានកក់ក្តៅចិត្តយ៉ាងក្រៃលែង ។ បើកុំតែបានជួបនារីបរទេសនេះ សូភាពច្បាស់ជាលោតទឹកបាត់ទៅហើយ ។ សូភាពក៏យល់ព្រមតាមការស្នើរបស់ស្រីអ៊ីតាលីយែន ។ នារីទាំងពីរក៏បណ្តើរគ្នាត្រសងចេញពីសួនច្បារឆ្ពោះទៅកាន់លំនៅដ្ឋាន ។

គឺជាបន្ទប់ក៏តូចមួយជាប់នឹងដំបូលផ្ទះដែលមានតែគ្រែដំណេកមួយ តុសរសេរមួយ ទូមួយ និងកូនចង្ក្រានតូចមួយប៉ុណ្ណោះ ។

នារីបរទេសបើកបង្អួចយកដបទឹកក្រូចពីក្រៅ រួចនិយាយទៅកាន់ភ្ញៀវថ្មីថា៖

- ផ្ទះខ្ញុំគ្មានទូទឹកកកទេ ។ ក្នុងរដូវត្រជាក់ ខ្ញុំដាក់ឥវ៉ាន់នៅកន្លែងធ្វើហាត់បង្អួចនេះ ។

- ចុះរដូវក្ដៅ?
- ខ្ញុំទិញម្ហូបរាល់ថ្ងៃ

សូភាពនៅឈរទ្រឹងទាំងរំខានក្នុងចិត្តពន់ពេកក្រៃ ។ អារម្មណ៍មិនមូលក្នុងខ្លួនសោះ ។ នាងសញ្ជឹងគិតថា បន្ទប់តូចមួយដូច្នេះ ចុះបើគេមានប្ដីរបស់គេ តើនាងត្រូវទៅទទួលទានដំណេកកន្លែងណាវិញទៅ? ។ កាលបើនឹកឃើញដូច្នេះ ស្រីរិតតែមានការទើសទាល់យ៉ាងខ្លាំង ទើបដាច់ចិត្តនិយាយទៅនារីបរទេសថា៖

- អ្នកយកខ្ញុំមកនៅជាមួយដូច្នេះ បើប្ដីអ្នកត្រឡប់ចូលផ្ទះវិញ គាត់ច្បាស់ជាមិនសប្បាយចិត្តទេ
- ខ្ញុំគ្មានប្ដីទេ ។ ខ្ញុំនៅម្នាក់ឯងគត់ដូចអ្នកឯងអញ្ចឹង ។ យើងទុកគ្នាជាមិត្តណាំ ហើយយើងកុំហៅគ្នាថានាង-អ្នកអី ។ ខ្ញុំចូលចិត្តហៅ "ឯង-អា" វិញ ទើបជិតស្និទ្ធជាង ព្រមទេ?

សូភាពស្ដាប់ច្បាំងកាត់យល់បានល្មមដែរ ក៏ខំញញឹមតបបំពេញបំណងចិត្តមិត្តស្រីថ្មោងថ្មីជំនួសពាក្យឆ្លើយ ។

ស្រីបរទេសនិយាយថា៖

- ខ្ញុំឈ្មោះល្វីស្យាណា (Louisiana) ។ ចុះឯងឈ្មោះអីដែរ?
- ខ្ញុំឬ? ខ្ញុំឈ្មោះ .... សូ .... ហៅខ្ញុំថា សូបានហើយ
- ល្អណាស់! សូឯងនិងខ្ញុំល្វីស្យាណា យើងទាំងពីរជាមិត្តនឹងគ្នាណាំចាប់ពីថ្ងៃនេះតទៅ ។

ល្វីស្យាណា ចាប់ហត្ថសូភាព (ហៅសូ) មករលាក់ពីរបីដង ដោយសប្បាយរីករាយ រួចនិយាយថា៖

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- យើងលែងនៅម្នាក់ឯងទៀតហើយ ។ តើឯងសប្បាយចិត្តទេ? ។ ចូរឯងទុកផ្ទះនេះជាផ្ទះរបស់ឯងទៅ កុំខ្លាចក្រែងចិត្តខ្ញុំអី d'accord

- ចា៎ះ យល់ព្រម ។ ខ្ញុំអរគុណឯងណាស់ ស្សាណា

លីស្សាណាខំយកចិត្តទុកដាក់នឹងមិត្តនារីថ្មីរបស់គេណាស់ ។ កាយវិការនេះគួរតែធ្វើអោយនាងសូភាពត្រេកអរជាពន្លឹក ។ ប៉ុន្តែដោយសារតែការលួចរត់ចេញពីផ្ទះលោកស្រីផានីបានចោទជាចំណោទគួរអោយភ័យខ្លាចគ្រប់បែបយ៉ាង ទើបបណ្តាលអោយដួងចិត្តស្រីអភ័ព្វខ្វាយខ្វល់តានតឹងស្ទើរតែប្រេះបែកអស់ ។ ការកើតទុក្ខហួសប្រមាណ ការអរត់សង្កត់ចិត្តដើម្បីលាក់រឿងសម្ងាត់នេះញាំងអោយតរុណីភ្លេចភ្លឹកខ្លួនម្តងៗ ។ លីស្សាណាសំគាល់ឃើញអាកប្បកិរិយាមិនធម្មតារបស់សូភាពម្តងៗ ក៏ចេះតែខំដេញដោលសួរ ជួនក៏និយាយបែបកំប្លែងលេងថា៖

- អេ! ហ្វូៗ ឯងកំពុងស្រមៃយល់សប្តិទៅឋានណាហ្នឹង សូ?

សូភាពខំសើចបន្លប់ ។ លីស្សាណារៀបរយគ្រែបណ្តើរ និយាយបណ្តើរថា៖

- ខ្ញុំទៅគេងលើកម្រាលខាងក្រោម ទុកអោយសូឯងគេងលើគ្រែចុះ

- ទេ! ស្សាណាឯងជាម្ចាស់ផ្ទះ ត្រូវតែគេងលើគ្រែទើបត្រូវ

- នែ៎ គ្នាហាមមិនអោយនិយាយថា ម្ចាស់ផ្ទះ មិនមែនម្ចាស់ផ្ទះអីហ្នឹងទៀតទេ ។ ផ្ទះនេះជាផ្ទះរបស់យើងទាំងពីរនាក់ហើយ ក្រែងឯងយល់ព្រមធ្វើជាពួកម៉ាកគ្នាហើយឬ?

- ត្រូវហើយ តែខ្ញុំមិនចង់អោយឯងផ្លាស់ប្តូរទីដំណេកដែលធ្លាប់ស្រួលនោះទេ

- ឯងនេះចំជាក្បាលរឹងមែន!

ថារួច ក៏លើកដៃមកទះក្បាលសូភាពថ្មើៗដោយការហួសចិត្ត ។ សូភាព ទំគេគេចចេញយ៉ាងរហ័ស ត្បិតនាងជាខ្មែរមានទម្លាប់ប្រកាន់ក្បាលមិនដែល អោយនរណាប៉ះពាល់លេងតាមចិត្តចង់នោះឡើយ ។

តាំងពីមកនៅទីនេះ សូភាពនៅតែសម្ងំក្នុងផ្ទះឥតហ៊ានចេញទៅណាមក ណាទេ ដោយខ្លាចគេតាមដានរកនាងឃើញ ។ ការសំកុកនៅក្នុងផ្ទះគេ ដោយឥតប្រកបការងារអ្វីសោះនោះញ៉ាំងអោយនាងគប់ប្រមល់ទល់ ពុទ្ធោ ។ ណាមួយខ្លាចចិត្តម្ចាស់ផ្ទះដែលចេញទៅធ្វើការ ហាក់បីដូចជាខ្លួន មករស់នៅវិខានគេអោយពិបាកនឹងចិញ្ចឹមខ្លួន ។

រីឯលីស្សាណាវិញ នាងមិនដែលគិតឃើញអ្វីដូច្នេះឡើយ ។ ផ្ទុយទៅ វិញ នាងមានចិត្តសប្បាយរីករាយយ៉ាងប្លែក ដោយសារតែនាងរកបានគ្នា គ្រាន់នៅជាមួយ ។ នៅពេលត្រឡប់មកពីធ្វើការវិញម្តងៗ នាងដឹងថាមាន មនុស្សម្នាក់នៅរង់ចាំនាង ធ្វើអោយនាងមានសេចក្តីសុខក្នុងចិត្ត មិនកំសត់ ឯកាដូចពីគ្រាមុនទៀត ។

- មកដល់ផ្ទះវិញបានធូរចិត្តតែម្តង ។ ça va ? ម្តេចក៏សូមិនសូវនិយាយ ស្តី ហើយនៅផ្ងឹងៗអញ្ចឹង? ។ គ្នាប្រាប់ហើយថាកុំទើសទាល់អី .... ចាំគ្នា ទៅធ្វើបាយញ៉ាំ ។ យប់នេះគ្នាធ្វើ spaghetti តើសូឯងចូលចិត្តញ៉ាំទេ?

- ចា៎ះ ចូលចិត្តណាស់

- សូ! គ្នាស្គាល់កន្លែងលក់ឥវ៉ាន់អាស៊ីជាច្រើននៅប៉ារីស ។ ចាំថ្ងៃណាមួយ គ្នានាំឯងទៅទីនោះទិញឥវ៉ាន់មកធ្វើម្ហូបខ្មែរញ៉ាំម្តង

- អញ្ចឹងឬ?

- ឯងត្រូវតែបង្រៀនគ្នាអោយចេះធ្វើម្ហូបខ្មែរណា៎ អូខេ!

- អូហ៍កុំភ័យ ចាំខ្ញុំបង្រៀន តែខ្ញុំមិនជាអ្នកចំណាប់ខាងការធ្វើម្ហូបប៉ុន្មាន ទេ ។

ថាហើយ គេក៏សើចក្អាកក្អាយព្រមគ្នាឡើង ។

.....................................................................................................................................

លីសុវណ្ណាណានាំសូភាពទៅចុះឈ្មោះសុំការធ្វើនៅទីភ្នាក់ងារជាតិខាងការងារ (Agence nationale pour l'emploi) ហើយក៏ប្រទះឃើញការមួយ ។ គឺជាកិច្ចការបំរើគេក្នុងផ្ទះ ។

លីសុវណ្ណាក៏បានជូនសូភាពទៅដល់ផ្ទះគេ ។ នាងនៅឈរចាំខាងក្រោមផ្ទះដោយទុកអោយសូភាពឡើងទៅតែម្នាក់ឯង ។

បុរសម្ចាស់ផ្ទះជាជនជាតិបារាំងមានអាយុប្រហែលជាពាក់កណ្ដាលមនុស្ស ។ គេមានទឹកមុខគ្រៀមស្ងួតស្រៀបដូចជាមនុស្សដែលមានទុក្ខកង្វល់ញាំញីជាច្រើនខែមកហើយ ។ គេហៅសូភាពអោយអង្គុយស្រួលបួលហើយ ទើបចេញវាចាសួរនាងថា៖

- តើអ្នកធ្លាប់ប្រកបរបរជាអ្នកបោសជូតនេះដោយយកកំរៃមួយម៉ោងប៉ុន្មាន?
- ខ្ញុំពុំធ្លាប់ធ្វើការនេះនៅស្រុកបារាំងដោយយកកំរៃឈ្នួលទេ
- តើអ្នកយល់ថាអ្នកអាចមកនៅធ្វើការអោយខ្ញុំបានឬទេ?
- ចាស៎ ខ្ញុំជឿថា ខ្ញុំអាចធ្វើបាន ព្រោះការផ្ទះជាការរបស់ស្ត្រីដែលស្ត្រីទូទៅតែងតែចេះធ្វើជាធម្មតា

ឮសូភាពឆ្លើយដូច្នោះ បុរសបារាំងនេះសម្លឹងមុខនាងយ៉ាងពិនិត្យពិច័យ ។ គេនៅស្ងៀមមួយរយៈ ទើបបន្តវាចាទៀតថា៖

- ខ្ញុំជាមនុស្សម្នាក់ដែលមានជម្ងឺម្យ៉ាង ។ ខ្ញុំចង់បានស្រីម្នាក់ដែលមានសម្រស់ដូចអ្នកមកនៅធ្វើការក្នុងផ្ទះខ្ញុំ នៅជិតខ្ញុំ ក្រែងលោអាចជួយកែជម្ងឺផ្លូវចិត្ត

របស់ខ្ញុំបានខ្លះ ។ ខ្ញុំចង់ដឹងច្បាស់ ថាតើអ្នកគិតយកកំរៃពីខ្ញុំប៉ុន្មានក្នុងមួយម៉ោង?

ថាហើយ គេហជននោះក៏ដើរចេញទៅកាន់បន្ទប់មួយនៅក្បែរនោះ ។ សូភាពលួចសង្កេតមើលតាមពីក្រោយ ឃើញដំណើរគេរាងឃ្លោងបន្តិច ។ ដោយនាងមានបញ្ហាភាសាច្រាំងនោះ វាចាដែលជននេះពោលមកកាន់នាងវិញ្ញាញ់មិញ្ញពុំអាចអោយនាងយល់អស់បានទេ ។ នៅពេលដែលរង់ចាំនោះ សូភាពខំរំឭកប្រយោគវាចារបស់ជនបរទេសមកគិតសាជាថ្មី ក៏គ្រាន់តែដឹងថាគេសួរនាងពីតម្លៃឈ្នួលដែលនាងចង់បាន ។ កំពុងតែឈ្ងោកមុខគិតពិចារណាម្នាក់ឯង ក៏ស្រាប់តែបុរសម្ចាស់ផ្ទះមកឈរនៅចំពីមុខនាង រួចទម្លាក់ក្រដាសប្រាក់មួយរយហ្វ្រង់មកលើកូនតុតូចចំនួនប្រាំប្រាំមួយសន្លឹក ។

សូភាពភ្ញាក់ព្រើត ហើយក៏ងឿងឆ្ងល់ផង ។ នាងក៏ងើបឈរឡើងចោលភ្នែកសម្លឹងទៅម្ចាស់ប្រាក់ ។ នាងឃើញមុខគេក្រហមងាំង ។ គ្រាប់ភ្នែកក៏ក្រហម ហាក់បញ្ចេញពីមនោសញ្ចេតនាអ្វីមួយញ៉ាំងអោយសូភាពស្លុតរន្ធត់ភិតភ័យញ័រមាត់ញ័រក ។ នាងស្ទុះរឹងសំដៅទៅមាត់ទ្វារចេញ ។ ប៉ុន្តែត្រូវបុរសនោះស្ទុះទៅជាមួយ ហើយលឿនជាងនាង ទៅដល់ទ្វារ រួចលូកដៃបម្រុងចាក់សោផ្ទះ ។ សូភាពយល់ការណ៍មិនស្រួល ហើយក៏ដូចជាមានព្រះតាមជួយនាងផង សូភាពក៏គះដៃជនសាមាន្យចេញ ហើយក៏បើកទ្វាររត់គេចខ្លួនចេញពីផ្ទះចង្រៃនោះភ្លាមទៅ ។

ចុះទៅដល់ក្រោមភ្លាម នាងចាប់ទាញដៃល្វីស្យាណាត្រណាត់ត្រណែងទាំងទ្រូងញ័ររន្ធត់ពុំទាន់បាត់នៅឡើយ ហើយក៏ចេញវាចាទាំងត្រហេបត្រហបថា៖

- មក! យើងនាំគ្នាចេញពីទីនេះភ្លាមទៅ នៅមិនបានទេ
- មានរឿងអ្វីឬ?

- គ្រោះថ្នាក់ ... នៅយូរមិនបាន ... ខ្ញុំខ្លាចណាស់ ។ អាតាប៉ិកបារាំងនេះ វាមិនមែនរកជួលមនុស្សអោយបំរើការផ្ទះវាទេ ...វាចង់ទិញរូបកាយខ្ញុំ ... ខ្ញុំ! ខ្ញុំពុំដែលប្រទះរឿងអញ្ចឹងទេស្យាណា ខ្ញុំភ័យណាស់ ....

ក្បិណនោះ គេហជនសាមានក៏ចុះមកតាម រួចចេញវាចាដូចមនុស្សឈឺថា៖

- ខ្ញុំសូមអង្វរណាំ ជួយខ្ញុំផង ជួយលើកទឹកចិត្តខ្ញុំផង ។ ក្នុងចំណោមអ្នកទាំងពីរ ខ្ញុំត្រូវការមនុស្សម្នាក់ អ្នកណាមួយក៏បានដែរអោយតែព្រមចុះ

ល្វីស្យាណាស្រែកសន្ធាប់ថា៖

- តើអ្នកឯងត្រូវការចង់បានស្អី?

- កុំអាលខឹងអី .. ស្ដាប់ខ្ញុំសិន ខ្ញុំចង់បានស្រីម្នាក់ជួយរៀបចំផ្ទះខ្ញុំ

សូភាពក៏ឆ្លើយតបទាំងគំហឹងថា៖

- បានហើយ! ខ្ញុំមិនត្រូវការចង់បានប្រាក់ថោកទាបរបៀបហ្នឹងទេ ថ្វីត្បិតតែខ្ញុំក្រហើយគ្មានការធ្វើមែន ។

- ខ្ញុំពិតជាត្រូវការអ្នកមែន!

- ទេ! ជាដាច់ខាត!

គិតទៅមនុស្សយើង បើថាមានទុក្ខមួយជាន់ហើយ ក៏ថែមមួយជាន់ទៀត សូភាពរឹតតែតប់ប្រមល់ខ្លាំងឡើងៗ ។ ល្វីស្យាណាឃើញសូភាពចេះតែស្រងូតស្រងាត់ទៅៗ នាងក៏ចេះតែខំរកមធ្យោបាយលួងលោមដោយពាក្យផ្អែមល្ហែម ប្រៀបដូចជាមាតាលួងបុត្រតូច ឬស្វាមីលោមភរិយានៅគ្រាមានទុក្ខភ័យដូច្នោះ ។ នាងខំទៅយកសៀវភៅបិទរូបថតផ្សេងៗមកបង្ហាញសូភាព ដោយចង្អុលប្រាប់ពីរូបថតមួយទៅរូបថតមួយអំពីក្រុមគ្រួសាររបស់នាងទាំងអស់ ។ ល្វីស្យាណានឹកស្មានថា ការមើលរូបថតអាចធ្វើអោយ

សូភាពសប្បាយភ្លេចរឿងចង្រៃថ្មីៗនេះបាន ។ ផ្ទុយទៅវិញ រឹតតែនាំអោយសូភាពស្រណោះស្រណោកខ្លួនខ្លាំងឡើងៗទៅវិញ ។ ចំណែកលីស្សាណាមិនបានជាចាប់អារម្មណ៍ដល់ការទង្គិចផ្លូវចិត្តនាងសូភាពទេ នាងចេះតែខំបើកសៀវភៅតទៅពីទំព័រមួយទៅទំព័រមួយអោយសូភាពមើល ។ លុះពុំឮសូភាពឆ្លើយឆ្លងនិយាយមកកាន់នាងវិញដូចសព្វដង ទើបនាងងាកមុខមើលទៅសូភាព ហើយស្រដីសួរថា៖

- ឯងយំ! ហេតុអ្វីក៏ឯងយំ? ។ តើនរណាធ្វើអោយឯងពិបាកចិត្តទៀត? ... យី! តើឯងនៅយករឿងរំបាញ់បិញមកគិតដល់ណាទៀត?

វាចានេះរឹតតែធ្វើអោយសូភាពក្តុកក្តួលឡើងៗ ។ ជលនេត្រក៏កាន់តែដណ្តើមគ្នារហៀលហូរចុះពីដួងនេត្រាមក ....

- សូ! គ្នាមិនចង់ឃើញឯងយំទេ ព្រោះធ្វើអោយគ្នាចង់យំតាមឯងណាស់ ។ សូ! ចូរឯងកុំភ្លេចថា គ្នាស្រឡាញ់និងអាណិតឯងណាស់ណាំ ។ ឯងជាមិត្តនារីតែមួយគត់សំរាប់ជីវិតរបស់គ្នា ។ គ្នានៅជិតឯងជានិច្ច នៅជួយរំលែកទុក្ខព្រួយនិងសប្បាយរួមគ្នា ... តើឯងយល់ចិត្តគ្នាឬនៅ?

ថាហើយ ស្រីអ៊ីតាលីយែនយកដៃអង្អែលខ្នងសូភាពថ្នមៗ ហើយថែថើបថ្ពាល់នាងយ៉ាងថ្នាក់ថ្នម រួចក៏ជម្រុះពាក្យពេចន៍យ៉ាងផ្អែមល្ហែមថា៖

- ឯងមិនកំព្រាដូចពីមុនទៀតទេ គឺមានគ្នានៅជិតឯងជានិច្ច ។ គេងទៅណាំ ថ្ងៃស្អែកជាថ្ងៃថ្មី ឯងនឹងបួរគំនិតស្មុគ្រស្មាញនេះចេញ អូខេ!

រួចហើយក៏ថើបនាងមួយខ្សឹតទៀត ដោយបញ្ជាក់ថា៖

- គ្នាស្រឡាញ់ឯង

- អរគុណ! ... អរគុណមួយពាន់ដង ។ ឯងល្អនឹងគ្នាណាស់ ... តែគ្នាដូចជានាំទុក្ខសោកមកអោយឯងខ្វល់ខ្វាយដោយ ... សាររូបគ្នា ... គ្រប់ជំពូក

ពេក ... ខ្ញុំចង់ចេញពីទីនេះទៅ ... ទៅអោយឆ្ងាយ ...

- ទៅណា? ... នៅជាមួយគ្នាទីនេះហើយ ។ បើឯងទៅណាចោលគ្នានោះ ជីវិតគ្នាលែងមានន័យទៀតហើយ ។ គ្នានឹងលោតសម្លាប់ខ្លួន ប្រសិនជាឯងទៅណាចោលគ្នានោះ ...

................................................................................................

- ទេ! លែងខ្ញុំ! លែងខ្ញុំ! ... ខ្ញុំមិនមែនឈ្មោះសូភាពទេ! ខ្ញុំឈ្មោះសូ ... "សូ" យ៉ាងខ្លីលែង! ថាលែង

សូភាពស្រែកយ៉ាងភ្លាត់សម្លេងនាកណ្ដាលអធ្រាត្រស្ងាត់ ព្រមទាំងបម្រះផង ធ្វើអោយលីស្សាណាភ្ញាក់ផ្អើលពីដំណេក ហើយក៏ដាស់សូភាពស្ទួរភ្លាម ។

សូភាព ភ្ញាក់ ចេញ ពី សុបិន និមិត្ត ចម្លែក ទាំង យំ អណ្ដឹត អណ្ដក នៅឡើយ ។ លីស្សាណា ជូត ទឹក ភ្នែក សម្លាញ់ ចិត្ត អង្អែល ខ្នង អង្អែល ដៃ ហើយថែថើបយ៉ាងស្និទ្ធស្នាល ។ លើកនេះម្ដងទៀត សូភាពស្រាប់តែព្រឺខ្លួនខ្លាកហើយអៀនផង ថ្វីត្បិតតែជាស្រីនឹងស្រីដូចគ្នាក៏ដោយ ។ នាងស្ទុះងើបឡើងអង្គុយ លីស្សាណាស្ទុះតាម ហើយចូលមកអង្គុយកៀកកិតជិតនាងដោយពោលពាក្យលួងលោមយ៉ាងផ្អែមល្ហែមថា៖

- គួរតែឯងយល់ហើយថាគ្នាស្រឡាញ់ឯងណាស់ ។ គ្នាស្រឡាញ់ឯងយ៉ាងប្ដូរផ្ដាច់ដូចជាសង្សារមួយគូដែលមានភេទផ្ទុយគ្នាអញ្ចឹងណា៎

- គ្នាក៏ដូច្នោះដែរ (សូភាពឆ្លើយតបដោយត្រង់ៗ)

- មែនឬ? ។ អញ្ចឹងកុំទៅណាចោលគ្នាណា៎សម្លាញ់ ។

ថារួច លីស្សាណាក៏ចូលទៅគ្រលុំភួយនិទ្រាវិញទៅ ដោយទុកអោយសូភាពនៅរសាប់រសល់ខ្វល់ខ្វាយនទៀលពេញផ្ទៃពូកតែម្នាក់ឯង ។ ទោះបី

ជានាងបានទទួលករុណាធម៌យ៉ាងកក់ក្ដៅរំពីលីសូរ្យាណាមិត្តនារីរបស់នាងយ៉ាងណាក្ដី ក៏សូភាពនៅតែមានអារម្មណ៍ជ្រួលច្របល់មិននឹងនរឡើយ ។ ថ្មីៗនេះទៀត គ្រាដែលសូភាពមានទុក្ខផ្សេងៗ លីសូរ្យាណាក៏បានបញ្ចេញកាយវិការញញិកញញ័កប្លែកៗមកលើនាង ។ អាកប្បកិរិយាថ្មីនេះដូចជាប្លែកចំពោះនាងណាស់ ។ ឬមួយក៏ ...ជារឿងធម្មតារបស់សាសន៍អឺរ៉ុប? ។

ចាប់តាំងពីថ្ងៃនោះមក លីសូរ្យាណាហាក់ដូចជារីករាយ ជាងប្រក្រតី ។ នៅពេលត្រឡប់មកពីធ្វើការម្ដងៗ គេតែងតែមានទិញនេះទិញនោះមកអោយសូភាពជានិច្ច ។ អំណោយជាវត្ថុគ្រប់បែបយ៉ាង មានសំពត់អាវ និងគ្រឿងសំអាងកាយដែលលីសូរ្យាណាទិញផ្ញើនាង ធ្វើអោយនាងមានការទើសទាល់ក្នុងការទទួល ព្រមទាំងញញើតចិត្តមិត្តនារីនាងរាល់ៗដង ។

ព្រឹកមួយ ពេលដែលសូភាពកំពុងតែបូមសំអាតបន្ទប់គេង លីសូរ្យាណាក៏ត្រឡប់មកផ្ទះមួយភ្លែត ដោយបាននាំយកផ្កាកូឡាបមួយទងមកហុចអោយសូភាព ហើយបន្ថែមវាចាថា៖

- គ្នាស្រឡាញ់ឯង ស្រឡាញ់ឯងណាស់ណាំសូ ។ គ្នាមាននិស្ស័យជាមួយឯងណាស់ ។

- អរគុណណាស់ណាំសម្លាញ់

តែប៉ុណ្ណោះ លីសូរ្យាណាក៏ត្រឡប់ទៅធ្វើការវិញបាត់ទៅ ។ សូភាពដាក់ផ្កាទៅលើតុ ហើយបន្តកិច្ចការផ្ទះមិនបាននឹកភ្ញាក់ងឿងឆ្ងល់ពីការដែលលីសូរ្យាណាឆ្លៀតចេញពីកន្លែងធ្វើការយកផ្កាមកអោយនាងឡើយ ។

ថៃដន្យអ្វី ថ្ងៃនេះនៅពេលដែលនាងរៀបចំតុសរសេរអោយមានរបៀបរៀបរយឡើងវិញ ស្រាប់តែសូភាពប្រទះឃើញកូនសៀវភៅកំណត់ហេតុមួយរបស់លីសូរ្យាណាធ្លាក់នៅក្រោមតុ ។ សូភាពក៏រើសឡើងមក ហើយ

ក៏រពិសដៃផ្ទាត់សន្លឹកសៀវភៅអានលេង ។ សូភាពចាប់អារម្មណ៍នឹងពាក្យមួយម៉ាត់ដែលសរសេរអក្សរធំៗពណ៌ក្រហម ព្រមទាំងមានគូសបន្ទាត់ពីក្រោមថែមទៀត ។ ហេតុតែចង់ស្គាល់ន័យនៃពាក្យដ៏ចម្លែកនេះ សូភាពក៏បើកមើលក្នុងវចនានុក្រមបារាំងខ្មែរ (ដែលនាងយកមកតាមខ្លួនពេលលួចរត់ចេញពីផ្ទះលោកស្រីផានីនោះ ) ទើបភ្ញាក់ព្រើតកាលបើពាក្យ Lesbienne នេះប្រែសេចក្ដីថា "អំពីស្រីដែលស្រឡាញ់ស្រីគ្នាឯង" ។ ពុទ្ធោអើយ! សូភាពស្រឡាំងកាំង ភ័ន្តភាំងស្មារតី ។ ស្រើនឹកហួសចិត្តយ៉ាងក្រៃលែង ។ នាងពុំដែលនឹកដៀដល់រឿងនេះម្ដងណាសោះ ហើយក៏ពុំដែលនឹកថា ខ្លួននឹងបានជួបរឿងដូច្នេះឡើយ ។ គ្រានោះហើយដែលរូបភាពដ៏ស្និទ្ធស្នាលទាំងប៉ុន្មានបានបញ្ចាំងពេញអារម្មណ៍នាង ។ ស្រាប់តែទឹកភ្នែកពីរដំណក់ក្ដៅៗរមៀលធ្លាក់ពីនេត្រាតក់ៗ ។ សេចក្ដីអស់សង្ឃឹមជាលើកទីពីរបានចូលមកញាំញីដួងចិត្តនាងទៀតហើយ ។

- ឱ! វាសនាខ្ញុំអើយ! តើនៅវងកម្មពៀរដល់ពេលណាទៀតទើបអស់? ។ សូភាពនឹកគិតស្រណោះស្រណោកម្នាក់ឯង ។ មិនតែប៉ុណ្ណោះក៏អាណិតលីស្សាណាណាស់ដែរ ហើយក៏ខ្លាចថែមទៀតផង ។

ទីបំផុត សូភាពក៏ក្លែងខ្លួនដោយពាក់ម្ហូកឡែន បង់កកន្សែងឡែនរុំជិតអស់មាត់ ទុកតែប្រឡោះភ្នែកនិងច្រមុះប៉ុណ្ណោះ ហើយចុះចេញពីលំនៅរបស់លីស្សាណាក្នុងថ្ងៃនោះឯង ។

សូភាពជិះរថយន្តក្រុងសំដៅទៅធនាគារ សូហ្សេណាល់ (SOGENAL) នៅតំបន់ Haute pierre ដែលនៅក្បែរផ្ទះលោកស្រីផានីដើម្បីទៅដកហូតយកប្រាក់ ។

នាងប្រថុយទៅទីនោះទាំងភិតភ័យជាពន់ពេក ។ នេះក៏ព្រោះតែនាងត្រូវការប្រាក់កាសជាចាំបាច់សំរាប់យកទៅតាមខ្លួន ។ គ្រានោះឯង សូភាពមានរោគប្បកិរិយាមិនសូវខុសពីចោរប៉ុន្មានឡើយ ដោយសារតែភ័យខ្លាចក្រុមគ្រួសាររបស់លោកស្រីផានីឃើញនាង ។

នៅក្នុងធនាគារ សូភាពបើកកាបូបយកកូនសៀវភៅមូលប្បទានប័ត្រ (chèquier) ចេញមកដោយពោលប្រាប់ទៅភ្នាក់ងារថា នាងត្រូវការបើកហូតប្រាក់ ។ តាមពិតទៅ នាងមិនដឹងរបៀបគេធ្វើដូចម្ដេចទាល់តែសោះ ពីព្រោះលោកស្រីផានីបានធ្វើជំនួសនាងរាល់ៗដងដោយគ្មានដែលបង្ហាត់បង្រៀន ឬបង្ហាប់នាងអោយចេះប្រើប្រាស់ការប្រើសែកម្ដងណាសោះ ។ នៅគ្រានោះ ស្រីកំសត់មានកាយវិការឆ្កេមឆ្កួមស្ទាក់ស្ទើរ ទាល់តែភ្នាក់ងារសួរទើបនាងស្រដីតបថា ៖

- ខ្ញុំត្រូវការបើកប្រាក់ខ្ញុំដែលនៅសល់ទាំងអស់ តែខ្ញុំមិនចេះសរសេរទេ

គ្រាន់តែឮដូច្នេះ ភ្នាក់ងារស្ត្រីដែលធ្វើការក្នុងធនាគារក៏ជួយបំពេញសែកហើយសូភាពចុះហត្ថលេខា ។ គេក៏ហុចប្រាក់អោយសូភាពបីពាន់ហ្វ្រង់ ។ សូភាពទទួលយកប្រាក់មកទុករួចហើយ ក៏សួរទៅគេវិញថា ៖

- ខ្ញុំត្រូវការបីម៉ឺនហ្វ្រង់ ម្ដេចក៏អ្នកស្រីបើកអោយខ្ញុំតែបីពាន់ដូច្នេះទៅវិញ ។

ភ្នាក់ងារក៏និយាយពន្យល់សូភាពសព្វគ្រប់ ហូរហែដោយបញ្ជាក់ថា ប្រាក់នាងនៅសល់តែប៉ុណ្ណេះទេ ។ កាលបើឮគេឆ្លើយដូច្នោះមកកាន់នាង នាងសែនហួសចិត្ត ហើយក៏ពុំដឹងធ្វើដូចម្ដេចកើតឡើយ ។ ពេលនោះឯង សូភាពក៏នឹកឃើញថា នាងក៏មានសៀវភៅសន្សំប្រាក់មួយទៀតមែន ។ សៀវភៅនោះ នាងបានប្រគល់ជូនលោកស្រីផានីដើម្បីយកទៅដកហូតប្រាក់

យកមកសងថ្លៃចិញ្ចៀនពេជ្រមួយវង់នោះ ហើយក៏មិនបានទារយកមកទុកជាប់នឹងខ្លួនវិញ ។

សេចក្ដីរស់សង្ឃឹមនឹងការសោកស្ដាយញាំងអោយសូភាពជ្រួលច្របល់ក្នុងដួងចិត្តដោយចង់តែស្រែកទ្រហោយំអោយបែករអាកាសា ។ សូភាពរិលមុខរកកល់ចង់ដួល ។ កម្លាំងរស់រលីងពីក្នុងខ្លួនប្រាណ ។ ស្រីខំឈានជើងដើរចេញពីធនាគារទាំងខ្លួនស្រោលថ្ងើក ។ រីឯទឹកនេត្រាក៏ហូររហែងកាត់ផែនថ្ពាល់រកទប់ពុំឈ្នះ ។ នារីកំសត់ខាំមាត់ ដើរឱនមុខសម្រក់ទឹកភ្នែកលើផ្លូវថ្នល់ដែលក្រាលទៅដោយទឹកកកសក្បុស ។

លុះឃើញរថយន្តក្រុងមកដល់ សូភាពក៏ឡើងជិះទាំងខ្លួនស្រោលថ្ងើកដូចសំឡី ។ រថយន្តបានដឹកនាងយកមកដាក់នៅចំកណ្ដាលក្រុង ស្ត្រាស់បួរ ត្រង់កន្លែង place Kléber ។ ស្រីចុះពីរថយន្តមួយទៅឡើងរថយន្តមួយទៀតធ្វើដំណើរដោយគ្មានគោលដៅប្រៀបដូចជាមនុស្សវង្វេងស្មារតីម្នាក់ ។ ស្រាប់តែមកដល់មុខស្ថានីយ៍អយស្ម័យយាន (Gare) សូភាពឃើញអ្នកដំណើរនាំគ្នាចុះច្រូ ទើបសូភាពក៏ផ្អើលចុះតាមគេដែរ ។

នាងស្រីនៅឈរអោបមួយស្របក់ធំនៅមុខស្ថានីយ៍រថភ្លើង ។ រំពេចក្រោយមក ស្រាប់តែលេចកូនគំនិតមួយរត់កាត់ខួរក្បាលនាងភ្លែត ។ សូភាពក៏បើកកាបូបយួរមើលប័ណ្ណអាស័យដ្ឋានរបស់ស្ត្រីបារាំងម្នាក់ ទើបនាងសម្រេចចិត្តទៅឈរចាំទិញសំបុត្ររថភ្លើងជាមួយគេឯងបន្តកន្ទុយគ្នាតាមការណែនាំពីអ្នកដំណើរម្នាក់ដែលនាងបានសាកសួរគេនោះ ។ ទិញសំបុត្ររួចរាល់ហើយ សូភាពក៏ដើរឆ្ពោះទៅរង់ចាំរថភ្លើង ។ ចៃដន្យអ្វី ស្រាប់តែស្រីចោលភ្នែកទៅឃើញជំនោររអ៊ីតគូដណ្ដឹងរបស់នាង ។ ជំនោរក៏ឃើញនាងវិញដែរ ។ យុវបុរសក៏ស្ទុះរឺងសំដៅមករកសូភាពទាំងចិត្តរំភើបជាពន់ពេក ។

យល់ការណ៍មិនស្រួលដូច្នេះ សូភាពក៏ខំគេចភ្លែត កាត់ហ្វូងអ្នកដំណើរដែលដើរប្រវាត់ពេញទីនោះដើម្បីរកផ្លូវរថភ្លើងរៀងៗខ្លួន ។ ជំនោរខំរត់តាមដោយស្រែកហៅបណ្តើរថា៖

- អូនសូភាព! ឈប់សិន ចាំបងផង! បងចង់ជួបអូន .... បងចង់និយាយជាមួយអូនបន្តិចបានទេ?

សូភាពពុំចង់ឮសម្រែកហៅរបស់អ្នកកម្លោះនេះទេ ។ នាងលើកដៃចុកត្រចៀក ហើយខំរត់គេចទៅមុខឡើងចូលទៅកាន់ផ្លូវរទេះភ្លើង ។ សំណាងល្អ រថភ្លើងក៏រៀបនឹងបរចេញដែរ សូភាពភ័យពេកក៏រត់ឡើងចូលទូរថភ្លើងមួយបាត់ទៅ ។ មួយនាទីបន្ទាប់មក រទេះភ្លើងក៏បរចេញដំណើរទៅដោយទុកអោយជំនោរយើងឈរតាមមើលពីក្រោយទាំងអាឡោះអាល័យក្រៃលែង ។ ចំណែកសូភាពវិញក៏បានធូរទ្រូងមួយរយៈដែរកាលបើបានគេចផុតពីជំនោរ ។

ដោយការរវល់កម្លាំងទឹកចិត្ត ផ្សំនឹងការហេវឃ្លានផង សូភាពក៏លង់លក់ទាំងភ្លេចខ្លួនទៅ ។ បុរសម្នាក់បានមកដាស់ហៅនាងដើម្បីឆែកឆេរសំបុត្រ ។ សូភាពតក់ស្លុតហើយញ័រចំប្រប់ រួចក៏ហុចសំបុត្រទៅភ្នាក់ងារឆែកឆេរនោះ ។ នាងឮគេស្រដីមកកាន់នាងថា៖

- អ្នកស្រីបានទិញសំបុត្រថ្នាក់លេខពីរ តែអ្នកស្រីបានបន្លំមកជិះថ្នាក់លេខមួយ ។

- ឱ! កន្លែងនេះជាថ្នាក់លេខមួយឬ? (សូភាពសួរទាំងភិតភ័យ)

- បាទ! ចំពោះការប្រព្រឹត្តល្មើសនេះ ខ្ញុំត្រូវផាកពិន័យជាទឹកប្រាក់ចំនួនមួយរយដប់ប្រាំង ។

និយាយរួចពីមាត់ភ្លាម ភ្នាក់ងារឆែកឆេរក៏ធ្វើកូនសំបុត្រមួយហុចអោយ

សូភាពបន្ទាប់ពីទារប័ណ្ណសំគាល់ខ្លួនរួច ។ សូភាពខិតខំនិយាយអង្វរករភ្នាក់ងាររថភ្លើងទាំងស្រងូតស្រងាត់ថា៖

- សូមលោកមេត្តាអភ័យទោសអោយខ្ញុំផងចុះ ។ ខ្ញុំគ្មានបំណងប្រព្រឹត្តបន្លំបែបនេះទេ ។ នេះមកពីខ្ញុំពុំធ្លាប់ធ្វើដំណើរតាមរថភ្លើងឡើយ ហើយនេះគឺជាលើកទីមួយហើយលោកដែលខ្ញុំបានប្រព្រឹត្តអំពើគួរអោយស្តាយនេះ ។

នេះគឺជាន័យដែលសូភាពចង់និយាយទៅកាន់ភ្នាក់ងារឆែកសំបុត្រ ។ ប៉ុន្តែដោយនាងពុំចេះភាសាបារាំងប៉ុន្មាននោះ នាងនិយាយទៅកាន់គេគតាក់គតុបតាមតែនាងរកនឹកឃើញដោយពុំត្រូវន័យនៃពាក្យពេចន៍ដែលនាងគិតនោះប៉ុន្មានទេ ។ ការស្តាប់មិនសូវយល់ពីសំដីសូភាពជាភាសាបារាំង និងការដែលខ្វះអធ្យាស្រ័យយោគយល់ផងនោះ ភ្នាក់ងាររថភ្លើងក៏ស្រដីយ៉ាងតឹងរ៉ឹងថា៖

- បើអ្នកមិនព្រមបង់ប្រាក់ទេ ខ្ញុំនឹងដកហូតយកកាតរបស់អ្នកទុកមួយរយៈកាលសិន

- សូមលោកអត់ទោសអោយខ្ញុំផងលោក ខ្ញុំគ្មានប្រាក់ទេ

- បើអ្នកគ្មានប្រាក់នោះ អ្នកមិនហ៊ានធ្វើដំណើរទៅឆ្ងាយដូច្នេះទេ ។

- ពិតមែនណាំលោក

- អញ្ចឹងខ្ញុំត្រូវតែដកហូតយកកាតទុកសិន ។ ចាំកាលណាអ្នករកប្រាក់បង់ថ្លៃពិន័យរួចនោះ ទើបអ្នកបានទទួលកាតវិញ

កាលបើឮគេឆ្លើយមករកនាងយ៉ាងម៉ឺងម៉ាត់ដូច្នេះ សូភាពទៅជាកន្ទះរាក្នុងចិត្តជាពន់ពេក ។ ស្ត្រីបារាំងម្នាក់ដែលមានវ័យប្រហែលជាហុកសិបឆ្នាំដែលអង្គុយជាប់ក្បែរនាងសូភាពក៏ស្រដីជំនួសសូភាពថា៖

- មិនអីទេលោក បើនារីនេះមានបញ្ហាដូច្នេះ ខ្ញុំធានាចេញប្រាក់ជំនួសចុះ

- លោកស្រី ! !

សូភាពឱទានឡើងទាំងរំភើបនិងភ្ញាក់ផ្អើលចំពោះកាយវិការរបស់ស្ត្រីបារាំងចិត្តធម៌នេះ ។ ស្ត្រីចិត្តល្អនោះក៏ឃាត់សូភាពថា៖

- ទុកអោយខ្ញុំចេញប្រាក់ទូរទាត់ជាមួយគេចុះ ចូរនាងកុំមាត់កុំករអី

លុះភ្នាក់ងារឆែកឆេរដើរបាត់ទៅ សូភាពក៏សំដែងសេចក្តីកតញ្ញូចំពោះស្ត្រីដែលបានយករអាសារនាងនេះ ។ នាងនឹកថាប្រហែលជាព្រះដឹកនាំផ្លូវនាងអោយមកជួបស្ត្រីនេះហើយមើលទៅ ។ គេឮសូរអ្នកទាំងពីរឆ្លើយឆ្លងគ្នាជាហូរហែរហូតមក ។

- លោកស្រីបានជួយយករអាសារខ្ញុំអោយបានរួចផុតពីទុក្ខទោសអំបាញ់មិញ ខ្ញុំមិនភ្លេចគុណលោកស្រីទេ ! លោកស្រី !

- ទេ ! គ្មានគុណគ្មានអាស្រ័យអីទេនាង ។ មនុស្សយើងកើតមកត្រូវតែចេះជួយគ្នាទៅវិញទៅមកដោយមិនរើសមុខទេ ។ នេះជាការធម្មតាទេតើនាង ....

- ចាំះ លោកស្រីមានចិត្តល្អណាស់ ។ លោកស្រីគ្មានគិតប្រកាន់ជាតិសាសន៍ពណ៌សម្បុរសោះ

- ត្រូវណាស់ ខ្ញុំពុំមែនជាមនុស្សប្រកាន់ពណ៌សម្បុរទេនាង ។ អំបាញ់មិញនៅលើរថភ្លើង ខ្ញុំបានឮគេនិយាយត្មះតិះដៀលពីនាងយ៉ាងច្រើន ធ្វើអោយខ្ញុំទើសត្រចៀកខ្លាំងណាស់ ។ ខ្ញុំមិនចូលចិត្តទេមនុស្សណាដែលគ្មានបេះដូងនោះ ។ បើមិនបានជួយគេទេក៏ហីទៅចុះ សូមកុំអោយតែជាន់ពន្លិចគេថែមទៀត ។ ខ្ញុំជឿថា នាងពុំមែនជាមនុស្សចង់ប្រព្រឹត្តកំហុសនេះទេ ក៏ប៉ុន្តែប្រហែលមកពីនាងមានវិបត្តិអ្វីមួយដែលនាំអោយនាងមានការភ័ន្តច្រឡំដូច្នេះ ។

- ចាំះ ពិតហើយលោកស្រី
- ព្រោះតែខ្ញុំគិតឃើញដូច្នេះហើយបានជាខ្ញុំជួយនាងណាំ ។
- ចាំះ! អរគុណលោកស្រីខ្លាំងណាស់ដែលមានករុណាធម៌ចំពោះស្រីខ្មែរកំសត់ដូចយ៉ាងរូបខ្ញុំនេះ
- អូហ៍ នាងជាខ្មែរឬ?
- ចាំះ លោកស្រី
- កាលបើដឹងថានាងជាខ្មែរ នាងក៏បានធ្វើអោយខ្ញុំនឹកដល់អនុស្សាវរីយ៍មួយដែលកន្លងទៅកាលពីឆ្នាំ ១៩៨១ គឺកាលដែលខ្ញុំបានទៅចូលរួមក្នុងពិធីបុណ្យចូលឆ្នាំខ្មែរមួយនៅតំបន់ សូឡឺសែហ្វ (Saut-le-Cerf) ដែលរៀបចំឡើងដោយសមាគមខ្មែរនៅវ៉ូស្ស (les Vosges) ។ កាលណោះ ខ្ញុំបានទស្សនារបាំខ្មែរ ហើយបានភ្លក្សម្ហូបចំណីខ្មែរយ៉ាងឆ្ងាញ់ទៀតផង ។ សិល្បៈទាំងនេះដែលបង្ហាញអោយឃើញថា ជនជាតិខ្មែរក៏ធ្លាប់មានវប្បធម៌អរិយធម៌ខ្ពង់ខ្ពស់មិនចាញ់ប្រទេសជិតខាងសោះឡើយ ។ តាំងពីនោះមក ខ្ញុំក៏មានការចាប់អារម្មណ៍នឹងរឿងខ្មែររហូត ។ ខ្ញុំបានទិញសៀវភៅច្រើនណាស់ដែលសរសេរពីប្រទេសខ្មែរ ព្រោះខ្ញុំចង់ស្គាល់ចង់ដឹងពីប្រទេសកម្ពុជារបស់អ្នក ....
- អញ្ចឹងឬអ្នកស្រី?

សូភាពរំភើបរីករាយឥតឧបមាកាលបើឮគេនិយាយពីប្រទេសខ្មែរ ។ នាងពុំដឹងជាត្រូវឆ្លើយដូចម្តេចអោយសក្តិសមទៅគេវិញទេ ត្បិតនាងគ្មានការចេះដឹងអ្វីសោះ ។ ភាសាបារាំងសោតក៏ចេះស្តួចស្តើងយកមកប្រើការមិនបាន ។ ម្ល៉ោះហើយស្រីបានតែញញឹមទាំងពេញចិត្តទៅរកគេតែប៉ុណ្ណោះ ។

លុះរថភ្លើងបានមកដល់ចំណតស្ថានីយ៍អេពីណាល់ ស្ត្រីបារាំងមិនស្គាល់ឈ្មោះនេះក៏ដឹកដៃសូភាពអោយចុះមកជាមួយគាត់ ។ សូភាពបានជួយយួរ

ស្បែង និង សំពៀត ឥវ៉ាន់ របស់ ស្ត្រី ចិត្ត ធម៌ ដោយ ឥត ខ្លាច ឡើយ ហត់ សោះ ឡើយ ។ ឃើញដូច្នោះ ស្ត្រីចំណាស់ក៏ពោលឡើងថា៖

- នាងចិត្តបានណាស់
- អំពើនេះពុំទាន់សក្តិសមនឹងសប្បុរសធម៌របស់លោកស្រីមកលើរូបខ្ញុំទេ ។
- ខ្ញុំបានប្រាប់នាងរួចហើយថាកុំអោយនាងរំឭកពីគុណអាស្រ័យអ្វីនោះ
- ទោះ យ៉ាង ណាក៏អំពើដ៏ប្រពៃ នេះ មិន អាច បំភ្លេច បាន ទេ លោក ស្រី ។

លោកស្រី?!

ឃើញសូភាពមានអាការៈអេះអុញៗដូច្នេះ លោកស្រីបារាំងនោះក៏សាកសួរដោយឥតបង្អង់ថា៖

- នាងចង់សួរខ្ញុំពីរឿងអ្វីឬ?

សូភាព ក៏បើក កាបូប ឡើង យក ក្រដាស មួយ សន្លឹក មក បង្ហាញ ស្ត្រីបារាំង ។ គ្រាន់តែឃើញក្រដាសនោះភ្លាម គាត់ក៏មានវាចាទៅកាន់សូភាពទាំងភ្ញាក់ផ្អើលថា៖

- នាងត្រូវរកឈ្មោះហ្នឹងឬ? បានសេចក្តីថា នាងឥតមានទីកន្លែងសំណាក់ទេនៅយប់នេះ ប្រសិនបើនាងទៅរកឈ្មោះនេះមិនជួប ។
- ចាំះ ខ្ញុំឥតស្គាល់អ្នកណានៅអេពីណាល់នេះទេ លោកស្រី

លោកស្រីឯកក្បាលបណ្តើរ គិតបណ្តើរ ទើបស្រដីថា៖

- យប់ជ្រៅណេះទៅហើយៗនាងមិនស្គាល់អេពីណាល់ថែមទៀតនោះ ខ្ញុំយល់ថាវាមានការពិបាកបន្តិច ។ ចុះឧបមាថាអ្នកដែលនាងត្រូវទៅរកនោះ គេមិននៅផ្ទះ តើនាងត្រូវធ្វើយ៉ាងណាទៅ? ។ ...ណ្ហើយចុះ! ខ្ញុំនាំនាងទៅផ្ទះខ្ញុំសិន ចាំស្អែក ចាំគិតគូរតទៅទៀត ។ តើនាងយល់យ៉ាងណាដែរ?
- ចាំះ ខ្ញុំអរណាស់ដែលបានលោកស្រីជួយយកអាសារខ្ញុំដូច្នេះ

មួយរាត្រីបានកន្លងផុតទៅ .....

ព្រលឹមឡើង លោកស្រីចិត្តធម៌ក៏បានចេញទៅធ្វើការដោយហៅតាក់ស៊ីអោយជូនសូភាពទៅរកឈ្មោះដែលសូភាពត្រូវការជួបនោះដោយបានទុកនាម អាស័យដ្ឋាននិងលេខទូរស័ព្ទអោយសូភាពដោយចិត្តស្មោះសរជាទីបំផុត ។

- ចូរនាងកុំទើសទាល់អោយសោះ បើមានការអីចូរហៅរកខ្ញុំណា៎

- ចា៎ះ ខ្ញុំសូមអរគុណ (សូភាពសំដែងការដឹងគុណដោយឱនលំទោនតាមលក្ខណៈរបស់ខ្មែរសុទ្ធសាធ ។ រួចនាងក៏ចាកចេញពីស្ត្រីនោះទៅ) ។

នៅក្នុងរថយន្តតាក់ស៊ី សូភាពកាន់មើលប័ណ្ណនាមនិងអាស័យដ្ឋានរបស់ស្ត្រីនោះ ដោយនឹកក្នុងចិត្តថា "លោកស្រីនេះមានចិត្តល្អប្រពៃណាស់" ។ ទើបអនុស្សាវរីយ៍ចាស់មួយនៅក្នុងសួនច្បារក្បែរទន្លេរាំងជាមួយល្ងិស្សាណាបានហក់មកបញ្ជាំងជាថ្មីក្នុងអារម្មណ៍របស់នាង ។ នាងនឹកស្រណោះដល់អំពើល្អរបស់ល្ងិស្សាណាដែរ ។ រីឯការរត់ចេញពីផ្ទះល្ងិស្សាណាដោយគ្មានដំណឹងអ្វីដូច្នោះពិតជាអំពើឆ្គាំឆ្គងមួយគួរអោយសោកស្តាយយ៉ាងក្រៃលែង ។ ប៉ុន្តែទោះជាខុសឆ្គងបែបនេះក្តី ក៏នាងសុខចិត្តទទួលកំហុសទៅចុះ ជាជាងរស់នៅដោយរួមរក្សជាមួយភេទស្រីដូចគ្នាដូច្នេះនោះ ។

សូហ្វ័រតាក់ស៊ីបាននាំនាងមកដល់គោលដៅ ។

ប៉ុន្តែអនិច្ចាអើយ! គេក៏មិននៅផ្ទះទៀត ។ នាងខំរំពឹងពីចម្ងាយមកថាបានមកសំណាក់អាស្រ័យជាបណ្តោះអាសន្ននៅទីនេះ តែបែរជាប្រាសចាកពីក្តីបំណងទៅវិញ ។ តើនាងត្រូវរសាត់អណ្តែតទៅទីណាទៀត ព្រះអើយ! ។ កំពុងតែគិតដោះស្រាយពីបញ្ហាជីវិតដ៏សែនស្មុគស្មាញនេះ ស្រាប់តែមានសម្លេងក្មេងប្រុសម្នាក់ស្រែកហៅនាងយ៉ាងខ្លាំងៗថា៖

- ម៉ាក់! ម៉ាក់ ។

សូភាពទប់ដំហានង៉ក់ ហើយងាកក្រោយរកមើលម្ចាស់សម្លេងទន្ទឹមគ្នានឹងពេលដែលកុមារតូចចាប់ទាញជាយអាវរងានាងជាប់ ។ សូភាពងាកមើលឆ្វេងស្តាំ ។ លុះគ្មានឃើញមានមនុស្សចាស់ទុំណានៅក្បែរសោះ ទើបមាណវីដាក់ខ្លួនអង្គុយចុះចំពីមុខកុមារតូច ដោយពោលវាចាសាកសួរដោយផ្អែមល្ហែមថា៖

- នាងតូច នាងប្រឡំហើយ ។ ហេតុអ្វីបានជានាងមកទីនេះតែម្នាក់ឯងអញ្ចឹង? ។ នាងវង្វេងទេដឹង? ។ តើម៉ាក់នាងនៅឯណាដែរ? ប្រាប់មីងមកមើលក្មួយ!

នាងតូចគ្រវីក្បាលមួយៗ មាត់ពេបបន្តិច រួចសម្រក់ទឹកភ្នែក ។ កាលបើលើកខ្នងដៃជូតទឹកភ្នែករួច កុមារនេះក៏ស្រដីថា៖

- ម៉ាក់ខ្ញុំ គឺម៉ាក់ហ្នឹងហើយ

វានិយាយទាំងលើកដៃចង្អុលទៅរកសូភាពផង ។

- ហ៊ឺ! (សូភាពដកដង្ហើមធំមួយយ៉ាងវែង) ... ចុះប៉ានាង? ប៉ានាងនៅឯណាដែរ? តើនាងឈ្មោះអីដែរនាងតូច?

- រតនៈ

- រតនៈ! តើផ្ទះនាងនៅកន្លែងណាដែរ? ។ ចាំមីងជូនទៅជួបប៉ាប៉ានិងម៉ាក់វិញណា៎

- ទេ! រតនៈអត់ចង់ទៅជួបប៉ាប៉ាវិញទេ ប៉ាប៉ាកាចណាស់

- មិនបានទេ នាងនៅតូចណាស់ ត្រូវតែទៅនៅជាមួយប៉ាម៉ាក់វិញ ។ ទោះបីប៉ាប៉ាកាចក៏ដោយ ក៏ប៉ាប៉ានៅតែស្រឡាញ់នាងដែរ ជឿមីងចុះណា៎ក្មួយ

អារម្មណ៍សូភាពវិលវល់ប្របូកប្របល់វក់វី ដោយពុំដឹងគិតដោយវិធីណា ។ រឿងខ្លួនឯងពុំទាន់ដោះស្រាយរួចផង ក៏ស្រាប់តែមកប្រទះរឿងថ្មី

មួយទៀតដូច្នេះ ។ ខ្លួនពុំទាន់មានទីកន្លែងស្នាក់អាស្រ័យនៅឡើយ ហើយក៏គ្មានស្គាល់ទិសតំបន់អ្វីនៅក្នុងស្រុកនេះថែមទៀត ។ កាលបើឃើញមានប៉ូលីសម្នាក់នៅក្បែរនោះ សូភាពក៏នាំកុមាររតនៈទៅប្តឹងប៉ូលីសរំពីបុព្វហេតុសព្វគ្រប់ទាំងអស់ ។ គេអាចស្គាល់អាស័យដ្ឋានរបស់កុមារតូចនេះបានដោយសារផ្លាកតូចមួយដែលរតនៈព្យួរភ្ជាប់នឹងខ្សែ ក ។

........................................................................................................................................

នាងសូភាពបាននាំកុមាររតនៈឡើងមកដល់លើផ្ទះ ។ នាងមានការស្ទាក់ស្ទើរវារែកយ៉ាងខ្លាំងទំរាំដាច់ចិត្តចុចកណ្តឹងផ្ទះគេ ។ នៅពេលដែលទ្វារផ្ទះរបើកខ្ទាកឡើង នាងឃើញបុរសម្នាក់មានវ័យប្រហែលខ្ទង់សែសិបឆ្នាំនៅឈរទីនោះទាំងទឹកមុខហ្មួហ្មង ។ សូភាពលើកដៃប្រណម្យជំរាបសួរបុរសនោះដែលនាងនឹកក្នុងចិត្តថាជាម្ចាស់ផ្ទះ ហើយដែលត្រូវជាបិតារបស់រតនៈផង ។ ការនឹកស្មាននេះក៏ត្រូវមែន កាលបើនាងឮពាក្យដែលគេនិយាយមកកាន់រតនៈទាំងគំរោះគំរើយទាំងមិនទាន់ចូលទៅក្នុងផ្ទះវិញស្រួលបួលផង ។ ចំណែករតនៈវិញ គ្រាន់តែឮពាក្យបិតាបន្ទោសហើយបញ្ចេញទឹកមុខមាំដាក់ដូច្នេះ វាស្ទុះរឹងមកឈរលាក់មុខនៅពីក្រោយនាងសូភាពមួយរំពេច គឺហាក់បីដូចជាខ្លាចបិតាសម្បើមណាស់ ។

ចូលទៅដល់ក្នុងបន្ទប់ទទួលភ្ញៀវភ្លាម លោកជីវិនពុំបានយកចិត្តទុកដាក់គួរសមរកភ្ញៀវស្រីរបស់គេឡើយ ។ គេឮសួរតែប្រសាសន៍លោកស្តីបន្ទោសបុត្រាលោកទៅវិញ ។

- អាកូនចង្រៃ! ចុះឯងដើរទៅណាមកណាអស់មួយព្រលប់ធំ? ។ ទៅ! ចូលទៅខាងក្នុងផ្លាស់ប្តូរសំលៀកបំពាក់លុបលាងមុខមាត់អោយស្អាតបាតភ្លាម ។ រ្លឺស! តែទ្រាំមិនបាន រញ្ជួទះថែមទៀតឥឡូវហ្នឹងហើយ ...

ផុតវាចាកាលណា លោកក៏ប្រាប់ខ្ញុំងរតនៈអោយចូលទៅខាងក្នុង ទើបបែរមកនិយាយជាមួយនាងសូភាពថា៖

- ក្មេងឥឡូវពិបាកប្រដៅណាស់នាង ។ វារស់នៅក្នុងសង្គមគេ វាបានចម្លងឬកពារស់ដីសំដៅប្រឡឹមប្រឡើសបើសមិនខុសពីកូនបរទេសប៉ុន្មានទេ ។ អាយុទើបតែប្រាំមួយឆ្នាំសោះ តែរឹងនេះរឹង រកតែខ្ញុំស្លូតដាក់មិនកើត ...

- ប្រហែលជាលោកមានទម្លាប់កាចដាក់កូនខ្លាំងណាស់មើលទៅ? ។ រតនៈដូចជាចាក់ស្បាតខ្លាចលោកសម្បើមណាស់ ។

នាងសូភាពនិយាយដោយត្រង់ៗ ដោយមិនបានគិតថាសំដីរបស់នាងអាចប៉ះទង្គិចដល់ចិត្តរបស់លោកជីវ័នឡើយ ។ លោកក៏មិនឆ្លើយតបតទៅនាងវិញថារ៉ាំទាំងអស់ ក្រៅពីនិយាយបន្លប់វិញថា៖

- ខ្ញុំអរគុណអ្នកស្រីណាស់ដែលបានជូនរតនៈកូនខ្ញុំមកផ្ទះវិញ ។ បើពុំយល់ទាស់ទេ ខ្ញុំសូមជូនអ្នកស្រីទៅផ្ទះវិញ ។ តើផ្ទះអ្នកស្រីនៅម្តុំណាដែរ?

លុះឮគេសួរពីផ្ទះសម្បែង សូភាពចង់ឆ្លើយប្រាប់គេថា "នាងគ្មានផ្ទះសម្បែងទេ" ព្រមទាំងចង់និយាយប្រាប់រឿងពិតរ៉ាំពីការដែលនាងធ្វើដំណើរមកអោយពីណាល់នេះដែរ ក្រែងលោគេហជនមានមេត្តាជួយដោះស្រាយអោយនាងបាន ។ ប៉ុន្តែកាលបើឃើញអាការៈគោះតើយសោះអង្គើយរបស់ម្ចាស់ផ្ទះ ដែលភ្លាមឡើងទារជូននាងទៅផ្ទះវិញ ហាក់ដូចជាចង់ដេញនាងដូច្នេះនោះ ហើយនាងដូចជាគ្មានឃើញស្រីណាម្នាក់នៅក្នុងផ្ទះនេះផង សូភាពក៏តបទៅគេហជនវិញថា៖

- ចា៎ះ សូមលោកកុំព្រួយអី ខ្ញុំទៅផ្ទះខ្ញុំដោយខ្លួនឯងបានហើយ

លុះនាងសូភាពចេញផុតទៅ លោកជីវ័នក៏រៀបចំបាយទឹកអោយរតនៈដោយពុំទាន់រលត់កំហឹងពីថ្ងៃនៅឡើយ ។ គេឮលោកនិយាយទាំងគំរោះ

គំរើយទៅរតនៈថា៖

- អាឯងនេះក្បាលរឹងណាស់! អញហាមត្រង់ណា ធ្វើត្រង់នោះ ។ លើកក្រោយ បើហ៊ានធ្វើផ្ដេសផ្ដាសអញ្ចឹងទៀត អញដាក់ទណ្ឌកម្មអោយខ្លាំងជាងនេះទៅទៀត ។ ម៉ែចក៏មិនសុំច្បាយឆាប់ៗទៅ នៅអង្គុយមើលមុខអញដល់ណាទៀត?

- ប៉ាប៉ា!!

- ស្អី?

- ប៉ាប៉ាម៉ែចក៏មិនឃាត់មីងអោយញុំាបាយផង ។ គាត់ច្បាស់ជាមិនទាន់ញុំាដូចរតនៈដែរណាំ

- យើស! គិតតែស៊ីខ្លួនឯងអោយឆ្អែតទៅ កុំរវល់គិតគេពេក

ថ្វីបើគេបានឆ្លើយពាក្យនេះទៅរកកូនគេមែន ប៉ុន្តែបុរសយើងហាក់ដូចជាភ្ញាក់ខ្លួន ហើយមានវិប្បដិសារីយ៉ាងច្រើនចំពោះការខុសសុជីវធម៌របស់គេនាពេលកន្លងទៅអំបាញ់មិញនេះ ។ គេហជនក៏ស្ទុះចេញទៅរកមើល ក្រែងសូភាពពុំទាន់ទៅណាឆ្ងាយនៅឡើយ ។ ប៉ុន្តែ វាហួសទៅហើយ លោកមិនបានឃើញសូភាពដូចបំណងទេ ។ កាលបើឃើញបិតាត្រឡប់ចូលមកក្នុងផ្ទះវិញតែម្នាក់ឯង រតនៈក៏សាកសួរបិតាទាំងមុខស្លុតថា៖

- ប៉ាប៉ា មីងហ្នឹងអត់មកវិញទេឬ?

លោកជីវ៉នមិនឆ្លើយថាអ្វីទាំងអស់ ។ លោកចេញមកអង្គុយក្នុងបន្ទប់សាឡុងតែម្នាក់ឯង ។ លោកគិតតែដកបារីមកជក់ មួយដើមហើយមួយដើមទៀតដោយបង្ហុយផ្សែងទ្រលោមពេញបន្ទប់ទាំងអារម្មណ៍រវើរវាយគិតវែងឆ្ងាយ ទំនងដូចជាកំពុងគិតទៅរកបញ្ហាអ្វីមួយដ៏ស្មុគស្មាញខ្លាំងណាស់ ។ មួយស្របក់ក្រោយមក ទើបគេឮសូរវាចាលោកស្រែកហៅកូនប្រុសលោកអោយមកជិត ។

- រតនៈ ញាំបាយរួចហើយ មកណេះមួយភ្លែត

កុមារាដើរសំដៅឆ្ពោះមករកបិតាដោយបង្អួសជំហានមួយៗទាំងញញើត ញញើម ។

- រតនៈ

- បាទ!

រតនៈឱនភក្ត្រចុះ រួចរើសក្រចកដៃលេង ដោយភ័យខ្លាចបិតាស្ដីថា អោយទៀត ។ ឃើញដូច្នោះ លោកជីវ៉នក៏នឹករអាណិតកូន ហើយក៏សម្រួល វាចាថា៖

- កូនឯងឈប់ធ្វើផ្ដេសផ្ដាសអោយប៉ាប៉ាខឹងទៀតព្រះទេ ។

- បាទ!

- ប៉ាមិនដែលចង់ស្ដីអោយកូនទាល់តែសោះ ។ ព្រោះតែកូនឯងរឹងទទឹង ដាក់ប៉ាពេក បានជាប៉ាទ្រាំមិនបាន ។ កូនត្រូវដឹងថា ប៉ាស្រឡាញ់ឯង ណាស់ ។ បើកូនចេះស្ដាប់បង្គាប់ដោយចេះគោរពកោតខ្លាចប៉ានោះ ប៉ា សប្បាយចិត្តណាស់ ។ តើកូនឯងស្រឡាញ់ប៉ាទេ រតនៈ?

- បាទ! រតនៈស្រឡាញ់ប៉ាប៉ា

- បើស្រឡាញ់ប៉ាប៉ា កូនឯងកុំធ្វើអោយប៉ាខឹងច្រើនទៀតព្រះទេ ។ កាលណា ប៉ាខឹងច្រើន ... ប៉ារឹតតែឈឺច្រើន ... ចុះឧបមាបើប៉ាឈឺហើយស្លាប់បាត់ទៅ? តើកូនឯងនៅជាមួយអ្នកណា បើយើងមានតែឪពុកនិងកូនម៉ង់ៗអញ្ចឹង? ...

និយាយមកដល់ត្រឹមណេះ លោកជីវ៉នក៏ចាប់ក្អកយ៉ាងញាប់រន្ថើន ។

នៅខាងក្រៅផ្ទះឯណោះ សូភាពបានមកដល់ប្រហែលបីនាទីរួចទៅ ហើយ ។ កាលបើឃើញទ្វារផ្ទះចំហបន្តិច នាងចង់ចូល តែនាងមិនហ៊ាន ដោយខ្លាចចិត្តម្ចាស់ផ្ទះ ។ ស្រីពនេចរក៏ដាក់ខ្លួនរង្គុយក្បែរនោះ រង់ចាំស្ដាប់

ការសន្ទនារវាងឪពុកនិងកូនតទៅទៀត ។

លោកជីវិនបឺតបារីមួយខ្សឺតទៀត ទើបបន្តវាចាថា៖

- បើ ប៉ា ស្លាប់ ទៅ កូន ច្បាស់ ជា វេទនា ធំ ហើយ ។ ម្ដាយ ឯង គេប៉ ....

ហ៊ុ! ...(លោកដកដង្ហើមធំ ហើយក៏មិនបន្ថែមអ្វីទៀតឡើយពីរឿងមាតារបស់រតនៈ) ។ នៅពេលវ៉ាកងណូអែលនេះ ម៉ាដាមុរ៉ានដែលជាមេដោះកូនឯង គេមិននៅផ្ទះទេ ... ប៉ាក៏មិនដឹងយកកូនឯងទៅដាក់កន្លែងណាឡើយ ពេលដែលប៉ាទៅធ្វើការ ឬាត់ទៅនោះ ។ តើ...កូនហ៊ានទៅក្នុងផ្ទះតែម្នាក់ឯងទេ ... ប៉ាដូចជាទាល់គំនិតពុំដឹងយកកូនទៅផ្ញើនឹងអ្នកណាទេ ...

- បាទ! ហ៊ាន ប៉ាប៉ា

- បើអញ្ចឹង កូននៅផ្ទះ កុំលេងអីដែលនាំអោយមាន គ្រោះថ្នាក់ដល់ខ្លួន ដូចជាកាំបិត កន្ត្រៃ ឈើគូសជាដើម ឮទេ

- បាទ

- បើមានអ្នកគេចុចកណ្ដឹងហៅ ក៏កុំបើកអោយគេអោយសោះ ឮទេកូន

- បាទ!

- ល្អ! អញ្ចឹងទៅដុសធ្មេញសិនកុំអោយដង្កូវស៊ីធ្មេញ រួចទៅគេងចុះ

រតនៈក៏រត់ត្រុយចូលកាន់បន្ទប់ទឹកដោយទុកអោយបិតាបង្ហើយបារីរបស់មួយដើមទៀត ។

វាយោខែធ្នូបក់មួយវឹងមកបណ្ដាលអោយទ្វារផ្ទះលោកជីវិន ដែលចំហបន្តិចនោះ ហុកលាន់ព្រួច្រាំង ។ លោកជីវិនមាកការងឿងឆ្ងល់ ក៏ស្ទុះចេញទៅមើលមាត់ទ្វារចូល ។ លុះឃើញទ្វាររបើក លោកក៏បិទចាក់សោដោយមិនបានចាប់ភ្លឹកមើលទៅខាងក្រៅសោះឡើយ ។

ម៉ោង ២២ ប្លាយទៅហើយ សូរភាពនៅអង្គុយត្របោមក្បាលជង្គង់ គ្រលុំភួយ(ដែលនាងរកទិញបានពីព្រលប់មក) យ៉ាងក្រញ៉ោនៗនៅមាត់

ទ្វារផ្ទះលោកជីវ៉ែន ។ ពីគ្រាមុនៗ នាងធ្លាប់បានប្រទះឃើញអ្នកសុំទានទទួលទានដំណេកនៅលើផ្លូវថ្នល់ នៅលើកៅអីក្នុងសួនច្បារសាធារណៈផ្សេងៗ សូភាពតែងនឹករអើលរាណិតដល់ជនកំសត់ក្រីក្រតោកយ៉ាកទាំងនោះណាស់ ។ ឥឡូវនេះ ក៏ស្រាប់តែនាងបានមកស្គាល់ស្ថានភាពមួយមិនខុសពីជនស្មូមយាចកទាំងប៉ុន្មាននោះឡើយ ។ ក្នុងរយៈពេលប៉ុន្មានថ្ងៃដែលនាងរង់ចាំការវិលត្រឡប់មកវិញនៃលោកស្រី មុល្លែរ (គឺស្ត្រីបារាំងដែលនាងមានអាស័យដ្ឋាននោះ) នាងគិតថា នាងត្រូវតែរកជួលកន្លែងណាមួយសំណាក់បណ្ដោះអាសន្នសិន ។ ប៉ុន្តែនាងក៏មិនបានដឹងថា នៅស្រុកបារាំង ការរកជួលផ្ទះនៅដោយខ្លួនគ្មានប្រាក់ហៀវត្សរ៍នោះមិនមែនជាការងាយឯណាព្រះម្ចាស់ថ្លៃអើយ! ។ ការមិនបានគិតឃើញវែងឆ្ងាយអោយបានល្អិតល្អន់ពីមុនមកនេះហើយ ដែលញ៉ាំងអោយសូភាពរងក្ដីវេទនាដល់ថ្នាក់នេះ ។ សេចក្ដីក្លាហានខុសបែបបទ ខុសទំនងបែបនេះ អាចធ្វើបានមែននៅក្នុងស្រុកយើង ។ សូភាពគិតមិនបានដិតដល់ដោយនឹកស្មានថា ចង់ទៅរកអ្នកណាមួយ អ្នកនោះគេនៅចាំទទួលនាងនៅក្នុងផ្ទះដោយទោះបីជានាងគ្មានបានជូនដំណឹងគេជាមុនក្ដី ។ ជាពិសេស ជនជាតិរបស់គេៗមិនដែលសប្បាយចិត្តនឹងអោយយើងទៅរកគេដោយគ្មានការណាត់ទុកជាមុនសោះនោះឡើយ ។ ឥឡូវសូភាពបានពិចារណាយល់ខ្លះហើយ ។ ប៉ុន្តែអ្វីៗក៏កន្លងហួសអស់ហើយ អំពើទាំងនោះក៏កំពុងតែផ្ដល់ផលវិបាកអោយនាងយ៉ាងច្រើននៅពេលនេះ ។ នាងយល់ថា នាងប្រាកដជាមិនអាចធ្វើខ្លួនជានារីពនេចរផ្សងព្រេងបែបនេះតទៅទៀតឡើយ ។ ការយល់ឃើញដូច្នេះ បន្ថែមទៅលើនិស្ស័យដែលនាងមានចំពោះកុមាររតនៈទៀតនោះ ទើបសូភាពបានសំរេចចិត្តថាមករករតនៈនៅផ្ទះរបស់គេ ហើយប្រាថ្នាមកសុំនៅជាមួយរតនៈចុះ ។

\+ + + +

ម៉ោងប្រាំមួយព្រឹក ... ឡានដឹកសំរាមក៏បានមកប្រមូលយកសំរាមនៅក្បែរផ្ទះលោកជីវ៉ែន ។ សូភាពក៏ខំស្ទុះងើបពីដំណេក ហើយប្រញិបប្រញាប់បត់ភួយ ហើយខ្ទិបចុះទៅតាមជណ្ដើរមួយចុះទៅក្រោមដី (cave) ដោយខំលាក់ខ្លួនពួនអោគ្នាទំរាំរកពេលល្អអាចឡើងមករករតនៈបាន ។ នាងនៅរង់ចាំទាល់តែលោកជីវ៉ែនចេញផុត ទើបនាងហ៊ានឡើងទៅគោះទ្វារផ្ទះកុមាររតនៈ ។

រតនៈចេញមកបើកទ្វារទាំងស៊ើងមម៉ើង ។ ស្គាល់ជាក់ថានាងសូភាព កុមារក៏ស្ទុះរតរឹងចូលមកក្នុងរង្វង់ហត្ថារបស់នារីកំព្រា ថែមទាំងឱទានដោយសោមនស្សថា៖

- មីង! មីងមកវិញហើយឬ?

- ចា៎ះ មីងនឹកនាងណាស់បានជាមីងមករកនាងណា៎

- រតនៈក៏នឹកមីងដែរ ។ យប់មិញ រតនៈបានយល់សប្តិឃើញមីងណា៎ក ។ ឥឡូវមីងមកមែន

- អ៊ីចឹងឬ? ។ មីងអាចចូលផ្ទះរតនៈបានទេ?

- បាទ! បានមីង

ថាហើយ កុមារតូចក៏ទាញដៃសូភាពចូលក្នុងផ្ទះទាំងរំណរ ។

- មីងដឹងថា ប៉ាប៉ារបស់ក្មួយបានហាមប្រាមមិនអោយនាងបើកទ្វារអោយអ្នកណាទេ ។ ក្មួយបានធ្វើខុសបណ្តាំប៉ាប៉ាហើយ ។ បើប៉ាប៉ាដឹង គាត់ច្បាស់ជាវាយក្មួយមិនខាន ។ ក្មួយមិនខ្លាចត្រូវរំពាត់ទេ?

- បាទ ខ្លាចណាស់ តែបើក្រៅពីមីង រតនៈអត់បើកទ្វារអោយទេ ។ ប៉ាប៉ាក៏អត់ដឹងថារតនៈបើកទ្វារអោយមីងឯណា ។

- រតនៈ តើប៉ាប៉ាក្មួយត្រឡប់មកវិញម៉ោងប៉ុន្មានដែរ?

- បាទ! ប៉ាប៉ាថាម៉ោង ៧ យប់
- ម៉ោង ៧ យប់?

រតនៈក៏ចាប់ទាញដៃសូភាពអោយដើរតាមវាទៅកាន់បន្ទប់ដំណេករបស់វ៉ាតាវានិងវា ថែមទាំងចេះស្រដីថា៖

- នេះបន្ទប់រតនៈជាមួយប៉ាប៉ា បន្ទប់នេះរាយណាស់មែនទេមីង?
- មែនហើយ! ចាំមីងជួយរៀបចំអោយមានសណ្តាប់ធ្នាប់ឡើងវិញណាំ
- ចាំរតនៈជួយរៀបមីងដែរណាំ
- អញ្ចឹងក៏បាន ។

ថារួចវាក៏ស្ទុះជួយទាញភួយ ទាញកំរាលពូករៀបតម្រឹមជាមួយសូភាពយ៉ាងស្វាហាប់គួរ អោយខ្នាញ់ជាពន់ ពេក ។ សូភាពលប់មុខ លប់មាត់ប្ដូរសំលៀកបំពាក់អោយរតនៈស្អាតបាតហើយ នាងសូភាពក៏បន្តការរៀបចំប្ដោសសំរាតពីបន្ទប់មួយទៅបន្ទប់មួយអោយមានរបៀបរៀបរយដូចដែលនាងធ្លាប់ធ្វើនៅផ្ទះលោកស្រីផានី ។ មិនតែប៉ុណ្ណោះនាងក៏ឆ្លៀតធ្វើម្ហូបអាហារអោយរតនៈទទួលទាននិងទុកដាក់ជូនឪពុកកុមារនេះថែមទៀតផង ។ នាងធ្វើការបណ្ដើរ នឹកគិតក្នុងចិត្តបណ្ដើរថា៖ "ឱ! ហេតុតែជាផ្ទះដែលគ្មានស្ត្រីមេផ្ទះបានជារាយស្រកាកដូច្នេះ? ។ តើប្រពន្ធគេទៅណាទៅហ្ន៎?" ។ គិតឃើញដូច្នោះភ្លាម សូភាពក៏ហាក់ដូចជាមានកួនចិត្តមួយចង់ដឹងពីរឿងរ៉ាវរបស់លោកជីវ័នណាស់ ។ បើនឹងសួររតនៈ កុមារនេះក៏ប្រហែលជាមិនអាចផ្ដល់ពត៌មានអោយនាងបានដែរ ។ នាងខំរកនឹកឆ្នៃវង្ង់ភក្ត្រលោកជីវ័នសាជាថ្មីឡើងវិញ ត្បិតការឃើញតែម្តងនោះហាក់ដូចជាមិនបានធ្វើអោយនាងចាំបានទាល់តែសោះ មកពីកាលពេលោះ នាងក៏មិនហ៊ានមើលមុខគេចំប៉ុន្មានផង ។

រតនៈបានយករូបថតមួយសំណុំមកបង្ហាញអោយសូភាពមើលលេង ។ គឺជារូបរបស់ប៉ាប៉ាំវាជាមួយនិងវា ។ នាងសូភាពអង្គុយមើលរូបថតលោកជីវ៉នដោយពិនិត្យពិច័យ ។ នាងឃើញទឹកមុខគេស្លូតបូត ភ្នែកស្រទន់ ហើយស្រស់ ប៉ុន្តែហាក់ដូចជាលាតត្រដាងពីស្នាមទុក្ខអ្វីមួយដាមជាប់ក្នុងកែវភ្នែកដ៏មានស្នេហ៍នោះ ញ៉ាំងអោយសូភាពញាប់ញ័រក្នុងដួងចិត្តកាលបើនាងខំមើលរូបថតគេម្តងៗ ។ មាណវិនីកថា មុខមាត់បែបនេះមិនសមជាមនុស្សដែលមានអាកប្បកិរិយាព្រងើយកន្តើយដូច្នេះសោះ ។ គឺជាមនុស្សម្នាក់សោះអង្គើយមិនខ្វីរវីរវល់និងខ្វះការរាក់ទាក់គួរសមជាមួយនឹងស្ត្រីភេទថែមទៀតផង ។ គិតទៅ លក្ខណៈរបស់មនុស្សមានច្រើនបែបច្រើនយ៉ាងណាស់ដែលគេពុំអាចនឹងសំគាល់ ឬ វិនិច្ឆ័យបានភ្លាមៗឡើយ ។

សូភាពកំពុងតែស្លុងក្នុងការពិចារណាគិតពីចរិតលក្ខណៈរបស់លោកជីវ៉នក៏ស្រាប់តែភ្ញាក់ព្រើតកាលបើព្ររតនៈហៅនាង ។

- មីងមកនៅជាមួយរតនៈទៅ

- មីងមិនហ៊ានទេ ខ្លាចប៉ាប៉ារបស់រតនៈណាស់ ។ ប៉ាប៉ារតនៈមិនចូលចិត្តមីងទេណា៎!

- អត់ទេ មីងកុំថាអញ្ចឹង ។ ចាំរតនៈសុំប៉ាប៉ាអោយមីងនៅជាមួយរតនៈណា៎ ។ រតនៈលែងចង់បានម៉ាដាមអានអោយមើលរតនៈទៀតហើយ ។ រតនៈស្រឡាញ់មីងជាង ព្រោះមុខមីងដូចជាមុខម៉ាក់របស់រតនៈអញ្ចឹងណា៎

- ព្រោះតែអញ្ចឹងហើយបានជារតនៈច្រឡំហៅមីងថាម៉ាក់ពីថ្ងៃមុននោះឬ?

- បាទ!

- ក៏ព្រោះតែពាក្យ "ម៉ាក់" មួយម៉ាត់នោះហើយបានជាមីងខំស្កាត់មករករតនៈក្នុងថ្ងៃហ្នឹងណា៎

- អញ្ចឹងមីងកុំទៅណាចោលរតនៈទៀត

- ហ៊ឺ! ចាំមីងគិតបន្តិចសិនណា៎ ។ ណ្ហើយចុះ ជិតដល់ម៉ោងប៉ាប៉ារបស់ក្មួយមកផ្ទះវិញហើយ ។ មីងលារតនៈសិនហើយ ។ ចាំមីងខ្ញុំឧស្សាហ៍មកលេងឮទេ

សូភាពក៏ចាប់រតនៈមកឱបថ្នាប់ប្រាណ ហើយអង្អែលក្បាលកុមារតូចបីដូចជាមាតាបង្កើតម្នាក់ដែលពោរពេញទៅដោយព្រហ្មវិហារធម៌ចំពោះបុត្រសម្លាញ់ ។ នារីឱនថើបថ្ពាលរតនៈមួយខ្សឹត ទើបរួតរះលាចេញទៅដោយខ្លាចលោកជីវ៉ែនមកទាន់ ។

មួយសន្ទុះក្រោយមក គេឃើញលោកជីវ៉ែនត្រឡប់ចូលមកលំនៅដ្ឋានវិញទាំងប្រញាប់ប្រញាល់ ។ លោកស្ទុះចូលទៅក្នុងផ្ទះបាយ ស្រាប់តែឃើញមានចាន ស្លាបព្រា កែវទឹករៀបចំយ៉ាងត្រឹមត្រូវរួចស្រេចមកហើយ ។ លោកក៏លាន់មាត់សរសើរ៖

- ល្អ! កូនប៉ាឥឡូវចេះរៀបតុផង!

- មិនមែនរតនៈរៀបទេប៉ាប៉ា ។

លោកជីវ៉ែនពុំបានឮចម្លើយរបស់រតនៈទេ ។ លោកកំពុងតែគិតថា ពីយប់មិញ លោកដូចជាគ្មានធ្វើម្ហូបទុកទេ ។ ចុះហេតុអ្វីក៏យប់នេះមានម្ហូបពេញឆ្នាំង មើលតែមានគេជប់ដោយសីលមន្តដូច្នេះ? ។ គិតមិនឃើញ ក៏ចេញវាចាប្រាប់កូនថា៖

- ម៉ោះ កុំគិតច្រើន ម្ហូបនៅក្នុងផ្ទះយើងគឺជារបស់យើងហើយ ។ មកញ៉ាំបាយទៅកូន ...

\+

\+ \+

## - ៥ -

នាងសូភាពរមែងតែងតែចូលផ្ទះរតនៈជាប្រក្រតីនៅពេលដែលលោកជីវ៉ែនទៅធ្វើការបាត់ទៅ ។ នាងបានរៀបចំទុកដាក់មើលការខុសត្រូវក្នុងផ្ទះនោះបីដូចជាផ្ទះរបស់នាងពិតៗ ។

គឺអស់រយៈពេលបួនថ្ងៃហើយដែលលោកជីវ៉ែនចេះតែគិតចេះតែឆ្ងល់ ថាតើនរណាគេទៅហ្នឹងដែលមានចិត្តសប្បុរសចំណាយពេលមកជួយធុរៈលោកយ៉ាងដូច្នេះ? ។

ថ្ងៃមួយ ដោយលោកក្អកខ្លាំងពេកមិនអាចនៅធ្វើការបាន ក៏បានសុំគេចេញមកផ្ទះវិញ ។ លុះបើកទ្វារចូលដល់ក្នុងផ្ទះកាលណា លោកក៏បានប្រទះឃើញនាងសូភាពកំពុងតែរ៉ុតខោអាវ ។ ទាំងពីរនាក់ស្រឡាំងកាំងហើយមើលមុខគ្នាទាំងហួសចិត្តវៀងៗខ្លួន ។ ស្ងៀមមួយស្របក់ ទើបលោកជីវ៉ែនផ្ដើមវាចាថា៖

- ឱ! គឺអ្នកស្រីទេឬដែលបានជួយរៀបចំផ្ទះសម្បែងខ្ញុំតាំងពីប៉ុន្មានថ្ងៃនេះមក? ។ ខ្ញុំសូមអរគុណអ្នកស្រីហើយ

- ខ្ញុំសូមទោសលោកចុះ មិនគួរណាខ្ញុំហ៊ានចូលមកលុកលុយក្នុងផ្ទះលោកយ៉ាងនេះទេ

- ទេ! ទេ! មិនមែនជាទោសពៃរ៍អ្វីឡើយ ។ ខ្ញុំទេដែលបានប្រព្រឹត្ត កំហុសមួយទៅលើអ្នកស្រីដែលធ្លាប់បានធ្វើអំពើល្អមកលើកូនខ្ញុំ ។ ណ្ហើយចុះ! សូមអ្នកស្រីឈប់អ៊ុតត្រឹមណេះចុះ ។ ខ្ញុំសូមជូនអ្នកស្រីទៅផ្ទះវិញ

សូភាពដូចជានឹកហួសចិត្តជាពន់ពេកក្រៃ កាលបើឮពាក្យថា "ជូនទៅផ្ទះវិញៗ" ដែល លោក ជីវ៉ន ចូល ចិត្ត ប្រើ ដាក់ នាង នៅ ពេល ដែល ជួប នាង ម្តងៗ ។ នាងគិតថា បុរសនេះដូចជាគ្មានពាក្យអ្វីនិយាយក្រៅពីពាក្យ១ឃ្លានេះសោះ ។ ឱ្យ! ប្រហែលជាគេស្អប់ខ្ពើមរូបនាងខ្លាំងណាស់ហើយ មើលទៅ? ។ គិត ឃើញ ដូច្នោះ ភ្លាម សូភាព ដូច ជា នឹក អន់ ចិត្ត មួយ រំពេច កល្យាណីក៏ឆ្លេាយវាចាចេញមកដោយអចេតនាថា៖

- ខ្ញុំដូចជាមិនយល់ពីលោកសោះ ដែលចូលចិត្តទន្ទេញពាក្យទារ "ជូនខ្ញុំទៅផ្ទះវិញ "មកកាន់ខ្ញុំ ។ ចុះឧបមាបើខ្ញុំជាភ្ញៀវរបស់លោកវិញ តើលោកហាមាត់ដេញភ្ញៀវរបស់លោកដូច្នេះដែរឬ?

លោក ជីវ៉ន ស្តាប់ឮ អស់ ហើយ តែ លោក ធ្វើ ឫក ជា មិន ឮ ទៅ វិញ ។ លោក បែរ ជា ទៅ រៀប សៀវ ភៅ ដែល រាយ ប៉ាយ នៅ លើ តុ វិញ យ៉ាង ព្រងើយ ។

ចំណែកនាងសូភាព ដោយនឹកខ្មាសនឹង អំពើដែលខ្លួនហ៊ានលបចូលមកក្នុង ផ្ទះ គេ ហើយ ដែល ពុំ បាន ទទួល ស្វាគមន៍ ពី ម្ចាស់ ផ្ទះ ដូច្នេះ ក៏ប្រញាប់ប្រញាប់លាចេញទៅ ។ នាងមិនភ្លេចលើកដៃសំពះលាគេហជនដោយបន្លឺពាក្យព្រមជាមួយគ្នាថា៖

- ខ្ញុំសូមលាសិនហើយ
- ឈប់សិនអ្នកស្រី ចាំខ្ញុំជូនឡានទៅ
- អរគុណហើយលោក ។ បើលោកចង់ជូនខ្ញុំទៅ ក៏ជូនពុំដល់ដែរ ព្រោះ

ផ្ទះខ្ញុំស្ថិតនៅឯ "ជើងមេឃ" ឯណោះ (សូភាពឆ្លើយតបទៅលោកជីវ៉ែនទាំងកំបុតកំបុយ)

- អ្នកស្រី! .... ខ្ញុំ ....

- បើលោកមិនយល់ទាស់ទេ សូមឈប់ហៅខ្ញុំថាអ្នកស្រីទៀតទៅ ។ ខ្ញុំពុំមែនជាស្រីមេម៉ាយ ឬធ្លាប់មានប្ដីទេ ... ហៅឈ្មោះខ្ញុំបានហើយ ...

- តើនាងឈ្មោះអ្វីដែរ?

នាងមិនខ្ចីឆ្លើយ ក៏ស្ទុះរឹងសំដៅទៅទ្វារចេញ ។ រតនៈក៏ចេញតាមចាប់តោងរវាររងានាង ហើយស្រែកហៅថា៖

- មីង! មីង!

សូភាពមិនឮពាក្យថាមីង! មីងទេ បែរជាឮថា "ម៉ាក់! ម៉ាក់" ទៅវិញដូចកាលដែលកុមាររតនៈបានហៅនាងគ្រាដំបូង បង្អស់ដូច្នោះឯង ។ សូភាពក៏អង្គុយចុះចាប់ឱបរតនៈដោយពោលពាក្យលួងលោមថា៖

- មីងលារតនៈសិនហើយណាំ

- មីងមិនស្អប់រតនៈទេឬ?

- ទេ! មីងអត់ស្អប់ទេ

- អញ្ជឹងមីងខឹង ...?

- អត់ខឹងទេ!

- មីងមកលេងជាមួយរតនៈទៀតទេ?

- មីងមិនទាន់ដឹងទេ ចាំមើលសិនណាំ ...

វិការដ្ឋាននេះមិនកំបាំងពីខ្សែចក្ខុរបស់លោកជីវ៉ែនទេ ។ ដោយលោកជាមនុស្សគ្មាន មនោសញ្ចេតនា នោះ លោកក៏មិន ជាចាប់ អារម្មណ៍ អ្វី ប៉ុន្មានឡើយ ។ ប៉ុន្តែលោកដូចជាចង់ដឹងដែរ ថាហេតុអ្វីបានជារតនៈកូនប្រុសរបស់

លោកជាប់ចិត្តអ្វីម្លេះនឹងស្រីនេះ រហូតបានសុំលោកអោយយកនាងសូភាពមក នៅជាមួយគ្រាន់នឹងជួយមើលខុសត្រូវឈើរូបវាថែមទៀតផង ។

ម៉ោងទើបតែប្រាំមួយល្ងាចសោះ តែផ្ទៃមេឃងងឹតស្លុប ។ លោកជីវ៉ន នៅសម្ងំក្នុងបន្ទប់ទទួលភ្ញៀវតែម្នាក់ឯង ដោយជក់បារីអស់មួយកញ្ចប់រួចទៅហើយ ។ លោកកំពុងចាប់ហែកកញ្ចប់ទីពីរទៀត ។ តាមធម្មតា លោកពុំដែលជក់ច្រើនម្លឹងៗទេ ។ ជាពិសេស នៅពេលដែលលោកក្អកច្រើនដូច្នេះ ។ វេជ្ជបណ្ឌិតបានហាមលោកមិនអោយពិសាបារីទៀតឡើយ ។ ពេលនេះ លោកទទឹងនឹងបញ្ញត្តិពេទ្យ ... ធ្វើអោយលោករឹតតែក្អកខ្លាំងឡើងៗថែមទៀត ។

ចំណែកនាងសូភាពវិញ នាងមិនបានចេញទៅណាឆ្ងាយពីមុខផ្ទះលោកជីវ៉នទេ ។ ថ្វីបើបុរសនេះ "ទារជូននាងទៅផ្ទះ" ប្រៀបដូចជាបណ្ដេញនាងក៏ដោយ ។ កាលបើនឹកឃើញថា ខ្លួនឯងដូចជារអន់ខ្លាំងពេកនោះ នារីក៏យំ យែកអោយបានធូរទ្រូងម្ដង ។ ជាមួយគ្នានោះ នាងនឹកឃើញរស់ហើយពាក្យដែលលោកស្រីផានីនិយាយជំរាបឪពុកមារបស់ជំនោរថា "នាងមានជប៊ូមហារីក" ។ នឹកឃើញដល់ជប៊ូសាហាវនេះកាលណា សូភាពកាន់តែស្លុតចិត្តឡើងៗ ។ នាងក៏យំទួញរឹតតែច្រើនឡើងថែមទៀត ។

ដោយរាត្រីស្ងាត់ សម្លេងយំអណ្ដឹតអណ្ដក នេះក៏បានចូលទៅកន្ត្រាក់អារម្មណ៍លោកជីវ៉នអោយភ្ញាក់ពីភាពរវើរវាយ... ។ ដោយមានការងឿងឆ្ងល់ លោកក៏បើកទ្វាររើតមើលទៅក្រៅផ្ទះ ក៏ស្រាប់តែប្រទះឃើញនាងសូភាពនៅអង្គុយយំមុខផ្ទះលោក ...

– ពុទ្ធោ!.... រួចចុះហេតុអ្វីបានជានាង ....? ម៉ោះ! អញ្ជើញចូលមកក្នុងផ្ទះខ្ញុំសិន...ណ៎ានាង

ថារួច លោកក៏ចាប់ទាញដៃសូភាពអោយក្រោកឈរឡើង ហើយនាំចូលទៅក្នុងផ្ទះ ។ សូភាពនៅតែយំអណ្ដឺតអណ្ដកមិនទាន់ចាត់នៅឡើយ ។ នាងឱនភក្ត្រចុះ ដោយមិនហ៊ានមើលចំមុខលោកជីវ័នទេ ។ លោកជីវ័នក៏ផ្ដើមនិយាយថា៖

- ខ្ញុំសូមទោសនាងចុះ ដែលបានប្រព្រឹត្តវរំពើឆ្គាំឆ្គងមកលើនាង.... ។ យី! នាងគ្រលុំក្អួយក្រាសយ៉ាងនេះ នាងឈឺទេដឹង? ។ នាងរងាខ្លាំងឬ?

លោកក៏លាដៃទៅស្ទាបថ្ងាសសូភាព ហើយឧទានទាំងភ្ញាក់ផ្អើលថា៖

- មែន! នាងឈឺមែន! ថ្ងាសនាងក្ដៅគគុក ។ ចាំខ្ញុំយកថ្នាំមកអោយនាងលេប....

ថារួចក៏ចូលទៅក្នុងដើម្បីយកថ្នាំមកជូនភ្ញៀវស្រី ។ សូភាពមិនហ៊ានប្រកែក ក៏លេបថ្នាំបំពេញចិត្តម្ចាស់ផ្ទះ ។ លោកជីវ័នក៏បន្តការសន្ទនាជាថ្មីទៀត ។

- ខ្ញុំនឹកថា ប្រហែលជាឪពុកម្ដាយនាងខឹងនឹងនាងមិនតិចទេ ដែលនាងបានមកធ្វើការក្នុងផ្ទះខ្ញុំដោយឥតបានកំរៃដូច្នេះ?

- ខ្ញុំគ្មានឪពុកម្ដាយទេលោក

- ចុះនាងនៅជាមួយអ្នកណាដែរសព្វថ្ងៃនេះ?

- ខ្ញុំជាមនុស្សឥតផ្ទះសម្បែង ដាច់សង្វែងឥតទីពឹងពំនាក់ទេ ...

- បានសេចក្ដីថា.... ឱ! ព្រះអើយ! បើខ្ញុំដឹងតាំងពីគ្រានោះមក

- បើលោកដឹងពីគ្រានោះមក លោករឹតតែមិនហ៊ានទាក់ទងជាមួយខ្ញុំដែលជាមនុស្សខ្វាត់ព្រាត់ មែនទេលោក?

- មិនមែនទេ នាងវិនិច្ឆ័យខ្ញុំខុសស្រឡះ ។ យប់ជ្រៅណាស់ហើយ នាងឈឺផងច្បាស់ជាអស់កម្លាំងខ្លាំងណាស់ ។ ខ្ញុំសូមទុកបន្ទប់ខ្ញុំជូននាងសំរាន្តចុះ ។

មានប្រសាសន៍រួច លោកក៏នាំនាងចូលទៅខាងក្នុង ។ រួចចាប់បីកូនប្រុសលោកចេញបម្រុងយកទៅអោយទទួលទានដំណេកជាមួយលោកនៅក្នុងបន្ទប់ទទួលភ្ញៀវវិញ តែត្រូវសូភាពឃាត់ថា៖

- មិនអីទេ សូមលោកទុកអោយរតនៈគេងនៅទីនេះចុះ

.................................................................................................

ព្រះសុរិយានាសិរសរដូវបានចោលពន្លឺដ៏ស្រទាប់ស្រទន់ចូលមកក្នុងល្វែងបន្ទប់ទាំងឡាយក្នុងផ្ទះលោកជីវ៉ន ។

លោកជីវ៉នភ្ញាក់ឡើងរៀបចំខ្លួនទៅធ្វើការ ។ លោកត្រូវចូលទៅយកខោអាវពីក្នុងទូរបស់លោកនៅក្នុងបន្ទប់ដែលលោកប្រគល់អោយនាងសូភាពទទួលទានដំណេក ។ លោកដំដើរលបៗព្រោះមិនចង់អោយរំខានដល់ដំណេកនាងក្រមុំដែលកំពុងលក់យ៉ាងស្កប់ស្កល់ ។ លោកឃើញនាងសូភាពគេងឱបរតនៈកូនកំសត់តែមួយរបស់លោកហាក់បីដូចជាមាតាម្នាក់ឱបបុត្របង្កើតរបស់ខ្លួនដូច្នោះ ។ លោកក៏មានអារម្មណ៍ចម្លែកមួយមករង្រួនបេះដូងដែករបស់លោកអោយជ្រួលច្របល់ញាប់ញ័ររន្ធត់យ៉ាងអាថ៌កំបាំង ។ ពុំដឹងជាមានអ្វីមកជម្រុញជំហានលោកអោយដើរទៅរកគ្រែនាងសូភាពទៅវិញ ។ លោកក៏បានមកឈរគយគន់ភក្ត្រនាងដោយមានមនោសញ្ចេតនាប្លែក ព្រមទាំងលូកដៃទៅស្ទាបថ្ពាលសកល្យាណីយ៉ាងថ្មើៗដោយមិនដឹងខ្លួនផង ។

សូភាពភ្ញាក់ពីដំណេក ហើយស្ទុះងើបអង្គុយភ្លែត ទាញភួយមកបិទបាំងខ្លួន ព្រមទាំងបញ្ចេញសូរសៀង ដោយភ័យខ្លាចថា៖

- លោកមកដាស់ខ្ញុំ ដើម្បីជូនខ្ញុំទៅផ្ទះវិញឬ?

- ទេ! ទេ! ខ្ញុំ ...

- លោកទើសទាល់ខ្លាំងណាស់មែនទេ ក្នុងការទទួលមនុស្សដូចយ៉ាងរូបខ្ញុំ?

- មិនមែនអញ្ចឹងទេនាង ។ ផ្ទុយទៅវិញ ខ្ញុំចង់ឃាត់នាងថា កុំអោយនាងទៅណាទៀត សូមនាងទុកផ្ទះខ្ញុំដូចជាផ្ទះរបស់នាងចុះ ។ តើបានទេនាង? បានទេនាង?

សូភាពហួសពីគ្រេកអរណាស់ទៅហើយ គ្រាន់តែនាងមិនឆ្លើយតបថាអ្វីទាំងអស់តែប៉ុណ្ណោះ ។ ដើម្បីបន្ធូរការខ្មាសអៀន នាងបែរជាងើបចុះចាកគ្រែ ហើយដើរទៅផ្ទះបាយដាំទឹកឆុងកាហ្វេជូនលោកជីវ៉ែនទៅវិញ ។ រួចហើយនាងក៏លើកយកមកជូនលោកជីវ៉ែនដល់បន្ទប់ទទួលភ្ញៀវ ធ្វើអោយលោកជីវ៉ែនឈាន់មាត់ថា៖

- ឃើ! សូមនាងកុំបំរើខ្ញុំអី ។ ខ្ញុំប្រុងទៅឆុងញ៉ាំខ្លួនឯងទេតើ!
- ឱ! តើលោកខ្លាចខ្ញុំទំរើសលោកអោយខូចទម្លាប់ល្អរបស់លោកឬ?

លោកជីវ៉ែនហួសចិត្តនឹងសំដីនាងសូភាព ក៏សើចយ៉ាងក្អាកក្អាយ ។

+

+ +

# - ៦ -

សិសិររដូវក៏កន្លងផុតទៅហើយ រដូវផ្ការីកក៏មកដល់ដែរ ។ ចិត្តដ៏ក្រៀមក្រោះ ស្វិតស្រពោន... ជីវិតដែលធ្លាប់តែរវើរវាយត្រសែតគ្មានគោលដៅ រឿងដែលខ្មៅងងឹតងិតងាមជាប់ក្នុងបេះដូងកំព្រារបស់សូភាពក៏ប្រែក្លាយទៅជាពណ៌ស៊ីជំពូ រីកស្រស់ថ្លាបីដូចជាសន្លឹករុក្ខជាតិនានាដែលខំលូតលាស់បញ្ចេញត្រួយខ្ចីល្អក់ ឬបីដូចជាបុប្ផគ្រប់បែបយ៉ាងដែលកំពុងរីកបញ្ចេញលំអរបង្អួតគ្នាពេញទីសួនច្បារ និងនៅក្នុងស្មៅភ្នំនានាទាំងឡាយដែរ ។

លោកជីវ័នបាននាំនាងសូភាពនិងរតនៈទៅដើរកំសាន្តទៅលេងភ្នំ ទឹកកកដែលជាកន្លែងមួយសំរាប់ធ្វើកីឡារំកិលទឹកកក (Ski) នារដូវរងា ។

ជីវិតទាំងបីខំដកដង្ហើមស្រូបយកខ្យល់ល្អបរិសុទ្ធដាក់ពេញសួត ។ គេឃើញនាងសូភាពសប្បាយរីករាយជាងគេបង្អស់ ដោយសារតែនាងទើបនឹងរកបង្អែកជីវិតបាន ។ នាងនឹកឃើញទៅដល់បទ "បុប្ផាជូឡុង" ដែលច្រៀងដោយនាងហួយមាសត្រង់ឃ្លាទីពីរដែលមានសេចក្ដីថា "ស្នេហ៍ស្បើយចំណាស់ចេះផ្ទាក់ថ្នមចិត្ត ជួបម្ចាស់ជីវិតរាណពិតដល់ខ្ញុំ ក្រោមផ្ទៃមេឃានាពេលស្រទុំ ម្លប់ឈើធំៗស្លុតស្លុងកាមា" ហើយនាងក៏ច្រៀងលេងរហ៊ុមៗយ៉ាងសប្បាយរកអ្វីប្រដូចមិនបាន ។

រតនៈរត់ទៅលេងឆ្ងាយពីបិតានាងសូភាព ដូចជាទុកឱកាសនេះអោយអ្នកទាំងពីរឱ្យបរិតប្រកៀកប្រកើយគ្នាទៅតាមចំណង់តណ្ហានៃសត្វលោក ។

សេចក្ដីស្នេហានាកណ្ដាលធម្មជាតិដ៏ស្រស់បំព្រង នេះញ៉ាំងអោយចិត្តនៃលោកជីវ័ននិងនាងសូភាពភ្លើតភ្លើនឥតព្រំដែន ។ លោកគេងកើយភ្លៅនាងស្ដាប់នាងនិយាយរៀបរាប់ពីខ្សែជីវិតផ្សងព្រេងរបស់នាងអោយគេស្ដាប់ ។ លោកទាញដៃសង្សារមកដាក់លើទ្រូង ហើយអង្អែលថើបដោយក្ដីស្រឡាញ់និងក្ដីករុណាឥតព្រំដែន ។

រតនៈបេះបានផ្កាព្រៃមួយបាច់ធំ ហើយរត់មករកជីវិតទាំងពីរដោយរំណរ ។ គេស្ទុះងើបឡើងអង្គុយទន្ទឹមគ្នាទាំងទឹកមុខញញឹមពព្រាយ ។

–ប៉ា! ម៉ាក់! នេះផ្កាដែលរតនៈបេះពីក្នុងស្មៅមក

និយាយរួច រតនៈហុចផ្កាទៅ លោកជីវ័នលូកដៃស្ដាំ នាងសូភាពលូកដៃឆ្វេងទៅទទួលបាច់ផ្កាព្រមគ្នា ធ្វើអោយរតនៈសប្បាយរីករាយលោតទះដៃរប្រាវៗ រួចអង្គុយចុះឱបអ្នកទាំងពីរទាំងក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ ។ យល់ដល់ចិត្តបិតារបស់គេៗក៏រត់ទៅលេងឆ្ងាយពីទីនោះទៀតទៅ ។

សូភាពសែនរំភើបជាពន្លឹកកាលបើឮពាក្យដែលរតនៈហៅនាងថា "ម៉ាក់" ។ នាងក៏សួរលោកជីវ័នដោយងឿងឆ្ងល់ថា :

–តើបងឬដែលបង្គាប់រតនៈអោយហៅខ្ញុំថា "ម៉ាក់" នោះ ?

–ទេ! បងមិនបានបង្គាប់វាទេ ។ រតនៈស្រឡាញ់ចូលចិត្តអូនតាំងពីដើមមក ប្រហែលមកពីសេចក្ដីស្រឡាញ់នេះហើយដែលបណ្ដាលអោយវាចេះហៅអូនថា "ម៉ាក់" ដោយចិត្តវាណា៎

កូននេះចេះណាស់! ។ និស្ស័យជាមួយរតនៈនេះហើយដែលបានផ្សារភ្ជាប់វាសនាអូននិងបងណា៎

– ឱ! សូភាពមាសបងអើយ! បងអរគុណវាសនាណាស់ដែលនាំអោយយើងបានជួបគ្នា

– បងសម្លាញ់! គឺអូនទេដែលត្រូវអរគុណព្រហ្មលិខិតដែលបានកំរិតវាសនាអូនអោយមកជួបបង ហើយបានរួបបងអាណិតដល់ជីវិតដ៏ឥតខ្លឹមសាររបស់អូននោះណា៎ ...

– ម្ចាស់ចិត្តបងអើយ!

– បង ជីវ៉ន ម្ចាស់ ជីវិត អូន អើយ! សូម បង អាណិត អូន អោយ ច្រើន ហើយសូមបងជួយបណ្តុះបណ្តាលប្រាជ្ញាស្មារតីអូនអោយបានក្លាយជាមនុស្សគ្រាន់បើម្នាក់នឹងគេផងណា៎បង ។

– កុំព្រួយ អោយ សោះ អូន សម្លាញ់! បង នឹង ខិតខំ យ៉ាងណា អោយសូភាពរបស់បងក្លាយជាស្រីខ្មែរម្នាក់ដ៏មានខ្លឹមសារក្នុងសង្គម...

– អរគុណបងណាស់! ។ អូនស្តាយណាស់ ដោយសារឪពុកម្តាយអូនក្រីក្របានជាពុំអាចអោយអូនបានរៀនសូត្រនឹងគេ ។ អូនល្ងង់ណាស់បង ។ អូនឥតចេះអ្វីទេ ។

– មិនទាន់ហួសពេលទេអូន កាលណា បើយើងមានបំណងអ្វីមួយច្បាស់លាស់នោះ យើងនឹងបានសំរេច ជាមិនខាន ដូចសុភាសិតបារាំងមួយចែងថា "បើយើងចង់ គឺយើងអាចធ្វើបាន" ។

– អូនគ្មានប្រាថ្នាអ្វីក្រៅពីចង់ចេះអាន ចង់ចេះសរសេរអក្សរជាតិយើងអោយបានភ្លិនច្បាស់លាស់ អោយបានសក្តិសមជាកូនខ្មែរម្នាក់ កុំអោយគេដៀលថា អូនជាខ្មែរ មិនចេះអក្សរឯងនោះ

– ប្រសើរណាស់អូន គួរណាស់តែយើងនាំគ្នាលើកស្ទួយភាសាជាតិយើងដោយខិតខំសប្រួចរៀងរាល់ថ្ងៃ ។ ភាសាដែលយើងទាំងអស់គ្នាចេះស្រោប់ពី

យប់មួយ នៅពេលដែលរតនៈចូលនិទ្រា បាត់ទៅ គឺបន្ទាប់ពីរៀនចប់ សូភាពក៏សាកសួរទៅប្រុសសម្លាញ់ថា :

-បងហត់ទេ ?

-ហត់ដែរ

លោកជីវ៉ែនឆ្លើយផងសើចផង ។ សូភាពនឹកថា សង្សារនាងមាយាក៏និយាយថា :

-មាយាណាស់លោកគ្រូខ្ញុំ! ។ កូនសិស្សគេមិនមាត់ផង លោកគ្រូជាប្រុសហត់អី!

- មិនអោយបងមាយាម្តេចបាន បើកូនសិស្សរបស់បងស្រស់ម្លឹងៗនោះ ។

- អញ្ចឹង បងឯងស្រឡាញ់ព្រោះតែយល់ថា ខ្ញុំស្រស់ហ្នឹងឬ? ។ បងឯងចេះតែថាហើយ ខ្ញុំគ្មានស្រស់អីខ្ញុំទេ ។ ឱ! បើបងស្រឡាញ់តែសំបកក្រៅយ៉ាងហ្នឹង ។ បើថ្ងៃណាមួយសំបករូបហ្នឹងបាក់បែកកំពិតកំពីវដោយសារគ្រោះថ្នាក់អ្វីមួយទៅ បងឯងច្បាស់ជារត់ចោលខ្ញុំហើយមើលទៅ

- កុំនិយាយអោយបងអញ្ចឹងនោះ បងស្រឡាញ់ចិត្តអូនទេ ។ ម៉ោះ! ....

- ស្លៀកពាក់ទៅ បងជូនអូន "ទៅផ្ទះវិញ" អញ្ចឹងឬ? ។ ម៉េចក៏មិនដេញអូនទៀតទៅ បងសម្លាញ់?

- ឃើញទេ តាំងរំឭកពីរឿងចាស់ទៀតហើយ ។ នេះច្បាស់ជានៅគុំគួននឹងស៊ីបងហើយមើលទៅ?

- អូនអត់គុំទេ តែខួរក្បាលអូន វាដូចជាប្រដាប់ថតរូបអញ្ចឹង ។ ស្អីៗក៏ដោយអោយតែឃើញហើយ គឺផ្តិតជាប់ឥតងាយរលប់ទៅវិញទេ ។ មើលលោកគ្រូ ត្រូវការអីប្រាប់មកខ្ញុំចុះ

- បងត្រូវការ ...អី! ...ត្រូវការមួយ ...

- កាហ្វេមួយពែងឬ?
- យី! អោយបងញ៉ាំកាហ្វេយប់ ដូចអោយញ៉ាំថ្នាំរក់ងងុយអញ្ចឹង ។ បងគេងម៉េចលក់ ចិត្តបានមែនអូនឯងនេះ
- រួចចុះបងត្រូវការអ្វី? សូមអញ្ជើញបញ្ជាមកលោកធំ
- បងត្រូវការ ... ត្រូវការសុំថើបអូនឯងមួយខ្សឹត

ថាហើយ លោកក៏លោប្រមុះទៅជម្ពិតថ្ពាល់ស្រីស្នេហ៍ភ្លាម ។ សូភាពខំគេច ហើយបន្ទោសថា៖

- យី! ចំជាផ្តេសផ្តាសមែន! ។ ពេលកំពុងរៀនសូត្រ អ្នកណាគេអោយធ្វើអញ្ចឹងនោះ
- ចុះ បង មាន ញ៉ាំ ប្រាក់ ខែ គ្រូ បង្រៀន ឯណា? ម៉េចក៏ធ្វើ ផ្តេស ផ្តាស មិនបាន ។ បើខឹងណាស់ ថើបបងវិញទៅវារួចគ្នាទៅហើយ

សូភាពហួសពីគិត ដោយនិយាយមិនឈ្នះគេ ។ នាងសម្លក់លោកជីវ៉នបែបយ៉ាងខ្នាញ់មួយក៏ងើបដើរកាន់សៀវភៅចេញពីបន្ទប់សាឡុងទៅ ។ លោកជីវ៉នដើរតាមពីក្រោយលូកដៃឱបនាងជាប់ ។ សូភាពជ្រុះសៀវភៅពីដៃខ្ទោក ហើយក៏ប្រវ៉ាឱបកលោកជីវ៉នវិញទាំងរំភើបញ្ញាប់ញ័រ និងស្រើបស្រាល ...

- បងទៅគេងមុនចុះ អូនមិនទាន់ងងុយគេងទេ ចាំអូនទៅក្រោយណា៎

លោកជីវ៉នពុំបានចាប់ភ្លឹកអ្វីទេ ក៏ដើរចូលបន្ទប់ដំណេកមុនទៅ ។

មួយ ស្របក់ ក្រោយ មក នាង សូភាព ក៏ដើរ ចូល ទៅ ក្នុង បន្ទប់ ។ នាងឃើញលោកជីវ៉នសំរាន្តលក់ស្រមុកខរៗបាត់ទៅហើយ ។ ស្រស់ស្រីក៏ចេញមកអង្គុយក្នុងបន្ទប់ទទួលភ្ញៀវវិញ ។ នាងនឹកថា បើលោកជីវ៉នស្រឡាញ់រូបនាងម្ល៉ឹងៗ ម្តេចក៏គេពុំដែលនិយាយពាក្យ "សុំរៀបការ" ជាមួយនាងម្តងណា

សោះ? ។ ឬមួយក៏មកពីរូបនាងច្បាស់បង់រស់តម្លៃជានារីក្រមុំ ដោយសារនាងមកនៅជាមួយគេ ហើយបានប្រគល់រូបកាយអោយគេប៉ះពាល់ខ្ទេចខ្ទីរស់ទៅហើយ? ។ គិតពីរឿងរៀបការកាលណា នាងក៏នឹកព្រួយទៅដល់ជំនោរ ។ ជំនោរមិនស្គាល់នាងប៉ុន្មានសោះ តែគេតាមដណ្តឹងរូបនាង ។ ប៉ុន្តែ នាងបែរជាប្រកែកហើយរត់ចេញពីផ្ទះលោកស្រីផានីទៅវិញ ដោយសារនាងគេចចេញពីជំនោរ ត្បិតខ្លួនមានជម្ងឺមហារីកនោះ ។

ជម្ងឺមហារីក! "ជម្ងឺមហារីក!" គួរអោយភ័យតក់ស្លុតណាស់ ។ នឹកដល់ខ្លួនមានជម្ងឺធ្ងន់ សូភាពឈឺក្បាលណាស់ ។ សូភាពដណ្តឹងសួរខ្លួនឯងថាតើខ្លួនមានជម្ងឺនេះមែនឬ? ។ ទេ! ដូចជាមិនជឿទេ ព្រោះខ្លួនពុំដែលឈឺអ្វីក្រៅពី គ្រុនក្តៅបន្តិចបន្តួចប៉ុណ្ណោះ.... ។ ចុះបើខ្លួនឈឺមែន? តើហេតុអ្វីក៏ខ្លួនប្រាថ្នាចង់រៀបការជាមួយលោកជីវីន? ។ គិតចុះ គិតឡើង វិលវល់ច្របូកច្របល់ពុំដឹងជាយកប្រធានណាមួយមកពិចារណាសោះ ។ ម្ល៉ោះហើយអារម្មណ៍នាងកករល្អក់វិលក្បុង ធ្វើអោយក្បាលនាងណែនជាពន់ពេក ។

វិពេចនោះ ស្រីឃើញរូបជំនោរលេចភ្លែតចំពោះមុខនាង ហើយនិយាយចំអកដាក់នាងថា៖

- "សូភាព បងខំតាមស្រឡាញ់រូបអូន ។ បងស្រឡាញ់ជារបៀបខ្មែរ គឺគោរពកាយអូន ហើយដណ្តឹងអូនរៀបការពេញច្បាប់ តែអូនដាច់មេត្តារត់ចោលបងទុកអោយបងវេទនាផ្លូវចិត្តរហូតដល់សព្វថ្ងៃ ។ មិនតែប៉ុណ្ណោះ អូនមករួមរស់ជាមួយបុរសថ្មីដែលគេមិនដែលទាំងស្រដីថាសុំរៀបការជាមួយរូបអូនសោះ ។ ឯណាទៅ លក្ខណៈជាស្រីក្រមុំខ្មែរ? ...

នាងពុំចង់ឮ ពុំចង់ឃើញរូបជំនោទេ ។ នាងខំគេចមុខចេញពីអ្នកម្លោះ ក៏ស្រាប់តែនាងឃើញរូបនាងបែងភាគជាប្អូនប្រាំ ហើយស្តីបន្ទោស

នាងថា "ជំនោរនិយាយត្រូវណាស់ ។ នាងខុសហើយ! លោកជីវ័នគេរក់ស្រឡាញ់នាងស្មោះទេ! " ។ រូប១ទៀតនៅខាងស្ដាំបន្ថែមថា "នាងបានដើរជាន់គន្លងប្រពៃណីខ្មែរ ... ចូរនាងកុំភ្លេចថា នាងជានារីខ្មែរណាំសូភាព! ក្រមុំខ្មែរ! ... តម្លៃនៃក្រមុំ គឺស្ថិតនៅលើភាពបរិសុទ្ធ ។ នាងបានបន្ថោកតម្លៃនារីរបស់នាងងាយណាស់! ... ឃើញទេ ជីវ័នគេទុកនាងត្រឹមជាគូកំណាន់ ។ គេមិនដែលសុំនាងរៀបការជាភរិយាពេញច្បាប់ទេ! ដឹងខ្លួនច្បាស់ឬនៅសូភាព?! "

សូភាពបិទភ្នែក បិទត្រចៀក ហើយរង្វរសម្លេងសតិសម្បជញ្ញៈថា "សូមមេត្តាកុំតិះដៀលខ្ញុំពេក ។ ខ្ញុំបានជាខុសហួសទៅហើយ ... " ។

ទោះជាយ៉ាងណាក្ដីក៏ជីវ័ននិងសូភាពចេះយល់ចិត្តថ្លើមគ្នា ចេះស្រឡាញ់ថ្នាក់ថ្នម គោរពខ្លាចចិត្តគ្នាទៅវិញទៅមកសឹងតែរកគូស្នេហាឯណាមកប្រដូចអោយស្មើពុំបានឡើយ ។ គួរអោយកត់សំគាល់ថា តាំងពីនាងសូភាពមករួមរស់ជាមួយកាលណាមក លោកជីវ័នមានចិត្តប្លែកជាងពីមុនច្រើនណាស់ ។ ពេលចប់ការងារម្ដងៗ លោកប្រញាប់រូតរះវិលមកលំនៅដ្ឋានដោយត្រេកត្រអាលចង់ជួបមុខស្រីស្នេហ៍ និងបុត្រសម្លាញ់ ។ លោកយល់ថា ក្នុងគេហដ្ឋានរបស់លោកសព្វថ្ងៃ គ្មានខ្វះអ្វីដូចមុនទៀតទេ ។

រៀងរាល់ពេលបរិភោគ ជីវិតទាំងបីជជែកគ្នាសប្បាយក្អាកក្អាយណាស់ ។ ចំពោះអ្នកផងទាំងពួងដែលមិនបានដឹងពីអាថ៌កំបាំងរបស់លោកជីវ័ននិងនាងសូភាព គេមុខជាកោតសរសើរ ថា ចំជាគ្រួសារមួយដ៏ល្អពោរពេញទៅដោយសុភមង្គលដ៏ត្រចះត្រចង់ពិតៗ ។

ដោយការគិតហួសប្រមាណនាំអោយវិប្បដិសារីជេរស្ដីនាងក្នុងរាត្រីដែលកន្លងទៅ ថ្ងៃនេះ នាងសូភាពមានទឹកមុខស្រពាប់ស្រពោនខុសប្រក្រតី ។

តាំងពីគេទាំងពីររួមរស់ជាមួយគ្នាមក ជីវ័នកម្រឃើញមុខស្រៀមក្រំរបស់សង្សារណាស់ ។ ក្លាយបើឃើញស្រីសម្លាញ់ប្រែទឹកមុខប្លែកខុសពីទម្លាប់ដូច្នេះ បុរសក៏ប្រញាប់សាកសួរដោយវាចាផ្អែមល្ហែមថា៖

- ម៉េចបានជាមុខអូនស្រៀមម្ល៉េះ? នរណាធ្វើអោយអូនខឹងឬ? ប្រហែលជាវាតនះហើយដែលរុកគួនអូននាំអោយអូនធុញទ្រាន់នោះ?

មានប្រសាសន៍រួច លោកក៏លូកហត្ថាទៅបបោសអង្អែលនារីសំណព្វចិត្តយ៉ាងថ្នាក់ថ្នម ... ។ លោកចាប់កេសីស្រីមកដាក់ផ្ទាប់ទ្រូង ។ សូភាពសម្ងំស្ងៀមឈឺខ្ទោភាប្រុសស្នេហ៍ឥតស្រដីថាអ្វីទាំងអស់ ។ នាងគ្រាន់តែនឹកគិតក្នុងចិត្តថា "តើធ្វើដូចម្តេចទៅហ្ន៎ អោយបងជីវ័នរបស់នាងយល់ដល់ជម្រៅនិងសេចក្តីប្រាថ្នារបស់ភាពនោះ? ។ ភាពចង់សួរបងដែរ តែភាពខ្មាស ពុំអាចហាមាត់ថ្លែងសួរបងបានទេ ។ ល្ហើយចុះ! ភាពត្រូវតែទ្រាំរង់ចាំ រង់ចាំបន្តិចទៀតចុះ រង់ចាំអោយបងថ្លែងដោយខ្លួនឯង ។ បើបងពិតជាស្នេហ៍រូបភាពពិតប្រាកដមែន" ។

- បងដឹងថា អូនមានអាថ៌កំបាំងអ្វីមួយជាមិនខាន ។ ចូរកុំលាក់បងអីភាពអូន ប្រាប់មកចុះ កុំខ្លាចញញើតចិត្តបងធ្វើអ្វីណាំអូនណាំ ។

ដល់ព្រះគេជជីកសួរនាងពេក ស្រស់វរលក្ខណ៍ក៏ងាកភក្ត្រមកសម្លឹងមុខប្រុសកំណាន់ ហើយពោលឡើងថា៖

- អូនគ្មានរឿងអ្វីទេ ក្រៅពីចង់ដឹងថា តើបងស្រឡាញ់អូនឬទេ?

- ពុទ្ធោអើយ! ម៉េចក៏បានជាសួរបងអញ្ចឹង? តើមាននរណាគេនិយាយអាក្រក់ពីបងឬ? (សួររួច គេក៏ថើបកេសាស្រីថ្មើៗ) ។

សូភាពខំញញឹម ហើយតបវិញថា៖

- បងអៀសខ្លួនឬ? ។ ហ្នឹងច្បាស់ជាមាននាយមានអាយឯណាទៀតហើយ?

ជីវ័នប្រវាឱបស្រីយ៉ាងណែន ហើយនិយាយដោយស្មោះរស់ពីដួងចិត្តថា៖

- ជាច្រើនឆ្នាំកន្លងមកហើយ បងពុំដែលមានចិត្តប៉ងប្រាថ្នាលើនារីណាម្នាក់សោះ ។ ទើបតែពេលថ្មីៗនេះ បេះដូងបងរំភើបញាប់ញ័រស្រឡាញ់ពេញចិត្តអូនភាពរបស់បងដោយរស់រវីពីថ្លើមប្រមាត់ ។ ប៉ុន្តែ បង ....

និយាយមកដល់ត្រឹមណេះ លោកជីវ័នក៏ហាក់ដូចជានឹកឃើញដល់រឿងអ្វីមួយដែលញាំងរោយដួងចិត្តស្រយុត ហើយតានតឹងមួយរំពេច ។ លោកងាកមើលឆ្វេងស្តាំ រួចក៏ស្រដីសួរថា៖

- រតនៈទៅណាហើយអូន?

- រតនៈចូលគេងហើយបង

- គួររោយរាណិតរតនៈណាស់ វាសនាវាពុំដឹងជាប្រែក្លាយទៅដូចម្តេចទេបើរត់ពីបងទៅ?

- តើបងចង់ទៅណាចោលអូន និងរតនៈឬ?

- បើបងនៅរស់ បងសូមស្បថសច្ចាថា បងមិនទៅណាចោលអូនទេ.. ។ តើអូនស្រឡាញ់រតនៈទេអូន?

- យី! ម៉េចក៏បងសួរអូនអញ្ចឹង? ។ កូនរបស់បង ក៏ដូចជាកូនរបស់អូនដែរ ។ តើអូនមានអាកប្បកិរិយាណាមួយដែលបង្ហាញថា អូនមិនស្រឡាញ់រតនៈឬបង?

- ទេ អត់ទេ! បងសួរដូច្នេះ ក៏មកពីបងគិតច្រើនពេកទេ! ....

ដើម្បីកុំរោយស្រីស្នេហ៍កើតក្តីសង្ស័យបាន ជីវ័នក៏នាំបន្ទប់និយាយពីរឿងផ្សេងៗទៅវិញ ។ ភ្លាមនោះ ជីវ័នក៏ចាប់ក្អកស្ទើរតែស្ទះដង្ហើម ។ សូភាពភ័យណាស់ ខំរីតទ្រូងប្រុសកល្យាណទាំងក្តីស្រឡាញ់ លាយនិងក្តីករុណាឥតព្រំដែន ។

+

+ +

## - ៧ -

សូភាពមានក្តីងឿងឆ្ងល់យ៉ាងខ្លាំង កាលបើឃើញប្រុសសង្សារត្រឡប់ចូលមកផ្ទះវិញមុនម៉ោងធម្មតា ។

រាល់ដង ជីវិនតែងញញឹមញញែមដាក់ស្រីស្នេហ៍របស់គេ ។ ប៉ុន្តែថ្ងៃនេះ គេមានទឹកមុខស្លេកស្លាំង ដំណើរធេងធោង ។ សូភាពឃើញដូច្នោះ ក៏ស្ទុះទៅជួយគ្រាហ៍ប្រុសស្នេហ៍យកទៅដាក់លើគ្រែ ។ នៅលើពូក ជីវិនក្អកយ៉ាងរន្ថើនញ៉ាំងអោយគេរស់កម្លាំងល្ហិតល្ហៃ ។ សូភាពភិតភ័យប្រាសប្រាលនៅមិនសុខសល់សោះ ។ នាងនៅអង្គុយជិតសង្សារ ជួយរឹតដើមទ្រូងទាំងតក្កមា ។

- មិនស្រួលទេបង! ត្រូវតែហៅពេទ្យមក កុំទុកយូរអី

- ជម្ងឺបងជាជម្ងឺដែលមើលពុំជាទេ ... ភាពអូនអើយ! តើអូនដឹងទេ ថាបងឈឺអី? (ជីវិនខំប្រឹងនិយាយទាំងហត់គឃ្លូ) ។

- អូនដឹងហើយ

- ហេតុអីក៏អូនដឹង?

- អូនឃើញបងពិសាថ្នាំច្រើនពេក អូនក៏បានយកប្រអប់ថ្នាំទៅសួរឱសថ

ការី ។ គេប្រាប់អូនរស់ហើយ ។ ទោះយ៉ាងណាអូននៅតែមានសង្ឃឹមជានិច្ច ថាពេទ្យនឹងអាចព្យាបាលបងអោយជាបាន ។ គួរតែបងអញ្ជើញទៅសម្រាន្ត ពេទ្យទើបឆាប់ជាណាបង

- ភាព! បងចង់និយាយរឿងមួយ ...

- និយាយទៅបង អូនចាំស្តាប់ ...

- ប្រសិន បើ បង នឹកដល់ សុខ ភាព ដ៏ទន់ ខ្សោយ របស់បង ... បង មិន គួរ ស្រឡាញ់អូនទេ ... ព្រោះបងនឹងធ្វើអោយ អូនកើតទុក្ខដោយសារបងនៅ ក្នុងជាតិនេះ ។ ... ប្រហែលជាភាពយល់ថា ...បងជាបុរសម្នាក់មានបំណង អាក្រក់ប្រាថ្នាបំផ្លាញអនាគតរបស់អូនហើយមើលទៅ ... អូនក៏ប្រហែលជា មិនយល់ពីជំរៅចិត្តបងទេថាបងស្រឡាញ់និងអាណិតអូនប៉ុណ្ណានោះដែរមែន ទេ?

សូភាពអង្គុយស្តាប់វាចារបស់គូស្នេហ៍ទាំងទឹកភ្នែករហាម ។ ជីវ៉ែនក្អកខ្លាំង ឡើងៗធ្វើអោយ គេចង់ស្ទះដើមទ្រូងឬងៗ ។ ជីវ៉ែនក៏ខំបន្តវាចាទាំងរំជើប រំជួលតទៅទៀតថា៖

- តាមពិត បងឈឺយូរហើយ ... តែតាំងពីបងបានជួបអូនមក ... បង ក៏ហាក់ដូចជាភ្លេចការឈឺថ្កាត់អស់រលីង ។ បងស្មានថា ជម្ងឺបង ...បានធូរ ស្បើយ...ទើបបងក៏ប្រហែស... ។ នៅពេលមួយ... ដែលបងគិតថា... បងសុំ រៀបការ...ជាមួយអូន... ។ ពេលនោះហើយ...ដែលជម្ងឺនេះបានរើឡើងជា ថ្មី...មកពីបងខំគិតពេក...គិតពេកទៅ...ក៏នឹកដល់ខ្លួនបងដែលមានជម្ងឺ...ធ្វើ អោយអារម្មណ៍បងវិលវល់...នាំអោយដួងចិត្តបងខ្វាយខ្វល់ពេកណាស់...មិន មែនបងមិនយល់ចិត្តអូនទេ ។ បងដឹងណាស់...ថាភាពកើតទុក្ខដោយសារបង យ៉ាងច្រើន...ដោយសារយើងរួមរស់នៃបនិត្យជាមួយគ្នា...ហើយពុំព្រមរៀប

ការនោះ ។ អូន អើយ! បងពុំគួរយកជីវិតអូនមកប្រឡែងលេង...ដូច្នេះ សោះ... ប្រសិនបើបងស្លាប់ទៅ...តើអូន?

សុភាពឆ្លើយកាត់ភ្លាមថា៖

- អូននឹងក្លាយជាស្រីមេម៉ាយម្នាក់ ។ បងអើយ! ថ្វីបើយើងពុំទាន់រៀបអាពាហ៍ពិពាហ៍... គ្មានកិច្ចសន្យា... គ្មានលក្ខណអ្វីមែន តែអូនជារបស់បង ។ អូនស្រឡាញ់បងដោយស្មោះ ដោយគ្មានអ្នកណាបង្ខិតបង្ខំអូនទេ... ។ ថ្វីបើអូនធ្លាប់កើតទុក្ខព្រោះចង់អោយបងផ្តល់ន័យនៃពាក្យ "ស្វាមី" អោយអូននោះ ហើយថ្វីបើបងពុំទាន់បានឈ្មោះជាស្វាមីរបស់អូនតាមផ្លូវច្បាប់ក៏ពិតមែន តែភាពជាប្រពន្ធរបស់បងតាំងពីយូរមកហើយ... ហើយក៏ជាមាតារបស់រតនៈដែរណា៎...

- តើអូននៅតែស្រឡាញ់រតនៈរហូតតទៅឬ?

- ចា៎ះ ថ្វីបើអូនមិនមែនជាមាតាដែលបង្កើតវាមកមែន ។ ប៉ុន្តែរតនៈជាកូនរបស់បង ។ ដូច្នេះ រតនៈជាកូនរបស់អូនដែរ ។ វាជាកូនរបស់យើងណា៎បង! ។ តើបងជឿទុកចិត្តអូនឬនៅ? ។ ណ្ហើយបង! ចូរបងកុំខំប្រឹងនិយាយច្រើនពេក បងហត់ខ្លាំងណាស់ ។ ខំសម្ងំគេងទៅណា៎អោយឆាប់មានកម្លាំង

ស្រីកំសត់ចាប់ហត្ថាប្រុសស្នេហ៍មកប្រច្បាច់ថ្នមៗ ហើយលើកមកដាក់ផ្ទាប់នឹងថ្ពាល់នាង ។ នាងសែនខ្លោចផ្សាអាណិតជីវិនណាស់ ។ ទឹកភ្នែកនាងកាន់តែហូរខ្លាយមកអកទប់មិនឈ្នះ ។ ប៉ុន្តែ សុភាពខំអត់សង្កត់ចិត្តខាំមាត់ខំអត់យំ ត្បិតនាងពុំចង់អោយអ្នកជម្ងឺកាន់តែស្លុតរន្ធត់ចិត្ត និងធ្លាក់ទឹកចិត្តខ្សោយថែមទៀត ។ លោកជីវិនខំប្រឹងបញ្ចេញកម្លាំងកំហែងដែលកាន់តែខ្សោយទៅៗដោយបញ្ឈាដៃស្តាំរបស់លោកទាញកេសាស្រីពន្លកមកដាក់

ហើយលើទ្រូងអ្នក ព្រមទាំងអង្អែលក្បាលនារី ដោយរន្ធត់ញាប់ញ័រ រួចទំបញ្ចេញវាចាខ្សាវៗទៀតថា៖

- នៅក្នុងលោកនេះ អ្វីៗទាំងអស់សុទ្ធតែមានទីបញ្ចប់របស់វា ។ យ៉ាងណាមិញ ជីវិតបងក៏ប្រហែលជាជិតដល់ថ្ងៃរលត់ទៅវិញដែរ ។ ...អូនអើយ...ថ្វីបើរូបកាយយើង...អាចឃ្លាតឆ្ងាយពីគ្នាបាន...តែចិត្តយើងទាំងពីរ...នៅតែរក់ត្របាញ់នៃបនិត្យជិតគ្នា...គ្មានគ្រារសាយឡើយ... ។ បងនឹងខិតខំបន់ព្រះសូមអោយលោកជួយ...ថែរក្សាអូនជំនួស...រូបបង... ។ អំណើះតទៅ...បើគ្មានបងទេ...សូមអូនជួយថែទាំ...រតនៈកូនកំសត់របស់បងផង...វាគ្មានញាតិសន្តានឯណាទេ...សូមអូនអាណិតវាកុំលះបង់វាចោលឡើយ...

- តែរតនៈ គេមានម្តាយរបស់គេណាំបង ។ តើធ្វើដូចម្តេចទៅ អូននឹងហួងហែងរតនៈបាន? ។ ចុះបើមាតាបង្កើតរបស់គេមកទាមទារដណ្តើមរតនៈពីទ្រូងអូនទៅ? តើអោយអូនធ្វើយ៉ាងណាទៅ?

គ្រាន់តែឮសំណួរនេះភ្លាម អតីតកាលដ៏ជូរចត់របស់លោកជីវិនក៏បញ្ចាំងឡើងយ៉ាងរស់រវើកក្នុងអារម្មណ៍ បណ្តាលអោយលោករីតតែឈឺចុកចាប់រមួលអួលផ្សាពេញបេះដូង ។ "បឃូរា" គឺជានាមរបស់នារីដែលបានផ្តល់កំណើតអោយរតនៈនេះ ជាពេជ្ឈឃាតចូលមកហូតព្រលឹងកាត់ផ្តាច់សង្ខារលោកជីវិនបណ្តោយ ។ នាងសូភាពសែនស្លូតរន្ធត់យ៉ាងក្រៃលែង ត្បិតនាងពុំដែលនឹកគិតដល់ថាបុរសដ៏ជាទីស្នេហាដ៏លើសលប់របស់នាងលាចាកលោកនេះ ទៅ ដោយ ងាយៗ ទុក ចោល អោយ នាង នៅកណ្តោចកណ្តែង ដូច្នេះសោះ ។ ស្រីអភ័ព្វស្រែកទ្រហោយំទួញខ្លែងៗបោកខ្លួនដូចអកញ្ញើ ឬដូចនាងបដាចារ... ។ នាងឈ្ងុលភក្ត្រាដែលស្រោចស្រពទៅដោយជលនេត្រទៅលើផែនឧរាគូស្នេហ៍ទាំងអាឡោះអាល័យ ។ គេឮសូរគំអួញយំស្រែកដ៏សែនអនិច្ចាថា៖

- បងអើយ! អូនខំសង្ឃឹម...អ្ហឹក...អ្ហឹក...ថា បានរូបប្រុសបងជាបង្គោលនៃជីវិតកំព្រារងាតែលតោលរបស់អូន...អូននឹកស្មានថា...បានបងជារស្មីនៃជីវិតអូន...ឥឡូវបងស្លាប់ចោលអូនហើយ!.. បង!...បង!...អ្ហឹក...អ្ហឹក!!!

ទំនួញដ៏វិយោគសោយសោករបស់ស្រីកំសត់បានទៅដាស់កុមាររតនៈដែលកំពុងនិទ្រាលក់នោះអោយភ្ញាក់ស្រឡាំងកាំងឡើង ។ កុមារកំសត់រត់មករកទីកន្លែងដែលជាប្រភពនៃសម្លេងសោកានោះ ។ លុះមកដល់ជិត នាងឃើញសូភាពនៀលយំយែកបោកខ្លួនលើទ្រូងបិតាដែលបិទភ្នែកជិតឈឹងនឹងថ្កល់នោះ ។ កុមារតូចស្រយុតរសេរសង្គរាត្បាក៏ស្រក់ទឹកភ្នែកមកតក់ៗ ហើយស្រែកយំងោង ព្រមទាំងសួរទាំងអណ្ដឹតអណ្ដកថា៖

- ម៉ាក់! ប៉ាប៉ាកើតអីហ្នឹង?

សូភាពខ្លោចផ្សាពន់ពេកក្រៃ នាងចាប់ឱបរតនៈហើយរៀបរាប់ទាំងរអួលររាក់ថា៖

- រតនៈកូន

ប៉ាកូនស្លាប់ចោលយើងហើយ... ពីថ្ងៃនេះទៅ...យើងទាំងពីរកំព្រាហើយណា៎... យើងរស់ទីពឹងពំនាក់ហើយ...កូនអើយ...យើងអីក៏អភ័ព្វម្ល៉េះ ។ ឱ! ព្រះអង្គអើយ! តើខ្ញុំម្ចាស់មានបាបកម្មអ្វី ពីអតីតជាតិ...បានជាជាតិនេះ...ខ្ញុំម្ចាស់ស្គាល់តែការរងទុក្ខ...មិនចេះចប់...ដូច្នេះ??!!

រតនៈឈរឱបទ្រូងយំដង្ហក់គួរអោយអនិច្ចា ។ ទាំងពីរនាក់ចាប់ឱបគ្នាយំយែកស្រែកប្ដឹងដល់អស់ទេព្ដាពីមហាទុក្ខដ៏រន្ធត់នេះ ។

នៅខាងក្រៅ មហាមេឃហាក់ដូចជាជួយអាណិតខ្លោចផ្សាដល់ជីវិតកំព្រាទាំងទ្វេហានេះដែរ ដោយបានយំយែកបង្អុរព្រះពិរុណមកស្រោចស្រពលើធម្មជាតិទាំងឡាយយ៉ាងសន្ធឹកសន្ធាប់ ។ វាយោនៃសារទរដូវបានបន្សាត់

គ្រាប់ភ្លៀងមកបោកប៉ះកញ្ចក់បង្អួចលាន់ឮប្រាវៗគួរអោយភ័យខ្លាច ។ យូរៗម្តង រន្ទះបោលរស្មីដ៏ភ្លឺផ្លេកៗឆ្លូតផ្ទៃមេឃដែលខ្មៅងងឹតដោយបញ្ចេញសម្លេងដ៏គួរអោយព្រឺស្បើប ។

បើយើងក្រឡេកមកមើលក្នុងបន្ទប់ផ្ទះសពលោកជីវ៉នវិញ នោះយើងឃើញនាងសុភាពដេកដួលលើកម្រាលក្តារក្រាលបាត់ស្មារតីទៅហើយ ។ គេឮសូររតនៈស្រែកយំក្តែងៗដោយសារតែមានការតក់ស្លុតនិងភិតភ័យ ព្រោះនៅតែម្នាក់ឯង ។

+++++

ជិតចេញផ្សាយហើយពីសមាគមអ្នកនិពន្ធខ្មែរ!!

ប្រលោមលោករឿង "ស្រមៃបន្ទាប់ពីស្រមៃ" របស់អ្នកនិពន្ធដដែល ។ ជាប្រលោមលោកផ្អែកមនោសញ្ចេតនា រៀបរៀងឡើងទៅតាមលំនាំរឿងពិតដែលលោកអ្នកនាងធ្លាប់បានស្តាប់រួចមកហើយតាមរលកធាតុអាកាសវិទ្យុរាសីក្នុងរាត្រីថ្ងៃព្រហស្បតិ៍នាខែមិថុនា ១៩៨៩ ។

សូមកុំភ្លេចជួយជាវអាន និងទុកជាឯកសារប្រចាំបណ្ណាល័យគ្រួសាររបស់លោកអ្នកនាង!

– ៩ –

តើមានអ្វីដែលធំជាងទុក្ខនៃការព្រាត់ប្រាសបាត់បង់មនុស្សដ៏ជាទីស្រឡាញ់នោះ? ។ សូភាពអស់បង្អែកជីវិតហើយ ។ ប៉ុន្តែ ស្រីអភ័ព្វត្រូវមានបន្ទុកដ៏ធ្ងន់មួយទៀត គឺត្រូវមានភារៈចិញ្ចឹមបីបាច់ថែរក្សារតនៈបុត្រតែមួយរបស់សពលោកជីវិន ។ នាងឥតមានការធ្វើផង តើនឹងត្រូវប្រឈមមុខតទល់នឹងបញ្ហាជីវិតដោយរបៀបយ៉ាងណាទៅ? ។ លុះនឹកឃើញដល់បញ្ហាលំបាកគ្រប់បែបយ៉ាងនេះកាលណា ឱរាស្រីសែនរួលណែនខ្លោចផ្សាឈឺចាប់ ហើយមានក្តីវិតក្កឥតឧបមា ។

សភាពស្រងេះស្រងោចនេះបណ្តាលអោយនារីកំសត់អង្គុយសញ្ជប់សញ្ជឹងភ្លឹកភ្លេចខ្លួន ហើយគិតតែពីសម្រក់ទឹកភ្នែករាល់ថ្ងៃ ។ គ្រប់ទីកន្លែងទាំងអស់សូភាពតែងតែឃើញស្រមោលគូស្នេហ៍ដែលនាងធ្លាប់គោរព និងស្រឡាញ់ជាងវត្ថុអ្វីទាំងអស់នៅក្នុងលោកនេះ ។ ជាពិសេសទៅទៀត វង្វង់ភក្ត្ររបស់កុមាររតនៈដែលដូចបេះបិទនឹងភក្ត្ររបស់បិតាប្រៀបដូចដំណក់ទឹកនោះ ញាំងអោយស្រីកាន់តែនឹកស្រណោះ ស្រយុតស្រយង់អស់អង្គកាយ ហើយកាន់តែសោកស្តាយអាឡោះអាល័យខ្លាំងឡើងៗរៀងរាល់ថ្ងៃ ។

កង្វល់ហួសព្រំដែននេះញ៉ាំងអោយរូបកាយនាងស្រេកស្រុតទ្រុតទ្រោមស្គមទៅៗគួរអោយអនិច្ចាជាពន់ពេក ។ តើមិនអោយនាងគិត មិនអោយនាងព្រួយដូចម្ដេចបាន បើនាងល្ងង់ មិនចេះដឹងអ្វី និងគ្មានស្ថានភាពមាំទាំជាល់នឹងផង ។ តើវាសនាអនាគតរតនៈក្មេងកំព្រានេះនឹងទៅជាយ៉ាងណា? ។ ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ ក៏សូភាពបានតាំងចិត្តយ៉ាងដាច់អហង្ការថា នាងសុខចិត្តតស៊ូតទល់គ្រប់ឧបសគ្គដើម្បីរក្សាកុមារតូចមិនអោយឃ្លាតឆ្ងាយរបេះពីដើមទ្រូងនាងឡើយ ។

គុក! គុក! គុក! រតនៈឮសូរសម្លេងគេគោះទ្វារផ្ទះរបស់ខ្លួន ។ ប៉ុន្តែនាងសូភាពដោយអារម្មណ៍របស់នាងបានអណ្ដែតហោះហើរចេញឆ្ងាយពីខ្លួននាងនោះ នាងគ្មានចាប់អារម្មណ៍ឬសូរអ្វីទាំងអស់ ។ រតនៈសម្លឹងមើលមុខសូភាព មិនឮនាងហាមប្រាមអ្វីសោះ ក៏ស្ទុះរឹងទៅបើកទ្វារ ។ គ្រានោះឯងរតនៈឃើញស្ត្រីម្នាក់មាឌធំខ្ពស់ដើរចូលមករក ហើយលូកដៃមកចាប់ហត្ថារបស់រតនៈ ។ រតនៈមិនដែលស្គាល់ស្ត្រីនោះ ក៏រលាស់ដៃចេញ ហើយរត់មករកនាងសូភាព ដោយស្រែកហៅទាំងភ័យខ្លាចថា៖

- ម៉ាក់! ម៉ាក់! គាត់ជាអ្នកណាហ្នឹង?

ទន្ទឹមនឹងពាក្យហៅរបស់រតនៈ ស្ត្រីនោះក៏បាននាំខ្លួនមកឈរភ្លែតចំពីមុខនាងសូភាពរួចទៅហើយ ។ កាលបើយល់ជាក់ថាជាសូភាពនោះ ស្ត្រីនោះក៏ឧទានឡើងទាំងភ្ញាក់ផ្អើល និងយ៉ាងសែនហួសចិត្តថា៖

- យី! សូភាពទេតើ! អញមិនស្មានថាបានមករកឯងឃើញនៅកន្លែងនេះសោះ

កាលបើឮគេហៅចំណោះរបស់ខ្លួនដូច្នោះ ព្រលឹងវិញ្ញាណទាំងឡាយក៏ប្រមូលចូលក្នុងប្រាណនាងវិញ ។ ស្រីអភ័ព្វក៏ភ័ន្តភាំងស្រឡាំងកាំងស្ទើរតែ

មិនជឿភ្នែករបស់ខ្លួនឯង ។ នាងស្គាល់ច្បាស់ថាភ្ញៀវនោះគ្មានអ្នកណាក្រៅពីលោកស្រីផានីដែលជាអតីតចៅហ្វាយចាស់របស់នាងឡើយ ។ នាងខំរក្សាអារម្មណ៍នាងអោយហ្នឹងហ្នឹង ហើយថ្លែងវាចាគួរសមដាក់ភ្ញៀវថា៖

- ជំរាបសួរលោកអ៊ុំ! លោកអ៊ុំអញ្ជើញមកទីនេះមានការអ្វីដែរចាំះ?

មិនរវីរវល់នឹងឆ្លើយតបទៅសំណួរសូភាពឡើយ លោកស្រីបែរជាមានប្រសាសន៍ដោយគ្រោតគ្រាតថា៖

- ព្រោះតែមានសាហាយអញ្ចឹងទេតើ បានជាលួចរត់ចេញពីផ្ទះអញនោះ!

- ម៉េចក៏លោកអ៊ុំមានប្រសាសន៍យ៉ាងនេះ?

- ប្រកែកដល់ណាទៀត បើ.....

- សូមអញ្ជើញលោកអ៊ុំអង្គុយសិនទៅលោកអ៊ុំ

- មិនបាច់គួរសមច្រើនទេ ។ អញឈរក៏បានដែរ អញប្រញាប់ ។ បើតាមអញស្គាល់ឯងនោះ ឯងគ្មានញាតិសន្តានឯណាទេ មិនថាអញ្ចឹងឬ? ។ តើឯងត្រូវជាអ្វីជាមួយនឹងជីវ៉ែនដែរ?

- ចាំះ ខ្ញុំត្រូវជាប្រពន្ធរបស់គាត់ ។ ក្មេងនេះត្រូវជាកូនខ្ញុំ ចាំះ

គ្រាន់តែឮសូរចម្លើយបែបនេះ លោកស្រីផានីក៏ពេបមាត់ច្រវែបៗ រួចជម្រុះវាចាដ៏អាស្រូវដាក់នាងសូភាពថា៖

- ជីវ៉ែនជាប្ដីរបស់ឯង? ....នេះជាកូនឯង? ។ កុហក! ការពីរង្គាល់បានជាបានកូនអាយុប្រាំមួយឆ្នាំហើយនោះ បើឯងទើបតែរត់ចេញពីផ្ទះអញមកបានតែជាងមួយឆ្នាំប៉ុណ្ណោះសោះ?!

ដោយឃើញនាងសូភាពនៅរក្សាការស្ងប់ស្ងៀម លោកស្រីក៏ព្រួសវាចាបន្ថែមទៀតដូចតទៅ៖

- អញមកនេះ គឺមកតាមបណ្ដាំរបស់ "មយូរា" ដែលជាក្មួយស្រីរបស់

វិញ ។ ឯងក៏ប្រហែលជាធ្លាប់ឮឈ្មោះនេះហើយមែនទេ ។ គឺជាម្ដាយបង្កើតរបស់រតនៈ ។ កាលជីវិននៅរស់ មយូរាគេមិនទាមទារយករតនៈទៅទេ ។ ឥឡូវនេះ ជីវិនក៏ស្លាប់បាត់ទៅហើយ ទើបគេចង់បានកូនគេទៅវិញ ។ ឯងក៏ដឹងខ្លួនស្រាប់ហើយ ថាឯងមិនមែនជាម្ដាយរបស់រតនៈទេ ។ ដូច្នេះ ឯងគ្មានអំណាចអ្វីមកខាឃាំងមិនអោយរតនៈទៅនៅជាមួយម្ដាយបង្កើតរបស់វាទេ ។ ស្ដាប់បានទេ?

- សូមទោសចុះ លោកអុំ ខ្ញុំសូមប្រឆាំងនឹងបំណងនេះ ។ ខ្ញុំពុំអាចក្បត់បណ្ដាំរបស់បងជីវិនបានឡើយ ។ មុននឹងគាត់ស្លាប់ទៅ គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា រតនៈគ្មានញាតិសន្ដានឯណាទេ ។ គាត់ផ្ដាំខ្ញុំអោយរក្សាបីបាច់ចិញ្ចឹមរតនៈជាដាច់ខាត ។

- នែ៎! ចូរនាងកុំស្មានថា រតនៈចៅអញវាកំព្រាកំព្រាក្បាលមួយដូចនាងឯងនោះអោយសោះ ។ សូភាព! ដើម្បីអនាគតក្មេងនេះ ឯងគ្មានអំណាចអ្វីហួងហែងវាទេ ។ បើនាងជាស្រីល្អនោះ ជីវិនមិនមែនស្លាប់ទេ ។ នាងឯងនេះចង្រៃណាស់ ជាស្រីដែលស៊ីប្ដីឯង ប៉ះប្រុសណា ប្រុសនោះត្រូវស្លាប់!

- រឿងមរណភាពរបស់បងជីវិន គ្មានទាក់ទងអ្វីនឹងរូបខ្ញុំទេ សូមលោកអុំជ្រាប ។ គាត់ស្លាប់ទៅដោយសារគាត់មានជម្ងឺរបេងយូរយារណាស់មកហើយនោះទេ

- ជម្ងឺរបេង!! ឱ! ឯងមកចម្លងរបេងអោយជីវិនទៀត?

លុះឮពាក្យចោទដ៏សែនអសប្បុរសនេះកាលណា សូភាពនឹកខឹងឆួលភ្លាមមួយរំពេច ។ ស្រីក៏តបឆ្លើយទៅវិញយ៉ាងតឹងសរសៃកថា៖

- គិតទៅ លោកអុំប្រសប់ប្រឌិតរឿងមែន ។ កាលពីមុន ថាខ្ញុំកើតជម្ងឺមហារីក ។ ឥឡូវ ដល់ថ្នាក់កើតជម្ងឺរបេងទៀត?! ។ គឺដោយសារតែជម្ងឺ

មហារីកដែលលោកវរ៉ុចង់បំបែកខ្ញុំពីជំនោរនោះហើយ បានជាខ្ញុំត្រូវឃ្លាតពីផ្ទះ លោកវរ៉ុ ដោយចោលប្រាក់ជាប់បីម៉ឺនហ្វ្រង់ ។ សូមលោកវរ៉ុឈប់ប្រើមធ្យោបាយដ៏ខ្មៅងងឹតនេះទៀតទៅ ។ ក្នុងពេលដ៏រាសន្ននេះ ខ្ញុំត្រូវការប្រាក់ខ្ញុំវិញ ។ បើលោកវរ៉ុជាមនុស្សមានចិត្តទៀងត្រង់ អោយប្រាក់ខ្ញុំមកខ្ញុំវិញមក....

- ប្រាក់ឯង? ប្រាក់ស្អី?

- ប្រាក់ខែដែលខ្ញុំធ្វើការនៅរោងចក្រ ។ ប្រាក់ដែលខ្ញុំខំសន្សំទុករាល់ៗខែ សូមលោកវរ៉ុកុំធ្វើពើអីលោកវរ៉ុ!

- ឯងឥឡូវនេះខ្លាំងដៃសម្បើមណាស់ហ្ន៎ ។ កុំភ្លេចថា នាងឯងធ្លាប់ជាកញ្ជះរបស់អញណា៎ ។ បានហើយ! មិនបាច់និយាយច្រើនទេ អញថ្លង់ណាស់ ។ អញមិនមែនមកឈ្លោះជាមួយនាងដែលជាឈ្នួលបំរើអញនោះទេ ។ ទៅ! ទៅរៀបតែខោអាវរតនៈមកអោយអញ អញត្រូវការយកក្មេងតូចនេះទៅប្រគល់អោយម្ដាយបង្កើតរបស់វាវិញ ។

- ទេ! ខ្ញុំមិនប្រគល់រតនៈជូនលោកវរ៉ុជាដាច់ខាត ។ ប្រសិនបើម្ដាយបង្កើតចង់បានកូនគេទៅវិញ សូមអោយគាត់មកយករតនៈដោយខ្លួនឯងទៅចុះ ។ ដល់ពេលនោះ ខ្ញុំប្រហែលជាមិនប្រកែកទេ ...

- ឯងប្រាកដជាមិនព្រមអោយក្មេងនេះមកអញឬ?

- ចា៎ះ ប្រាកដណាស់ ។ ខ្ញុំក៏ជឿថា រតនៈមុខជាមិនព្រមទៅតាមលោកវរ៉ុទេ ។ បើមិនជឿ លោកវរ៉ុសួរវាទៅមើល

លោកស្រីផានីក៏ក្រឡេកមើលទៅរតនៈ ។ ឃើញគេមើលមុខខ្លួនចំដូច្នោះ រតនៈក៏ស្ទុះទៅឈរពួនពីក្រោយខ្នងរបស់នាងសូភាពភ្លាម ។ លោកស្រីផានីក៏ដើរទៅជិតកុមារតូច រួចបោសអង្អែលខ្នង ទាំងពោលពាក្យល្អួង

លោមរតនៈថា៖

- រតនៈចៅ! ចៅមិនស្គាល់ជីដូនទេឬ? ។ តោះ! ទៅស្លៀកពាក់មក ទៅនៅជាមួយជីដូនវិញ ។ ជីដូននឹងនាំចៅទៅទិញល្បែងល្អៗយ៉ាងច្រើន ទិញនំឆ្ងាញ់ៗ ទិញខោអាវល្អៗ ថ្មីៗអោយចៅណា៎ ។ ម្ដាយរបស់ឯងនៅចាំទទួលឯងក្នុងផ្ទះជីដូនឯណោះ ។ មកឆាប់ឡើង កុំអោយម៉ាក់ចាំយូរ....

- ទេ! ខ្ញុំនៅជាមួយម៉ាក់ខ្ញុំនេះវិញ (វាចង្អុលទៅនាងសូភាព) ...ខ្ញុំនៅជាមួយប៉ាប៉ាវិញ

- មានប៉ាប៉ាណាទៀត បើប៉ាប៉ាស្លាប់ចោលបាត់ទៅហើយនោះ?

- ម៉ាក់ថា ប៉ាប៉ាស្លាប់មែន តែព្រលឹងប៉ាប៉ានៅក្នុងផ្ទះជាមួយយើងដដែល....

ថារួច វារត់ទៅឈរមើលរូបបិតាដែលតាំងនៅលើជញ្ជាំងដោយសួរបញ្ជាក់ថា៖

- មែនទេប៉ាប៉ា?

វិការដ្ឋាននេះញាំងអោយនាងសូភាពរួលណែនក្នុងឧរាក្រៃពេក ។ នារីគេចមុខចេញ លួចសម្រក់ទឹកភ្នែក ។ រតនៈក៏រត់មកឱបនាង សួរទាំងស្រងូតស្រងាត់ថា៖

- មែនទេ ម៉ាក់?

- មែនហើយកូនសម្លាញ់! (នាងសូភាពឆ្លើយតបទាំងររាក់ររួល)

លោកស្រីផានីស្ដាប់ពាក្យហៅថា "ម៉ាក់! និងកូន! "ដែលអ្នកទាំងពីរហៅគ្នាយ៉ាងផ្អែមល្ហែមនោះ លោកស្រីសែនឃ្នាន់ខ្នាញ់ហើយទ្រលាន់ជាខ្លាំង ។ មិនតែប៉ុណ្ណោះ លោកស្រីមិនសប្បាយចិត្តទាល់តែសោះ កាលបើកុមារតូចមិនសុខចិត្តស្ដាប់ការបញ្ចុះបញ្ចូលរបស់លោកស្រីដូច្នេះ ។ លោកស្រីក្ដៅក្រហាយក្នុងចិត្តពេក ក៏បញ្ចេញវាចាទាំងហួងហែងអោយនាងសូភាពបួង

ទៀតថា៖

- គិតទៅ មនុស្សភ្លីភ្លើល្ងីល្ងើល្ងង់ខ្លៅដូចនាងឯងប្រសប់ម្ដ៉ោងដែរទេតើ ។ ប្រសប់ត្រង់ចេះធ្វើអោយរតនៈវាហៅ "ម៉ាក់" រួច ។ ទោះយ៉ាងនេះក៏ដោយ អញសូមព្រមានថា កុំភ្លេចថាឯងជាឈ្នួលបំរើរបស់អញ...គឺមនុស្សដែលគ្មានអនាគត កុំចង់តាំងខ្លួនជាម្ដាយរបស់រតនៈ កុំចង់អប់រំក្មេងនេះធ្វើអ្វី...អត់ការធ្វើដូចនាងឯង ក្រែងគ្មានអ្វីអោយចៅរបស់អញស៊ី ងាប់វានាំពិច្ចកចូលគុកទៅ ។ តើនាងឯងមានច្បាប់ឯណាហួងហែងវាទុក?

សូភាពកាន់តែឈឺអួលផ្សាក្នុងឱរា កាលបើត្រូវលោកស្រីផានីប្រមាថកាតទាននាងខ្លាំងឡើងៗបែបនេះ ។ ស្រីខំសង្កត់ចិត្ត ហើយសងសំដីទៅវិញថា៖

- លោកអ៊ុំ! ខ្ញុំមិនដែលភ្លេចពីអតីតកាលរបស់ខ្ញុំម្ដងណាទេ មិនចាំបាច់លោកអ៊ុំរំឭកថា ខ្ញុំជាអ្នកបំរើលោកអ៊ុំដែលជាមនុស្សថោកទាប ទន់ខ្សោយក្រីក្រ គ្មានតំរេះវិជ្ជា ។ ការដែលខ្ញុំតាំងខ្លួនជាមាតារបស់ក្មេងកំសត់នេះក៏ព្រោះតែខ្ញុំយល់ថា រតនៈគ្មានម្ដាយ ឬក៏មានដែរ តែម្ដាយដែលគ្រាន់តែបង្កើតកូនមកចោល ឥតខ្វាយខ្វល់នឹងចិញ្ចឹម ព្រមទាំងមិនអំពល់គិតដល់អនាគតរបស់គ្នា ដោយបណ្ដោយទុកអោយកូនរបស់ខ្លួនរស់នៅក្រោមអំណាចព្យាបាលរបស់ខ្ញុំដែលជាឈ្នួលបំរើរបស់គ្រួសារលោកអ៊ុំទៅវិញ ។ ខ្ញុំជាឈ្នួលគេមែន តែខ្ញុំជាមនុស្សដែលចេះមានសប្បុរសធម៌ ករុណាធម៌ជួយចិញ្ចឹមបុត្ររបស់អ្នកដទៃដែលមានឈ្មោះថាម្ដាយបង្កើតខ្វះព្រហ្មវិហារធម៌... ។ ណ្ហើយចុះ ខ្ញុំមិនបាច់សួរថា តើអ្នកស្រីមយូរា ឬមីសម្រែកញ្ញាះគេដូចយ៉ាងខ្ញុំ អ្នកណាគ្រាន់បើជាងទេ ។ ខ្ញុំទុកជូនលោកអ៊ុំពិចារណាដោយខ្លួនឯងចុះ...

- យើស! មីកាភាព នាងឯងកុំខ្លាំងដៃពេក... បានគ្រាន់បើបន្តិចដោយ

សារជីវិនលើកដំកើងជាគួកំណាន់ បង្រៀនអោយចេះពាក្យជ្រៅជ្រះនឹងគេ តែរជាហ៊ានយកពាក្យនោះមកដៀលត្មិះមយូរាក្ខយស្រីរបស់អញផង ។ រឿងរ៉ាវរបស់គេ ឯងមិនបាច់មកលូកកកាយហែកហួរទេ តិចពិបុកកើតរឿង... ។ នែ! បើមយូរាក្ខយស្រីអញវាព្រពាក្យពេចន៍ដំនៀលរបស់នាងឯង ។ នាងឯងប្រាកដជាជៀសពីត្រូវកំភ្លៀងមិនរួចទេ នេះអញប្រាប់អោយដឹងមុន ។ ប្រយ័ត្នស់ដីថ្ងៃមុខថ្ងៃក្រោយ កុំគ្រាន់បើពេក មិរហាមឥតទីពឹង...

- ចាំះ លោកអ៊ុំ! បើខ្ញុំខ្លាំងដៃខ្លះនោះក៏ព្រោះតែមកពីសេចក្ដីឈឺចាប់ហួសប្រមាណតែប៉ុណ្ណោះ ។ ពីដើម ខ្ញុំធ្លាប់ស្រឡាញ់និងគោរពលោកអ៊ុំទុកស្មើម្ដាយរបស់ខ្ញុំ ខ្ញុំមិនដែលហ៊ានតមាត់ ត.ក.ម្ដងណាមែន ។ ប៉ុន្តែ លុះខ្ញុំសំគាល់ឃើញថាលោកអ៊ុំមានចិត្តអសប្បុរសព្យាបាទខ្ញុំគ្រប់បែបយ៉ាងនោះ សូមទោសចុះ ខ្ញុំសូមរើបំរាស់ម្ដងហើយ

- យើស! ចេះគុំគួនសងសឹកផងឬ? នាងឯងចង់ធ្វើអីអញ ចង់ប្ដឹង! ប្ដឹងទៅ

- ខ្ញុំមិនបាច់ប្ដឹង មិនបាច់សងសឹកអីទេ តែសូមទោសចុះលោកអ៊ុំ! ពេលនេះខ្ញុំកំពុងស្ថិតនៅក្នុងការកាន់ទុក្ខបងជីវិនប្ដីរបស់ខ្ញុំនៅឡើយ... ។ បើលោកអ៊ុំមិនបានជួយឈឺឆ្អាល ជួយសម្រាលទុក្ខសោករបស់ខ្ញុំទេ សូមលោកអ៊ុំកុំយកបញ្ហាផ្សេងៗមកគរលើទ្រូងខ្ញុំទៀតអោយសោះ ។ ខ្ញុំជឿថា លោកអ៊ុំប្រហែលជាចេះរាណិតមេត្តាដល់សត្វលង់ទឹកដែរមែនទេ ។ បើអញ្ចឹង សូមលោកអ៊ុំជួយទិញយកចិញ្ចៀនពេជ្រដែលលោកអ៊ុំលក់អោយខ្ញុំនោះផងចុះបានទេ?

- មើល ចិញ្ចៀនស្អី?

- នេះនែ លោកអ៊ុំ!

- ចិញ្ចៀនហ្នឹង? ក្រឡែរញ៉ីង! ហ៊ានរអួតថាពេជ្រផង
- ចុះ ខ្ញុំដឹង អី លោករ៉ុ!! ។ ខ្ញុំក្រ តោក យ៉ាកមិន ដែល ចេះ មើល ពេជ្រ ឯណា ។ បើលោករ៉ុថាពេជ្រខ្ញុំចេះតែជឿហើយ
- នែ! មីកាភាព និយាយចុះនិយាយឡើង កុំផ្លែផ្កាដាក់អោយរញ្ជពេក
- ខ្ញុំមានទៅផ្លែផ្កាអីលោករ៉ុ ។ ចិញ្ចៀនពេជ្រដែលលោករ៉ុបញ្ចុះបញ្ចូលអោយខ្ញុំទិញ ។ ខ្ញុំ គ្រាន់តែចង់ឈក់វិញ ដោយការទ័លក្រទេតើ... ។ បើលោករ៉ុថា មិនមែនពេជ្រទេ ក៏ចាត់ទុកថាខ្ញុំចាញ់ប្ញោកលោករ៉ុទៅចុះ ធ្វើម៉េចបើបានជាល្ងង់ខ្លៅ ទៅធ្វើការក្រៅយកលុយអោយគេទុក ហើយទិញចិញ្ចៀន ត្បូង ក្រឡែ យល់ថា ពេជ្រ សុទ្ធ... នេះ ក៏ព្រោះ តែ ទុក ចិត្ត គេ ពេកប៉ុណ្ណោះ ។ បើលោករ៉ុរស់រឿងអ្វីទៀតហើយ សូមមេត្តាទុកអោយខ្ញុំបានស្ងប់ចិត្តបន្តិចចុះ...

ទាល់ប្រាជ្ញ ណាក៏នឹកខ្មាសអៀន អតីតស្រីបំរើពេកផង លោកស្រីផានីក៏គ្រឡប់ចេញទៅវិញទាំងម្ហូម៉ៅក្តៅក្រហាយដូចគេដុតទាំងរស់ដូច្នោះ ។

ទោះម្តេចម្តា នាងសូភាពខំប្រមែប្រមូលកម្លាំងកាយ ព្រមទាំងកម្លាំងចិត្តឡើងវិញ ហើយខិតខំដើររកការងារធ្វើជារៀងរាល់ថ្ងៃ ។ នាងពុំទាន់មានវាសនារកបានការងារណាមួយអោយបានជាប់លាប់សោះ ក្រៅពីធ្វើការបោសជូត បុរិុតខោអាវ មើលកូនគេមួយថ្ងៃបីម៉ោងប៉ុណ្ណោះ ។ ថ្វីបើលោកជីវែនបានបន្សល់ទុកប្រាក់កាសអោយនាងច្រើនគួរសមមែន តែនាងមិនមានយំរាងចាំតែចាយវាយប្រាក់នោះទេ ។ រីឯកំរៃដ៏ស្តួចស្តើងដែលនាងរកបានខ្លះនេះគ្រាន់នឹងអាចផ្តល់អោយនាងទប់ទល់ទៅលើការចំណាយសព្វសារពើដោយត្បិតត្បៀតជាទីបំផុត ។

សព្វថ្ងៃនេះ បើកុំតែបានកុមាររតនៈឆ្លៀវឆ្លាតចេះពាក្យសំដីជួយបន្ធូរ

បន្ថយនូវទុក្ខសោកខ្លះៗនោះ សូភាពពុំដឹងជាវក់វីចិត្តយ៉ាងណាទេ? ។ ត្បិតការសោកស្តាយដ៏ធំធេងក្នុងការបាត់បង់បុរសកំពូលដួងចិត្តពុំងាយអោយនាងបានធូរស្រាលរសាយចិត្តនៅឡើយទេ ។ មិនត្រឹមតែប៉ុណ្ណោះសោត ការភ័យខ្លាចគេមកប្រទេះយករតនៈពីទ្រូងនាងទៅនៅតែលងបន្លាចចិត្តនាងឥតមានល្ហែសោះឡើយ ។

យើងទុកអោយនាងសូភាពកើតទុក្ខខ្លោចផ្សាម្នាក់ឯងមួយរយៈសិនចុះ ។ យើងក្រឡេកទៅមើលជំនោរម្តង ។ ខ្ញុំសង្ឃឹមថា លោកអ្នកអានក៏ប្រហែលជានៅចាំឈ្មោះ "ជំនោរ" នៅឡើយ ។ វិលឯមកជាងមួយឆ្នាំហើយ គឺតាំងពីសូភាពរត់ចេញពីស្ត្រោស់បួរមកកាលណា យុវកម្លោះនេះពុំទាន់ដាច់ចិត្តយកប្រពន្ធនៅឡើយ ។

ថ្ងៃនេះ គេត្រេកអរខ្លាំងណាស់ កាលបើគេដឹងដំណឹងពីឳពុកមាគេថា សូភាពនៅ Golbey អេពីណាល់ ។ បន្ទាប់ពីបានរាស័យដ្ឋានរបស់នាងសូភាពភ្លាម គេក៏រូតរះទៅរកនាងដល់ទីលំនៅឯអេពីណាល់ ព្រមទាំងនាំដំណឹងដ៏ល្អមួយទៅប្រាប់សូភាពផងដែរ ។

សូភាពអង្គុយស្តាប់ជំនោររៀបរាប់ដោយយកចិត្តទុកដាក់ ។

– ភាព! ក៏ដូចជាខ្ញុំបានស្មានពីមុនមកមែន ថាភាពឥតមានឈឺអ្វីទេ ។ ពាក្យថាភាពកើតជម្ងឺ "មហារីក" នោះ គ្រាន់តែពាក្យប្រឌិតរបស់លោកស្រីផានីប៉ុណ្ណោះ ។ ខ្ញុំអរណាស់កាលដែលដឹងថាភាពនៅទីនេះ ។ លោកមាខ្ញុំក៏អរណាស់ដែរ ។ គាត់បានតឿនខ្ញុំអោយមករកភាពភ្លាម ។ មិនតែប៉ុណ្ណោះ គាត់ចង់អោយយើងទាំងពីរបានរៀបការជាមួយគ្នាថែមទៀតផង ។ ចំពោះខ្ញុំ ចិត្តខ្ញុំឥតមានប្រែប្រួលអ្វីសោះឡើយ សូមភាពជឿចិត្តខ្ញុំចុះ

សូភាពហៅជំនោរថា "ពូៗ" ដដែល ។ នាងក៏ថ្លែងទាំងសោកស្តាយប្រាប់

រអ្នកកម្លោះវិញថា៖

- សូមពូខំបំភ្លេចខ្ញុំចោលទៅ ។ ខ្ញុំពុំមែននៅក្រមុំដូចពីមុនទៀតទេ ។ ខ្ញុំជាស្រីមេម៉ាយ មានទាំងកូនមួយទៀតផង មិនសក្តិសមនឹងរូបពូដែលនៅកម្លោះនោះទេ ។ គួរណាស់ ពូរកនារីក្រមុំដែលមានវ័យក្មេងខ្ចី ទើបសក្តិសមនឹងពូណាំពូជំនោរ

- ទោះក្រមុំឬមេម៉ាយ ខ្ញុំនៅតែស្រឡាញ់ភាពគ្មានប្រួលប្រែឡើយ ។ សេចក្តីស្នេហាពិតពុំបានគិតដល់ឋានៈវណ្ណៈ ឬគិតដល់វ័យខុសគ្នាអ្វីទេ ។ សូមភាពកុំប្រកាន់ចិត្តរឹងពេក អាណិតខ្ញុំផង

- ខ្ញុំអាណិតពូជំនោរណាស់ ។ ធ្វើម៉េចបើជាតិនេះបានជាហួសទៅហើយ ចាំជាតិក្រោយចុះពូជំនោរ សូមពូកុំអាក់អន់ចិត្តនឹងខ្ញុំអី ។ អភ័យទោសអោយខ្ញុំផងណាំពូណាំ

- ហ៊ឺ! គួរណាស់តែភាពផ្តល់សេចក្តីសង្ឃឹមអោយខ្ញុំខ្លះផង ។ មិនគួរភាពមានចិត្តដាច់ដល់ម្ល៉ឹងសោះ ។ ណ្ហើយចុះ សូមភាពនៅអោយបានសុខណាំ ។ ខ្ញុំសូមលាភាពសិនហើយ...

សូភាពតាមមើលដំណើររបស់ជំនោរទាំងឱ្យាតានតឹងស្ទើរតែប្រេះធ្លាយ ។ មិនមែននាងមិនអាណិតជំនោរដែលខំតស៊ូស្រឡាញ់នាងនោះទេ ។ ប៉ុន្តែ នាងបានតាំងចិត្តថា នាងមិនយកប្តីទៀត ។ ទើបនាងត្រូវតែឆ្លើយតបទៅជំនោរវិញយ៉ាងដូច្នោះឯង... ។ នាងនឹកថា គ្មានបុរសណាមួយអាចជំនួសរូបបងជីវ៉នរបស់នាងបានឡើយ ។ ក្រៅពីជីវ៉នដែលចេះស្រឡាញ់ថ្នាក់ថ្នមចិត្តនាង ចេះយោគយល់ និងចេះបំពេញចិត្តនាង ហើយចេះលើកដំកើងនាងនោះ នាងគ្មានសេចក្តីទុកចិត្តបុរសណាទាំងអស់ ទោះជាជំនោរក៏ដោយ ។ នាងតែងធ្លាប់ឮគេនិយាយច្រើនពីរឿងប្រុសធ្វើឬកធំដែលមិន

ចោលរបៀបជិះជាន់ភរិយាទុកដូចជាទាសី ។ ប្រុសដែលមានគំនិតខិលខូចដើរចោលផ្ទះសម្បែងមានស្រីញីទៅតាមទំនើងចិត្តល្មោភស្នេហ៍ ឬក៏ធ្វើបាបប្រពន្ធដោយហៅមិត្តភក្តិមកជប់លៀងអោយប្រពន្ធបំរើជុតដៃជុតជើង បំរើភ្ញៀវមិនឈប់ឈរនោះ... ទើបសូភាពក៏សូមស្មាលាបញ្ចប់រឿងស្នេហាតែត្រឹមណេះចុះ ។

.....................................................................................................................................................

វិលងមកបានមួយសប្តាហ៍ហើយដែលនាងបានទទួលការជេរប្រមាថរបស់លោកស្រីផានី ។ ជម្លោះនោះមិនអាចអោយស្រីភ្លេចឆាប់ៗបានឡើយ ។

រាត្រីនោះឯង.....ស្រាប់តែបាត់រតនៈ.....

សូភាពភ័យណាស់ ខំរត់រករតនៈគ្រប់ទិសទី...នៅមុខផ្ទះ...នៅក្បៀនផ្ទះ....កន្លែងនានាដែលរតនៈធ្លាប់លេងជាមួយក្មេងជិតខាង ក៏នាងពុំបានឃើញរតនៈសោះ ។ ស្រីខំបង្កុកហៅក្តែងៗទាំងភ័យ ទាំងព្រួយ ទាំងរន្ធត់!

- រតនៈកូន! កូននៅឯណា? ។ កូននៅលេងត្រង់ណា? ។ យប់ណាស់ហើយ មេឃជិតភ្លៀងហើយ ខ្យល់ក៏ធ្លាក់មករងាណាស់កូនអើយ! ចូលផ្ទះយើងវិញណា៎ ។ ឬមួយកូនខឹងម្តាយរឿងអ្វីបានជាកូនរត់ពួន... ឬមួយកូនចង់លលេងនឹងម្តាយធ្វើអោយម្តាយភ័យយ៉ាងនេះ កូនប្រុសសម្លាញ់!

នាងរត់រកផង ស្រែកហៅផងដូចមនុស្សវិកលចរិតដូច្នោះ ។ កល្យាណីស្រីភ័យណាស់ ភ័យខ្លាចបុត្រាភ្ញារមានគ្រោះថ្នាក់... ។ ពេលនោះហើយដែលធ្វើអោយនាងនឹកទាំងអស់ឡើងវិញ...នឹកឃើញកាលជួបរតនៈដំបូង ឮរតនៈហៅនាងថា "ម៉ាក់"!...នឹកឃើញនាងបណ្តើររតនៈមកជូនបិតាគេវិញ...ស្រាប់តែស្រីយំសោងរៀបរាប់រំឭកថា៖

- ជីវិនបងអើយ! បងបន្ទុកបណ្តាក់កូនប្រុសតែមួយរបស់បងអោយអូន

មើលថែទាំ... ។ ឥឡូវបងស្លាប់មិនបានប៉ុន្មានខែផង... អូនធ្វើអោយបាត់រតនៈ... តើបងខឹងនឹងអូនយ៉ាងណាទៅ?

អស់សង្ឃឹមពន់ពេកក្រៃ សូភាពក៏វិលត្រឡប់ចូលផ្ទះវិញទាំងទឹកភ្នែករហាម ។

- យី! យី!

សូភាពភ្លាត់មាត់កាលបើឃើញនារីចម្លែកម្នាក់មានអាយុប្រមាណសាមសិបឆ្នាំ សម្បុរសណ្តែកបាយ ភក្ត្រល្អប្រិមប្រិយ៍នៅអង្គុយគងអន្ទាក់ខ្លាយ៉ាងហ៊ានៅក្នុងបន្ទប់ទទួលភ្ញៀវ ។ នារីនោះសម្លក់សម្លឹងនាងសូភាពទាំងទឹកមុខមាំ ហើយហារមាត់ប្រុងសួរ តែត្រូវសូភាពសួរកាត់មុនថា៖

- លោកស្រីជាអ្នកណាដែរបានជាអាចចូលមកក្នុងផ្ទះខ្ញុំបាន ពេលខ្ញុំមិននៅដូច្នេះ?

នារីជាភ្ញៀវធ្មេញកខែងរែងខ្ចាក់វាចាដោយគ្មានញញើតចិត្តម្ចាស់ផ្ទះថា៖

- ខ្ញុំមិនបាច់ប្រាប់ថាខ្ញុំជាអ្នកណាទេ ។ អ្នកបណ្តោយអោយរតនៈដើរលេងក្រៅផ្ទះអាភាត់អាភាយគ្មានប្រយ័ត្នប្រយែងអ្វីសោះ ព្រោះគិតថាវាមិនមែនកូនអ្នកឯងឬ? ។ នេះហើយឬរបៀបគ្រប់គ្រងរបស់ដ៏ល្អរបស់អ្នកនោះ? ។ បើកុំតែខ្ញុំមកទាន់ ម្ល៉េះសមរតនៈមិនដឹងជាត្រូវមានគ្រោះថ្នាក់អ្វីទេ ។

និយាយចប់ ស្រីជាភ្ញៀវក៏ងើបឈរឡើង ហើយដើរទៅកាន់មាត់បង្អួច ។

សូភាពលួចគយគន់ពីក្រោយ ឃើញនារីមានរាងសង្ហា សក្តិសមនឹងសំលៀកបំពាក់ដ៏ទំនើបឥតខ្ចោះ ។ នារីបែរមករកសូភាពវិញ ដៃកាន់ចុងក្រមាបង់កម៉ាកភ្នែរការដាំង (Pierre cordin) រលាស់ចុះរលាស់ឡើងដោយនិយាយម៉ាត់ៗថា៖

- ពូថាអ្នកឯងបានប្រមាថតិះដៀលខ្ញុំអោយម្ដាយបីងខ្ញុំស្លាប់សម្បើមណាស់មែនទេ?

គ្រាន់តែឮពាក្យប៉ុណ្ណេះ សូភាពគាត់យល់ជាស្រេចថា គឺលោកស្រីបយូរាភរិយាដើមរបស់លោកជីវ៉ន ។ ភ្ញៀវរូបភើតក៏បន្តប្រយោគវាចាយ៉ាងបើលងាយថា៖

- អ្នកត្រូវតែដឹងខ្លួនឯងយ៉ាងច្បាស់ថា អ្នកគ្មានសមត្ថភាពគ្រប់គ្រាន់ដើម្បីចិញ្ចឹម ព្យាបាល កូន របស់ ខ្ញុំ ទេ ។ ខ្ញុំ ត្រូវ ការ អោយ កូន ខ្ញុំ មាន អនាគត ភ្លឺស្វាង ។ ខ្ញុំមកយកវាទៅអោយអ្នកមានបារាំងមួយគូដែលគេបានសុំកូនរបស់ខ្ញុំទៅចិញ្ចឹម ។

សូភាពសែនហួសចិត្ត ។ នឹកកោតចិត្តគេដែលហាមាត់និយាយពាក្យនេះកើត ។ នាងនឹកក្នុងចិត្តថា "ជាតិជាម្ដាយដែលគ្មានចិត្តចេះស្រឡាញ់កូនខ្លួននេះបានចំហៅអស្ចារ្យមែន! ។ សុខចិត្តយកកូនខ្លួនឯងទៅអោយសាសន៍ដទៃចិញ្ចឹម រួចមកដៀលត្មះនាងមិនខុសពីលោកស្រីផានីសោះតែម្ដង" ។

លុះ ឃើញ សូភាព នៅ ស្ងៀម ទ្រឹង ឥត មាន ប្រតិកម្មអ្វី សោះ នោះ អតីតភរិយារបស់លោកជីវ៉នក៏សង្កើញសួរថា៖

- តើអ្នកនៅសញ្ចប់សញ្ជឹងគិតដល់ណាទៀត? ។ តាំងពីជួបម្ដាយបីងខ្ញុំមកអ្នកមានពេលគ្រប់គ្រាន់សំរាប់គិតហើយមែនទេ? ។ កុំភ្លេចសំដីអ្នកអោយសោះ ដែលផ្ដាំតាមម្ដាយបីងខ្ញុំថា បើខ្ញុំមកយកកូនខ្លួនឯង អ្នកមុខជាប្រគល់អោយភ្លាមនោះ ។ ចុះហេតុអ្វីក៏នៅរារែករុញរាដល់ណាទៀត? ។ អរគុណហើយដែលបានស្រឡាញ់កូនខ្ញុំ តែខ្ញុំជឿថា អ្នកមិនមែនស្រឡាញ់វាគន:ជាងខ្ញុំដែលបានបង្កើតវាមកទេ ។

សូភាពចង់តែភ្លើយថា៖

- "ខ្ញុំជឿថា ខ្ញុំស្រឡាញ់រតនៈជាងលោកស្រីដែលជាអ្នកបង្កើតវាមក ។ ទោះយ៉ាងណាក៏ខ្ញុំស៊ូឱ្យរតនៈមិនមែនដាច់ចិត្តលះបង់អោយវាទៅមហាសេដ្ឋីបរទេសឡើយ"

សូភាពមិនចង់ឈ្លោះប្រកែកទេ ។ នាងនៅតែរក្សាការស្ងៀមស្ងាត់ដដែល ។ មយូរាក៏ចេះតែនិយាយតែម្នាក់ឯងទៀតថា៖

- បើខ្ញុំលួចយករតនៈពេលអ្នកមិននៅ ក៏អ្នកមិនដឹងជាធ្វើអ្វីខ្ញុំកើតដែរ ឃើញថាខ្ញុំល្អជាមួយអ្នករស់ប៉ុណ្ណឹងហើយ

- តើលោកស្រីមានអ្វីសំគាល់ថា រតនៈជាកូនរបស់លោកស្រីទៅ?

- ស្មានតែល្ងង់! ឆ្លាតដែរទេតើ! ។ យី! សួររកសំបុត្រស្នាមសំគាល់ផង? អ្នកចង់ធ្វើជាតុលាការឬយ៉ាងម៉េច?

- គួរតែលោកស្រីយល់ដែរ ថាខ្ញុំមិនដែលស្គាល់លោកស្រីម្តងណាសោះ ។ ចុះបើមានអ្នកណាគេចង់ព្យាបាទខ្ញុំ រួចនាំគ្នាមកទាមទារយករតនៈគ្រប់ៗគ្នាទៅ ។ តើខ្ញុំទៅរករតនៈឯណាសំរាប់ប្រគល់អោយគេនោះ ។ ខ្ញុំត្រូវតែប្រយ័ត្នដូច្នេះហើយ

- មិនអីទេ! ហ៎កណេះ មើលទៅ... នេះជាសំបុត្រកំណើត... ចេះមើលអក្សរបារាំងទេ?...នេះឈ្មោះខ្ញុំ ហែមមយូរា ដើម្បីកុំអោយសង្ស័យថាមែនឬមិនមែន មើលកាតខ្ញុំទៅមានរូបថតសំគាល់ស្រេច...យ៉ាងម៉េចគ្រប់គ្រាន់ឬនៅ?

សូភាពក្រឡេកមើលឃើញជាក់ច្បាស់ត្រង់នាម និងគោត្តនាមថា៖

Nom : HEM

épouse METZIGER

Prénom : Mayura

សូភាពដឹងថា ប្ដីរបស់លោកស្រីមយូរាជាសាសន៍បារាំង ។

ឃើញច្បាស់ក្រឡែតដូច្នេះហើយ តើអោយនាងប្រកែករបៀបណាទៀតទៅ? ។ ឱ! ព្រះអើយ! តើមានពេលណាដែលលំបាកជាងពេលនេះ? ។ នាងពុំអាចបញ្ចេញប្រតិកម្មអ្វីឃាត់ឃាំងបានទៀតឡើយ ។ អ្នកស្រីមយូរាក៏រូសដៃរតនៈដើរចេញទៅ ។ ប៉ុន្តែរតនៈបែរជាស្រែកយំក្រាញនន្ទៀលដោយពុំចង់ឃ្លាតពីនាងសូភាពសោះឡើយ ។ ទោះជាយ៉ាងណាក្ដី ក៏រតនៈត្រូវមាតាបង្ខំតបណ្ដើរចេញទៅទាំងទឹកភ្នែករហាម ។ វាដើរងាកក្រោយ... ងាក ក្រោយ មក មើល ម្ដាយ ចិញ្ចឹម លុះ គ្រា តែ ចូល ផុត បាត់ ក្នុង រថ យន្ត Renault 9 ពណ៌ប្រាក់ដ៏ថ្មីស្រឡាងក្រោមបញ្ជារបស់លោកស្រីមយូរា ។ សូភាពឈរមើលទាំងអាឡោះអាល័យ ធ្វើអោយឱ្យនាងតឹងស្ទើរតែប្រេះបែក ។

គ្រាន់តែរថយន្តបរឹងចេញបាត់ទៅ សូភាពក៏ស្រែកទ្រហោយំដំងឡើងដោយក្ដីសោកស្ដាយ ស្រណោះអាណិតដល់កុមារតូចដែលនាងធ្លាប់ថ្នាក់ថ្នមព្យាបាលមកជាងមួយឆ្នាំមកហើយនោះ ។

- រតនៈ! រតនៈកូនម្ដាយ! ហ៊ឺ... ហ៊ឹក... ព្រះអង្គអើយ! ហេតុអ្វីក៏លោកផ្ដន្ទាតែរូបខ្ញុំម្ល៉េះ? ។ មនុស្សដែលខ្ញុំស្រឡាញ់ទាំងប៉ុន្មាន... ត្រូវព្រាត់ពីខ្ញុំអស់រលីង!...រតនៈ!...ម្ដាយស្រឡាញ់ឯងណាស់!...ឯងទុកអោយម្ដាយនៅកំព្រាម្នាក់ឯងទៀតហើយ...បងជីវិន!...យកអូនទៅផង...បងទុកអោយអូនរងទុក្ខវេទនាដល់ណាទៀត??!!..

សូភាពស្រែកយំទាល់តែភ្ញាក់ដឹងទាំងខ្លួនប្រាណ ។ ស្រីស្ទុះក្រោកឡើងរាវរករតនៈ...តែរតនៈនៅនិទ្រាក្បែរនាងសោះ ។ កុមារក៏វៃណាស់ដែរ កាលបើម្ដាយរាវប៉ះខ្លួនដូច្នេះ ក៏ភ្ញាក់ស្ទុះងើបឡើងទាំងសើងមម៉ើងទាំងភ័យផងភ្លល់

ផង ។ សូភាពក៏ចាប់ផ្តកកុមារយ៉ាងថ្នាក់ថ្នម រួចពោលទាំងញញឹមថា៖

- គេងវិញទៅកូន គេងវិញទៅ រត់អីទេណាំ កុំភ័យអី!

រតនៈក៏ប្រះខ្លួនគេងវិញតាមបញ្ជាមាតាចិញ្ចឹម ។ ភ្នែកបើកសម្លឹងមើលនាងសូភាពហាក់បីដូចជាចង់សួរពីបុព្វហេតុដែលនាំអោយនាងភ្ញាក់ឡើងទាំងកណ្តាលអាធ្រាត្រយ៉ាងដូច្នេះ ។ សូភាពយល់ការណ៍ ក៏និយាយប្រាប់រតនៈបណ្តើរ ដណ្តប់ភួយអោយបណ្តើរ ថា៖

- ម៉ាក់យល់សប្តិឃើញមានស្រីម្នាក់មកដណ្តើមរតនៈពីម៉ាក់ទៅ ។ ម៉ាក់ពុំចង់អោយកូនឃ្លាតពីទ្រូងម៉ាក់ទេណាំ ។ ម៉ាក់ស្រឡាញ់កូនឯងណាស់ណាំរតនៈ ទើបបានជាម៉ាក់ស្រែកយំយ៉ាងខ្លាំង... ។ ណ្ហើយ! បិទភ្នែកគេងទៅណាំពៅម៉ាក់...

សូភាពពុំចង់អោយសុបិនកំណាចនេះប្រែក្លាយជាការពិតទាល់តែសោះ ។ មួយរាត្រីនោះឯង សូភាពខំគិតដោះស្រាយរកមធ្យោបាយផ្សេងៗដើម្បីអោយនាងអាចរស់នៅជួបជុំជាមួយរតនៈតរៀងទៅ ។ ហួសកម្លាំងនឹងគិតតទៅទៀត កល្យាណីខំអធិស្ឋានព្រះអង្គសុំអោយព្រះអង្គជួយរៀបចំដំណើរជីវិតនាងអោយបានស្រួលបួល និងសុខសាន្តដូចអ្នកផងទាំងពួង ។ តើដំណើរជីវិតរបស់នាងសូភាពនិងរតនៈនឹងត្រូវហួរទៅមុខបែបយ៉ាងណាទៅដែរ? ។

+++++

- ៩ -

សុបិនចម្លែក "មយូរាមកយករតនៈ" នោះចេះតែមកលងបន្លាចអារម្មណ៍នាងសូភាពជារឿយៗ ញុំាងអោយដួងចិត្តនាងភ័យខ្លាច និងបណ្ដាលអោយខួរក្បាលនាងវិះគិតមិនឈប់ឈរសោះឡើយ ។

ចំណែកកុមាររតនៈក៏ស្រាប់តែឈឺក្ដៅខ្លួនឡើងដល់ជិតសែសិបអង្សា ។ នាងភិតភ័យយ៉ាងខ្លាំង ។ តាំងពីបិតារបស់រតនៈចែកឋានទៅដោយសារជម្ងឺនោះមក បើរតនៈឈឺម្ដងៗ ស្រីមានចិត្តខ្វាយខ្វល់ ហើយកើតក្ដីវិតក្កយ៉ាងក្រៃលែង ។ នាងមិនបណ្ដែតបណ្ដោយឡើយ ក៏ប្រញាប់ហៅពេទ្យមកពិនិត្យភ្លាម ។ ស្រីខំបញ្ចុកថ្នាំតាមឱវាទពេទ្យ ថែទាំជម្ងឺរតនៈបណ្ដូលជីវិតនាងយ៉ាងហ្មត់ចត់ដោយថ្នាក់ថ្នមរស់រវំពីចិត្តដោយឥតមានការធ្វេសប្រហែសបន្តិចណាឡើយ ។

បន្ទាប់ពីរតនៈបានជាសះស្បើយដូចដើមវិញមក សូភាពក៏បានទទួលទូរស័ព្ទពីស្ត្រីបារាំងចិត្តធម៌ដែលបានជួយនាងនៅតាមរថភ្លើងនោះ ។ លោកស្រីមុលល្លែរបានហៅនាងសូភាពទៅជួបមិត្តនារីម្នាក់របស់លោកស្រីដែលពិការមកពីប្រទេសអាល្លឺម៉ាញក្នុងគោលបំណងរកមនុស្សម្នាក់ជាជំនួយ ។ ដំណឹង

ដ៏ល្អនេះញ៉ាំងអោយនាងសូភាពរីករាយណាស់ដែរ ព្រោះម្យ៉ាង នាងនិងរតនៈអាចគេចឆ្ងាយពីលោកស្រីមយូរា ។ សំខាន់ជាងនេះទៅទៀតនោះគឺ នាងនឹងមានការងារធ្វើដើម្បីដោះស្រាយជីវភាពរស់នៅសព្វថ្ងៃនេះ ។

បន្ទាប់ពីការយល់ស្របព្រមព្រៀងគ្រប់លក្ខខ័ណ្ឌអស់ហើយ លោកស្រីបារាំងចិត្តធម៌ក៏បានជួយធ្វើសំបុត្រទៅប្រាប់ម្ចាស់ផ្ទះរបស់សូភាព ថែមទាំងជួយដាក់ប្រកាសលក់ឥវ៉ាន់ក្នុងផ្ទះផង ។

មួយខែក្រោយមក សូភាពក៏នាំរតនៈចាកចេញពីទីលំនៅដែលជាទីកន្លែងកំណើតស្នេហ៍ និងជាទីកន្លែងទុក្ខព្រាត់ប្រាសរបស់នាងជាមួយសពលោកជីវ៉ែនទាំងក្រៀមក្រំអាឡោះអាល័យជាទីបំផុត ។

នាងគិតថា ម្តងនេះនាងមុខជាមិនងាយត្រឡប់ចូលមកអេពីណាល់ ឬស្ត្រាស់បួរ៍ក្នុងប្រទេសបារាំងទៀតឡើយ ។ គិតឃើញដូច្នោះហើយ ទើបនាងតាំងចិត្តថា ត្រូវតែទៅអើតមើល ព្រមទាំងលាលីស្យាណា មិត្តនារីជាតិរ៉ុតាលីរបស់នាងបន្តិចសិនមុននឹងឃ្លាតទៅនៅឆ្ងាយ ។ នាងសម្រេចចិត្តយ៉ាងដាច់អហង្ការថា នាងត្រូវតែទៅជួបលីស្យាណាជាគ្រាចុងក្រោយ បើទោះជាវត្តមានរបស់នាងអាចធ្វើអោយលីស្យាណាមានអារម្មណ៍យ៉ាងណាក៏ដោយ ។ នាងគប្បីតែទៅដើម្បីសុំទោសមិត្តនារីរបស់នាងជាចាំបាច់ ។ ទោះយ៉ាងណាក្តី ក៏ស្រីនេះមិនដែលប្រមាថកាតទាន ឬកេងប្រវ័ញ្ចលើរូបនាងដូចលោកស្រីផានីឡើយ ។

មកដល់ស្ថានីយ៍រថភ្លើងស្ត្រាសបួរ៍ សូភាពនិងរតនៈក៏ជិះឡានក្រុងបន្តទៅកាន់ផ្ទះលីស្យាណា ។ គ្រាន់តែចុះពីរថយន្តដឹកនាំភ្លាម សូភាពក៏ឃើញមនុស្សម្នាផ្អើលឆោឡោនៅមុខផ្ទះលីស្យាណា ។ បេះដូងនាងលោតឌឹបៗមួយរំពេច ។ ស្រីនឹកភ្នកដល់សំដីមួយម៉ាត់របស់លីស្យាណាដែលធ្លាប់និយាយ

ប្រាប់នាងថា "បើកាលណាសូភាពចាកចោលខ្លួនទៅនោះ ខ្លួននឹងសម្លាប់ខ្លួន..." ។ តែទេ! វាដូចជាមិនទំនងសោះ ត្បិតនាងចាកចេញចោលល្អិស្សាណាជាងមួយឆ្នាំមកហើយ សមរីមកសម្លាប់ខ្លួននៅពេលនេះទៅវិញ? ។

ដៃម្ខាងកាន់វ៉ាលីស ដៃម្ខាងកាន់រតនៈ សូភាពខំជ្រែកហ្វូងមនុស្សដើម្បីចូលទៅមើលជិតដើម្បីអោយអស់ក្តីសង្ស័យ ។

ពេលចូលទៅដល់ នាងឃើញគេសែងស្រីម្នាក់ដែលមានកេសាជិតដាមដោយលោហិតស្រស់ៗ ។ សូភាពខំរើតមើលមុខអោយច្បាស់ ។ ពុទ្ធោអើយ! ល្អិស្សាណាមែនទេតើ! ។ ច្បាស់ថាជាល្អិស្សាណាពិតហើយនោះ សូភាពក៏ស្ទុះចូលទៅតាមមើលល្អិស្សាណាដែលដេកស្តូកស្តឹងនៅក្នុងឡានពេទ្យធ្វើអោយភ្ញាក់ងារប៉ូលីសទាំងឡាយស្រឡាំងកាំង ហើយបណ្តេញនាងអោយទៅឆ្ងាយផង ។ ប៉ុន្តែ សូភាពបានអះអាងថានាងបានស្គាល់នារីរងគ្រោះច្បាស់ ហើយនាងក៏សុំគេជិះឡានទៅមន្ទីរពេទ្យជាមួយល្អិស្សាណា ។ សូភាពឃើញពេទ្យគេបន្តោងឈាមអោយល្អិស្សាណា ។ នាងគ្រវីក្បាលសម្រក់ទឹកភ្នែកយ៉ាងខ្លោចផ្សារអាណិតមិត្តនារីនាងពន់ពេកក្រៃ ។

ទៅដល់មន្ទីរពេទ្យ គេក៏រុញនារីរងគ្រោះទៅកាន់បន្ទប់ព្យាបាលបន្ទាន់ ។ សូភាពខំដើរតាម លុះឃើញល្អិស្សាណាបើកភ្នែកព្រឹមៗ នាងក៏ស្ទុះទៅជិត ហៅមិត្តនារីទាំងរំជើបរំជួលចិត្ត ។ ល្អិស្សាណាយល់ជាក់ថាសូភាពហើយ ស្រីរងគ្រោះក៏ខំហាមាត់ម្តបៗនិយាយមកកាន់សូភាពទាំងដង្ហក់ថា៖

– គ្នា! ខំស្វែងរកឯង...គ្រប់ទិសទី...គ្រប់កន្លែងណាដែល...គេប្រាប់គ្នា...ថាមានខ្មែររស់នៅក្នុងខេត្តស្ត្រាស់ប្អួរ...១ឆ្នាំប្លាយហើយ...ដែលយើងបែកគ្នា...ស្គាល់តែ

ការរស់សង្ឃឹម...សូឯងមកនៅជា...មួយគ្នាវិញទៅ...ណា៎

- ចា៎ះ!

សូភាពឆ្លើយថា "ចា៎ះ" ព្រោះយល់ថា ជីវិតរបស់ល្វីស្យាណាកំពុងស្ថិតក្នុងគ្រោះថ្នាក់ ។ ទោះបីចម្លើយ "ចា៎ះ" មួយម៉ាត់នេះ ជាពាក្យភូត ភរកុហកក៏ពិតមែន តែក៏អាចផ្តល់សេចក្តីសង្ឃឹមតូចមួយ និងជាការជួយលើកទឹកចិត្តល្វីស្យាណាខ្លះដែរ ។

សូភាពយកដៃទៅស្ទាបរង្កៀលថ្ពាល់មិត្តនារីដោយឥតខ្លាចប្រឡាក់ឈាមឡើយ ថែមទាំងពោលពាក្យលួងលោមមិត្តនារីកំសត់របស់នាងទាំងរន្ធត់ចិត្តជាពន់ពេក៖

- តាំងចិត្តអោយក្លាហានឡើងសម្លាញ់!

- អរគុណណាស់!...សូ! គ្នាចង់និយាយប្រាប់ឯងរឿងមួយ...

- កុំខំនិយាយពេកក្រែងនាំអោយបាត់ខ្លាំងណា៎ស្យាណា

- មិនអីទេ!...កាលបើឯង...ចាកចោលគ្នា...បាត់ទៅ...គ្នាក៏បានជួបប្រទះស្រីម្នាក់ទៀត...នាងនោះ...ជាស្រីបារាំង...គ្នាក៏ស្រឡាញ់គេ...ដូចកាលគ្នាស្រឡាញ់ឯងដែរ គ្នាស្មានតែស្រីបារាំងនោះទំនេរ...ប៉ុន្តែគេមានប្តីរបស់គេ.....គ្នាខកចិត្ត...អស់សង្ឃឹមពេក...មួយលើក...ជាពីរលើក...គ្នាក៏លែងចង់...រស់...តទៅទៀត

និយាយបានតែប៉ុណ្ណោះ កម្មករពេទ្យក៏រុញគ្រែនារីរងគ្រោះចូលបន្ទប់ព្យាបាលបាត់ទៅ ដោយទុកអោយនាងសូភាពនិងកុមាររតនៈនៅអង្គុយចាំយ៉ាងអន្ទះសារជាទីបំផុត ។ សូភាពតានតឹងក្នុងឧរាជាពន់ពេក ។ យូរៗគេឮសូរនាងដកដង្ហើមធំម្តងៗ ។ កាលណាឮមាតាធ្វើដូច្នេះ រតនៈតែងតែងើបសម្លឹងមុខមាតាទាំងស្រងូតស្រងាត់ ។ យល់ឃើញមាតាកំពុងព្រួយចិត្ត រតនៈមិនហ៊ាននិយាយសាកសួរប៉ាច់ប៉ប៉ោចដូចសព្វមួយដងឡើយ ។ នាងសូភាព

អង្អែលក្បាលបុត្រភ្វា ហើយថ្លែងប្រាប់ថា៖
- កូននៅអង្គុយចាំម៉ាក់នៅកន្លែងនេះសិនហើយណា៎ ម៉ាក់ទៅរកទិញនំប៉័ងមកអោយញ៉ាំ
- រួចហើយ យើងទៅណាទៀតម៉ាក់?
- យើងទៅឆ្ងាយទៀតណា៎កូន ។ ឥឡូវនេះម៉ាក់ពុំទាន់ដាច់ចិត្តទៅណាភ្លាមទេ ។ ម៉ាក់ត្រូវចាំមើលពួកម៉ាករបស់ម៉ាក់បន្តិចសិន ។ មិនយូរប៉ុន្មានទេ កាលណាលោកគ្រូពេទ្យចេញមក យើងអាចដឹងពីអាការៈរបស់អ្នករបួសហើយ ។ ម៉ាក់ទៅសិនហើយណា៎ អង្គុយអោយស្ងៀម កុំដើរទៅណាអោយសោះ ប្រយ័ត្នវង្វេង
- បាទ!

សូភាពក៏ប្រញាប់ចេញទៅយ៉ាងរួសរាន់ ។

មួយស្របក់ក្រោយមក នាងក៏ត្រឡប់មកវិញទាំងត្រហេបត្រហប ។ ជួនពេលដែលលោកវេជ្ជបណ្ឌិតចេញពីបន្ទប់ព្យាបាលតែម្តង ។ សូភាពក៏ដើរលឿនស្ទើរសំដៅទៅគ្រូពេទ្យបារាំង ។ រួចសួរទាំងក្តីបារម្ភថា៖
- តើអ្នកជម្ងឺយ៉ាងម៉េចទៅហើយលោកដុកទ័រ?

លោកគ្រូពេទ្យគ្រវីក្បាល ហើយបញ្ចេញទឹកមុខយ៉ាងស្រងូតស្រងាត់ថា៖
- ហួសពេលហើយអ្នកស្រី!!

ពាក្យនេះកាលណា នាងសូភាពក៏ភ័ន្តភាំងស្រឡាំងកាំងធ្លាក់នំប៉័ងពីរដុំពីដៃដោយពុំដឹងខ្លួន ។ ស្រីរត់រឹងចូលទៅក្នុងបន្ទប់ព្យាបាលដោយគ្មានសុំអនុញ្ញាតិពីអ្នកណាសោះឡើយ ។ នារីកំសត់ដើរទៅជិតគ្រែឃ្លីស្យាណាដែលដេកស្តូកស្តឹងហ្នឹងថ្កល់ក្រោមក្រណាត់ស ។ នាងស្រក់ទឹកភ្នែកតក់ៗ ។ គឺជាទឹកភ្នែកសោកស្តាយចំពោះអំពើឆ្គាំឆ្គងដែលនាងបានប្រព្រឹត្តទៅលើបិត្តនារីរបស់

នាង ។ កំហុសនោះ សូភាពពុំទាន់បានសុំទោសមួយម៉ាត់នៅឡើយផង ស្រាប់តែមិត្តនារីរបស់នាងស្លាប់ចោលនាងទៅហើយ ។ សូភាពរស់កម្លាំងចិត្តរលីងធេងពីក្នុងប្រាណ ។ ស្រីដឹកដៃកុមាររតនៈចេញពីមន្ទីរពេទ្យទាំងក្តីសោកសៅ ។

រាត្រីកាលចូលមកដល់ សូភាពទិញអំប៊ូហ្គើ (Hamburger) ពីរដុំទៀតនិងទឹកក្រូចពីរកំប៉ុងយកចូលតាមក្នុងសណ្ឋាគារតូចមួយដែលនាងត្រូវសំណាក់បណ្តោះអាសន្ននាយប់នេះ ។

រតនៈបរិភោគនំ រួចក៏ប្រះខ្លួននិទ្រាយកំបាត់ទៅ ។

ចំណែកសូភាព នាងគ្មានទឹកឃ្លាន គ្មានទឹកស្រេកអ្វីទាំងអស់ ។

ស្រីរអ័ពបើកវ៉ាលីសថ្មៗ រើរករូបថតអនុស្សាវរីយ៍ទាំងប៉ុន្មានរបស់នាងនិងជីវិនបុរសគូស្នេហ៍ដែលឈរកៀកកិតនែបនិត្យជិតគ្នាបញ្ជាក់ពីសេចក្តីស្នេហាដ៏បរិសុទ្ធមកឱបថ្នាប់នឹងផែនទ្រូង ទាំងទឹកនេត្រាហូររហៀង ។

មរណភាពរបស់ល្អិស្បាណាធ្វើអោយនាងនឹកទៅដល់មរណភាពរបស់ជីវិនម្ចាស់រូបថតដែលនាងបានយល់ត្រឹមតែស្រមោលរូបលើក្រដាសឥតវិញ្ញាណប៉ុណ្ណោះ ។ នាងនឹកស្រណោះអាណិតខ្លួន ទ្រូងអណ្តែនអនិច្ចាវាសនានាងដែលជួបប្រទះតែការព្រាត់ប្រាសដូច្នេះ? នាងគិតថា ជីវិតនាងជាជីវិតដែលងងឹតសូន្យសុងគ្មានរស្មី ដូចជារាត្រីខ្វះដួងចន្ទ្រា ដូចជាទិវាខ្វះទិនករ ។

ឱ! កំណាច! កំណាចនៃព្រហ្មលិខិត! ព្រហ្មលិខិតអ្នកឃោរឃៅណាស់ចំពោះរូបនាង ។ រូបនាងប្រៀបដូចជាស្មៅមួយគុម្ពកណ្តាលវាលដ៏ល្ហេវល្ហ ប្រៀបបាននឹងចកមួយតូចកណ្តាលមហាសាគរដ៏ធំល្វឹងល្វើយ ឬប្រៀបបាននឹងម្លូដែលគ្មានជន្លង់យ៉ាងដូច្នោះដែរ ។

ស្រីកំសត់ខំប្រឹងទទួលវាសនាអភ័ព្វរបស់នាងទាំងញញើមៗលាយទ្បំទៅ

ដោយទឹកភ្នែក ។ ស្រីខំតស៊ូក្រាញនរៀលទ្រាំរស់ដើម្បីជាក្បួនជូនកូនរតនៈ បុត្របណ្ដូលបណ្ដាច់របស់សពលោកជីវិនប្រុសស្នេហ៍នាងទៅរកត្រើយអនាគត ដោយទឹកសង្ឃឹមជាមុនថា មេឃថ្មីដីថ្មីនៅប្រទេសអាល្លឺម៉ាញនឹងក្លាយជាជំរកដ៏សុខសាន្តត្រជាក់ត្រជុំសំរាប់នាងនិងរតនៈតាំងពីថ្ងៃស្អែកតទៅ... ។

- ចប់ -

សរសេរចប់នៅសាន់នីរ ថ្ងៃទី ៨ សីហា ១៩៨៥

រៀបរៀងកែចប់នៅម៉ុងទីញ៉ី ថ្ងៃ ៣០ តុលា ១៩៨៨



# ជើងមេឃថ្មី

## NOUVEL HORIZON

Roman de

Madame PECH Sangwawann

គ្មានគ្រួសារ គ្មានមិត្តភក្តិ គ្មានបង្អែកនៅក្នុងលោកដ៏ធំធេងអយុត្តិធម៌នេះ នាងសូភាពត្រូវតែខំបង្អោនខ្លួន និងគោរពតាមបញ្ជាដ៏តឹងរ៉ឹងរបស់លោកស្រីផានី ញ៉ាំងសង្វាក់ជីវិតទោលរបស់នាងជួបប្រទះតែការលំបាកយ៉ាងក្រៃលែង ។

បើទោះជាមានបុរសម្នាក់ឈ្មោះ "ជំនោរ" ដែលជាជនកំព្រាដូចនាងដែរ ខំតាមស្រឡាញ់ និង តាមស្ដីដណ្ដឹងនាងយ៉ាងណាក្ដី ក៏លោកស្រីផានីនារីដែលមានចិត្តជាមារធ្លាប់តែកេងប្រវ័ញ្ចលើជីវិតអភ័ព្វរបស់នាងនោះ បានប្រើគ្រប់ល្បៀតមធ្យោបាយ កំចាត់កំចាយសេចក្ដីស្នេហានេះអោយប្រេះឆាលុះត្រាតែបានឈ្នះទៅតាមឧបាយកលដ៏ខ្មៅងងឹតរបស់ខ្លួន ។

ចុះបើដល់ម្ល៉ឹងទៅហើយ តើនាងសូភាពស៊ូទ្រាំរស់នៅក្នុងជីវិតគ្រោតគ្រាតគ្មានច្រកចេញគ្មានន័យនេះ តទៅទៀតឬទេ? ។ ខំគេចពីផង់ ចូលទ្រុងអន្ទាក់ គេចពីឧបសគ្គៈមកជួបឧបសគ្គ ... ការស្រេកឃ្លានចង់ស្គាល់សេរីភាពរបស់នារីខ្មែរម្នាក់ ដូចយ៉ាងនាងសូភាពដែលធ្លាប់តែស្គាល់និងទទួលការអប់រំតាមលក្ខណៈប្រពៃណីខ្មែរ ជានារីដែលអវិជ្ជាឆោតល្ងង់ស្លូតត្រង់នោះ នាងអាចរកឃើញដំណោះស្រាយថ្មីដ៏ប្រសើរសំរាប់ប្រឈមមុខតទល់នឹងជីវភាពថ្មីលើទឹកដីប្រទេសបារាំងបានដែរឬទេ? ។

តើព្រហ្មលិខិតបានអូសទាញជំរុញនាងអោយខំតស៊ូក្រោមផ្ទៃមេឃថ្មីទៅរកជើងមេឃថ្មីដែលពោរពេញទៅដោយសុភមង្គលដូចជាការស្រមៃចង់បានរបស់នាងដែរឬទេ?

នេះជាខ្សែជីវិតមួយរបស់នារីខ្មែរភៀសខ្លួនម្នាក់នៅលើទឹកដីថ្មី ក្រោមមេឃថ្មីដែលបេះដូងលោកអ្នកនាងរំភើបចង់ដឹង ចង់សួរ ឆ្ងល់ និង គួរតាមដាន ..........


ASSOCIATION DES ECRIVAINS KHMERS A L'ETRANGER

18, Allée Wolfgang Mozart

95370 MONTIGNY-LES-CORMEILLES

TEL : (16-1) 34-50-15-47


PRIX : 45 F.F. ou 10 $ U.S.